ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រធានបទៈ ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា( SEIP ) ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេល ករណីសិក្សាៈ ខេត្តបាត់ដំបង

# EFFECTIVENESS OF IMPLEMENTING SECONDARY EDUCATION QUAILITY IMPROVEMENT PROJECTS THAT SUPPORT TEACHING AND LEARNING AT BAVEL HIGH SCHOOL

ដោយ/by

យឿន វន្ថា/ YOEUN VANTHA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រធានបទ: ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា( SEIP ) ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេល

# ករណីសិក្សា៖ ខេត្តបាត់ដំបង

EFFECTIVENESS OF IMPLEMENTING SECONDARY EDUCATION QUAILITY IMPROVEMENT PROJECTS THAT SUPPORT TEACHING AND LEARNING AT BAVEL HIGH SCHOOL

ដោយ/by

យឿន វន្ថា/ YOEUN VANTHA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

គ្រូដឹកនាំបង្គោល៖ លោក ថៃ ហេង

គ្រូដឹកនាំរង៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ: ៥៧០៨៧ អយក.ខក**

(**ការសម្គាល់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារុំម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ទី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វិក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី វេង្ហា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នុ ចន្ធី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ-ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# សេចក្តីអះអាងរបស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើង «**ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា** (SEIP) **ដែលជួយដល់ការបង្រៀន និងរៀន នៅវិទ្យាល័យបវេល ខេត្តបាត់ដំបង**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រ ជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំ ទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយ ត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែកត្តិក ឆ្នាំជូត ទោស័កព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

**ហត្ថលេខា**

**យឿន វណ្ណា**

# លិខិតបញ្ជាក់

**លោក ថៃ ហេង ជាគ្រូដឹកនាំបន្ទោល**

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ជាគ្រូដឹកនាំរង**

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោកស្រី **យឿន វណ្ណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា** (SEIP) **ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេល ខេត្តបាត់ដំបង**» ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

| | |
|---|---|
| .......................................... | .......................................... |
| **លោក ថៃ ហេង** | **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** |
| ជានាយករងវិទ្យាស្ថានជាតិអប់រំ | ជានាយកវិទ្យាស្ថានជាតិអប់រំ |

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះ អាចសម្រេចដល់គោលដៅប្រកដដោយភាពជោគជ័យ គឺដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់ឱកាសជួយសម្របសម្រួល និងជ្រោមជ្រែងតាំងពីដើមរហូតដល់ចប់។ ហេតុនេះនាងខ្ញុំដែលជាអ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មាន ឧបត្ថម គាំទ្រ និងផ្តល់ឱកាសឲ្យខ្ញុំបានរៀនសូត្រទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។

លោកឪពុកក្មេក អ្នកម្តាយក្មេក និងស្វាមីជាទីស្រលាញ់ដែលតែងតែលើកទឹកចិត្ត និងគាំទ្រដល់ការបន្តការសិក្សារបស់ខ្ញុំដោយមិនគិតពីការនឿយហត់។

ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំដែលបានរៀបចំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឲ្យនាងខ្ញុំមានឱកាសបន្តការសិក្សានៅទីនេះ។

គណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកលោកគ្រូ អ្នកគ្រូទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់នាងខ្ញុំដោយមិនគិតពីការនឿយហត់។

លោក ថៃ ហេង ជាគ្រូដឹកនាំបង្គោលដែលជានាយករងវិទ្យាស្ថានជាតិអប់រំ លោកតែងតែឆ្លៀតពេលវេលាដ៏មានតម្លៃក្នុងការផ្តល់គំនិតណែនាំទ្រឹស្តីល្អៗកែលម្អរាល់ចំណុចដែលខ្វះខាត ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្ត បច្ចេកទេស វិធីសាស្ត្រនានា ព្រមទាំងផ្តល់ឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទរបស់នាងខ្ញុំ មិនតែប៉ុណ្ណោះលោកបានជួយបង្ហាញទិសដៅដល់រូបនាងខ្ញុំ រហូតធ្វើឲ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ជាគ្រូដឹកនាំរង និងជានាយកវិទ្យាស្ថានជាតិអប់រំ លោកតែងតែឆ្លៀតពេលវេលាដ៏មានតម្លៃក្នុងការកែសម្រួល រចនាបទ ឃ្លាប្រយោគ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំងជួយកែសម្រួលកម្រងសំណួរផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការវិភាគទិន្នន័យផងដែរ។

មិត្តរួមថ្នាក់ជំនាន់ទី៧ ទាំងអស់ដែលតែងតែជួយផ្តល់កម្លាំងចិត្តដល់រូបនាងខ្ញុំ តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ឬឯកសារផ្សេងៗដែលទាក់ទង ធ្វើឲ្យនាងខ្ញុំមានចិត្តស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយដើម្បីសម្រេចគោលដៅនៃការស្រាវជ្រាវសរសេរនិក្ខេបបទនេះ។

គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដែលពាក់ព័ន្ធនឹងភាគសំណាកទាំងអស់ដែលបានចូលរួមឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការផ្តល់ទិន្នន័យធ្វើឲ្យការស្រាវជ្រាវនេះទទួលបានភាពជោគជ័យ។

ជាទីបញ្ចប់នេះនាងខ្ញុំសូមជូនពរដល់អ្នកមានគុណទាំងទ្វេរ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការដៃគូអភិវឌ្ឍ លោកគ្រូដឹកនាំ ឯកឧត្តមបណ្ឌិត និងលោកគ្រូ អ្នកគ្រូទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ មានសុខភាពល្អបរិបូណ៌ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប

ការអប់រំមាននាទីយ៉ាងសំខាន់បំផុតក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍប្រទេសជាតិ ជាពិសេសការអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះដែលក្រសួងអប់រំ យុវជន និងកីឡាបានស្វែងរកយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ តាមរយៈការសហការគ្នាជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធផ្សេងៗ។ ជាពិសេសក្រសួងអប់រំបានសហការគ្នា ជាមួយ **ធនាគារពិភពលោក** (WB) ដែលជាដៃគូរអភិវឌ្ឍយ៉ាងល្អតាំងពីដើមរៀងមក និងបានបន្តគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានជួយទាំងផ្នែកហិរញ្ញប្បទាន និងបច្ចេកទេស។ ជាលទ្ធផលក្រសួង អប់រំ និង ធនាគារពិភពលោក បានសម្រេចធ្វើការសហការគ្នា តាមរយៈគម្រោងមួយឈ្មោះថា «**គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា** (SEIP)»។ ដើម្បីបង្កើនគុណភាពអប់រំនៅប្រទេសកម្ពុជា ដូច្នេះគម្រោងបានកំពុងធ្វើសកម្មភាពក្នុងគោលបំណងបីសំខាន់ៗ គឺ **ទី១** បង្កើនអគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាលារៀនមធ្យមសិក្សា តាមរយៈការជួយសាងសង់បន្ថែមនូវអគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងសាលារៀន។ **ទី២** ដាក់ឲ្យអនុវត្តសាកល្បងនូវប្រព័ន្ធការគ្រប់គ្រងសាលារៀន(SBM) ដែលឆ្លុះបញ្ចាំងពីវិមជ្ឈការ និងសហវិមជ្ឈការ និងគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ។ **ទី៣** បង្កើនប្រសិទ្ធភាពការបង្រៀន និងការរៀនរបស់គ្រូនិងសិស្ស តាមរយៈការចុះជួយគ្រូផ្ទាល់នៅតាមសាលារៀន និងតាមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន។ ដូច្នេះគម្រោង កដូចជាក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតសំខាន់ទៅលើការវាយតម្លៃមុនគេ តាមរយៈការធ្វើកំណែទម្រង់លើការប្រឡងស្តង់ដាប្រចាំខែ ព្រោះការប្រឡងប្រចាំខែជាការវាយតម្លៃកម្រិតថ្នាក់រៀន ដើម្បីអភិវឌ្ឍការបង្រៀន និងការរៀនរបស់គ្រូនិងសិស្សយ៉ាងមានប្រសិទ្ធភាព។

ដូចនេះក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវមានគោលបំណងរកឲ្យឃើញនូវ៖

១. លទ្ធផលសិក្សារបស់សិស្សក្រោយពេលអនុវត្តគម្រោងកែលម្អសាលានៅមធ្យមសិក្សា(SEIP)

២.លទ្ធផលនៃការគ្រប់គ្រងសាលារៀនក្រោយពេលការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP)នៅវិទ្យាល័យបវេល។

ការសិក្សាស្រាវជ្រាវនេះ ដោយផ្អែកលើលទ្ធផលសិក្សារបស់សិស្សឆមាសទី១ ឆ្នាំ២០១៨-២០១៩ និងឆ្នាំ២០១៩-២០២០ និងឯកសារមួយចំនួនដែលពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា និងអ្នកស្រាវជ្រាវមុនៗ។ ទិន្នន័យដែលប្រមូលបានពីវិទ្យាល័យបវេលមានចំនួន៥៨នាក់ ស្រី៣៧នាក់ រួមមាន គណៈគ្រប់គ្រង២នាក់ លោកគ្រូ អ្នកគ្រូចំនួន២២នាក់ ស្រី១៥នាក់ និងសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ចំនួន ៣៤នាក់ ស្រី២២នាក់។ អ្នកស្រាវជ្រាវបានធ្វើការសិក្សាតាមបែបបរិមាណវិស័យផង និងតាមបែបគុណវិស័យផង ដោយផ្តោតលើសំណួរស្រាវជ្រាវចំនួនពីរគឺ **(១)** តើមានភាពខុសគ្នាដូចម្តេចរវាងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាចាស់(ឆ្នាំ២០១៨-២០១៩) និងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាថ្មី(ឆ្នាំ២០១៩-២០២០)ក្រោយពេលអនុវត្តកម្មវិធីកំណែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP)? **(២)** តើគម្រោង(SEIP) បានជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះ ទៅលើការគ្រប់គ្រងសាលារៀន ការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ?

តាមលទ្ធផលដែលបានពីការសិក្សាស្រាវជ្រាវ បានបង្ហាញឲ្យឃើញពី ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលបានជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេល ដូចខាងក្រោម៖

១. តាមរយៈការប្រៀបធៀបមធ្យមពិន្ទុរបស់សិស្សសម្រាប់ឆមាសទី១ **ថ្នាក់ទី៧(២០១៨-២០១៩) ជាមួយសិស្សថ្នាក់ទី៨(២០១៩-២០២០)** អ្នកស្រាវជ្រាវសង្កេតឃើញថា មធ្យមពិន្ទុតាមមុខវិជ្ជានីមួយៗឃើញ ថាមានការកើនឡើងគួរឲ្យកត់សំគាល់ នេះបង្ហាញឲ្យឃើញផងដែរអំពីការយកចិត្តទុកដាក់ក្នុងការខិតខំរៀនសូត្ររបស់សិស្សបានល្អ សិស្សមានការស្វ័យសិក្សាខ្ពស់ ជាពិសេសបង្ហាញឲ្យឃើញពីការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាដែលប្រកបដោយអភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព ជាពិសេសមានការសហការគ្នាល្អជាមួយលោកគ្រូ អ្នកគ្រូក្នុងការបង្ហាត់បង្រៀនសិស្សដោយស្មារតីទទួលខុសត្រូវលើតួនាទី ភារកិច្ចរបស់ខ្លួនម្នាក់ៗបានល្អ។ ដោយឡែកក៏មានមុខវិជ្ជា២មានការថយចុះមធ្យមពិន្ទុគឺប្រវត្តិវិទ្យា និងគីមីវិទ្យា អ្នកស្រាវជ្រាវយល់ថា ការធ្លាក់ចុះនេះអាចបណ្តាលមកពីកំហុស

បច្ចេកទេសក្នុងការធ្វើវិញ្ញាសាតេស្តស្តង់ដាប្រចាំខែ នឹងអាចមកពីលោកគ្រូ អ្នកគ្រូមិនសូវយល់ពីរបៀបធ្វើវិញ្ញាសាស្តង់ដាប្រចាំខែនីមួយៗ និងអាចមកពីសិស្សអវត្តមានច្រើនក្នុង ពេលធ្វើតេស្តប្រចាំខែជាដើម។

២. ការប្រៀបធៀបមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) **គឺ ១៦.៦២** និងមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៨(២០១៩-២០២០) **គឺ ២៦.៦៥។** អ្នកសិក្សាស្រាវជ្រាវយល់ថា មធ្យមសរុបមានការកើនឡើងនេះ បញ្ជាក់ថាការអនុវត្តគម្រោងកែលម្អការ អប់រំនៅមធ្យមសិក្សា(SEIP) ដែលបានជួយដល់ការរៀន និងការបង្រៀននៅវិទ្យាល័យបវេលពិតជាមានប្រសិទ្ធភាពប្រាកដមែន។

៣. តាមរយៈការប្រៀបធៀបមធ្យមពិន្ទុរបស់សិស្សសម្រាប់ឆមាសទី១ **ថ្នាក់ទី៧(២០១៨-២០១៩) ជាមួយសិស្សថ្នាក់ទី៧(២០១៩-២០២០)** អ្នកស្រាវជ្រាវសង្កេតឃើញថា សិស្សទាំងពីកម្រិតថ្នាក់នេះសុទ្ធតែចាប់ផ្ដើមឈានចូលកម្រិតអនុវិទ្យាល័យ និងត្រូវឆ្លងកាត់ការធ្វើតេស្តចូលរៀនផងដែរ ហើយចំពោះមធ្យមពិន្ទុតាមមុខវិជ្ជានីមួយៗឃើញថាមានការកើនឡើងគួរឲ្យកត់សំគាល់ នេះបង្ហាញឲ្យឃើញផងដែរអំពីការយកចិត្តទុកដាក់ក្នុងការខិតខំរៀនសូត្ររបស់សិស្សបានល្អពីមួយឆ្នាំទៅមួយឆ្នាំ សិស្សមានការស្វ័យសិក្សាខ្ពស់ ជាពិសេសបង្ហាញឲ្យឃើញពីការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាដែលប្រកបដោយអភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព ជាពិសេសមានការសហការគ្នាល្អជាមួយលោកគ្រូ អ្នកគ្រូក្នុងការបង្ហាត់បង្រៀនសិស្សដោយស្មារតីទទួលខុសត្រូវលើតួនាទី ភារកិច្ចរបស់ខ្លួនម្នាក់ៗបានល្អ។ ដោយឡែកក៏មានមុខវិជ្ជា២មានការថយចុះមធ្យមពិន្ទុគឺប្រវត្តិវិទ្យា និងគីមីវិទ្យា អ្នកស្រាវជ្រាវយល់ថា ការធ្លាក់ចុះនេះអាចបណ្ដាលមកពីកំហុសបច្ចេកទេសក្នុងការធ្វើវិញ្ញាសាតេស្តស្តង់ដាប្រចាំខែ និងអាចមកពីលោកគ្រូ អ្នកគ្រូមិនសូវយល់ពីរបៀបធ្វើវិញ្ញាសាស្តង់ដាប្រចាំខែនីមួយៗ និងអាចមកពីសិស្សអវត្តមានច្រើនក្នុងពេលធ្វើតេស្តប្រចាំខែជាដើម។

៤. ការប្រៀបធៀបមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) **គឺ ១៦.៦២** និងមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៩-២០២០) **គឺ ២២.៧០។**

អ្នកសិក្សាស្រាវជ្រាវយល់ថា មធ្យមសរុបមានការកើនឡើងនេះ បញ្ជាក់ថាការអនុវត្តគម្រោងកែលម្អការអប់រំនោមធ្យមសិក្សា(SEIP) ដែលបានជួយដល់ការរៀន និងការបង្រៀននៅវិទ្យាល័យបវេលពិតជាមានប្រសិទ្ធភាពប្រាកដមែន។

៥. ការប្រៀបធៀបគម្លាតស្តង់ដាសរុប នៅឆមាសទី១ សម្រាប់សិស្សថ្នាក់ទី៧(២០១៨-២០១៩) គឺ**៩.៣៥** ឯសិស្សថ្នាក់ទី៨(២០១៩-២០២០)មានគម្លាតស្តង់ដាសរុបគឺ **១២.០៨**។ យើងឃើញថាគម្លាតស្តង់ដាសរុបមានការកើនឡើង នេះបង្ហាញឲ្យឃើញថាប្រសិទ្ធភាពនៃការប្រឡងប្រចាំខែឬឆមាសកាន់តែតឹងរឹង និងច្បាស់លាស់ នោះធ្វើឲ្យមានគម្លាតស្តង់ដាកាន់តែធំដែរ មានន័យថាសិស្សពិតជាបានបញ្ចេញសមត្ថភាពផ្ទាល់ខ្លួន មិនអាចចម្លងគ្នាបាន ឬសួរគ្នាបាន។ ទាំងនេះ បញ្ជាក់អំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនោមធ្យមសិក្សា ដែលបានជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលពិតជាមានប្រសិទ្ធភាព។

៦. ការប្រៀបធៀបគម្លាតស្តង់ដាសរុប នៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧(២០១៨-២០១៩)គឺ **៩.៣៥** និងសិស្សថ្នាក់ទី៧(២០១៩-២០២០) **គឺ១២.៤៩**។ យោងតាមទិន្នន័យនេះ យើងឃើញថាគម្លាតស្តង់ដាសរុបគ្រប់មុខវិជ្ជាមានការកើនឡើង បញ្ជាក់ថារាល់ការរៀន និងបង្រៀនគឺមានការរឹតបន្តឹង ជាពិសេសការប្រឡងប្រចាំខែនីមួយៗមានតម្លាភាព មានន័យថាសិស្សមិនអាចចម្លងគ្នា ឬសួរគ្នាបានទេ ហើយគ្រូបង្រៀនវិញគឺមានការបំពេញការងារ បង្រៀនយ៉ាងយកចិត្តទុកដាក់ ខិតខំស្រាវជ្រាវវិធីសាស្ត្រថ្មី ចំណេះដឹងថ្មីៗសម្រាប់យកមកបង្រៀនសិស្សឲ្យកាន់តែប្រសើរថែមទៀត។ ទាំងនេះបង្ហាញឲ្យយើងឃើញពីប្រសិទ្ធភាពនៃការអនុវត្តគម្រោង កែលម្អគុណភាពអប់រំនោមធ្យមសិក្សា ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាព។

៧. ក្រោយពេលសាលាបានអនុវត្តគម្រោង SEIP នេះមកឃើញថា សាលាទទួលបានលទ្ធផលសិក្សារបស់ល្អជាងមុន ការគ្រប់គ្រងមានការកែប្រែល្អជាងមុន ចំណែកលោកគ្រូ អ្នកគ្រូ ចំនួន៤នាក់ បានទៅសិក្សាបន្តដើម្បីបង្កើនគុណវុឌ្ឍិបន្ថែម ហើយមានការកែប្រែឥរិយាបទទាំងការបំពេញការងារ ការមក

បង្រៀន និងការមករៀនរបស់សិស្សបានទៀងទាត់ពេលវេលាល្អ គ្រូបង្រៀនមានកិច្ចតែងការ និងមានការដឹកនាំសិស្សធ្វើពិសោធន៍ ឬធ្វើសកម្មភាពផ្សេងៗដែលគាំទ្រដល់ការរៀន និងការបង្រៀន លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាទទួលបានការបណ្តុះបណ្តាលបន្ថែមលើឯកទេសក្នុងការបង្រៀន និងការគ្រប់គ្រងសាលាតាមរយៈគម្រោង។ ជារៀងរាល់ខែមានការប្រជុំការងារបានទៀងទាត់ និងមាន ការប្រជុំបច្ចេកទេសតាមមុខវិជ្ជានីមួយៗបានទៀងទាត់ ជាពិសេស សិស្សត្រូវឆ្លងកាត់ការធ្វើប្រឡងស្តង់ដាប្រចាំខែម្តង រាល់ចុងខែ។ ទោះបីជាការអនុវត្តគម្រោង SEIP នៅវិទ្យាល័យបវេលនេះនៅមានកម្រិតក៏ដោយ គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ និងគណៈទ្រទ្រង់សាលានៅតែខិតខំបន្ត ដើម្បីបំពេញការងារអស់ពីកម្លាំងកាយចិត្ត និងមនសិការលើការងារ ដើម្បីធ្វើឲ្យសិស្សានុសិស្សនៅវិទ្យាល័យបវេលទទួលបានចំណេះដឹងថ្មីស្របតាមការសិក្សាបែបសតវត្សន៍ទី២១ បង្រៀនសិស្សឲ្យចេះអំពីបំណិនជីវិតច្បាស់លាស់ ការចេះរួមរស់ជាមួយគ្នាប្រកបដោយសុខដុម មានសីលធម៌ល្អក្នុងសង្គម។

# Abstract

Education plays a very important role in human resource development and is the backbone of the nation's development, especially high quality and effective education. At the same time, the Ministry of Education, Youth and Sports has sought strategies for education reform through collaboration with development partners and other stakeholders. In particular, the Ministry of Education has partnered with the World Bank (WB), a good development partner since the beginning, and has continued to support the Ministry of Education, Youth and Sports, which has provided both financial and technical assistance. As a result, the Ministry of Education and the World Bank have decided to work together through a project called the Secondary Education Improvement Project (SEIP). In order to improve the quality of education in Cambodia, the project is working on three main objectives: **first,** to increase school buildings and infrastructure in secondary schools by helping to build more school buildings and other infrastructure in schools. **Second**, piloting a school Best management (SBM) that reflects decentralization and co-decentralization and accountability at the sub-national level. **Third**, to improve the teaching and learning of teachers and students by assisting teachers directly in schools and through teacher qualification programs. Therefore, the project, as well as the Ministry of Education, Youth and Sports, focuses on the first assessment through the reform of the monthly standardized exam, because the monthly exam is an assessment of the class level to develop teaching and learning. Teachers and students effectively.

Therefore, in this research, the researchers aim to find out:

1. Compare student learning outcomes after implementing the Secondary School Improvement Project (SEIP).

2. Outcomes of school management after the implementation of the Secondary Education Improvement Project (SEIP) at Bavel High School.

This research study is based on the academic results of students in the first semester of 2018-2019 and 2019-2020 and some relevant documents, especially the Ministry of Education, Youth and Sports and previous researchers. The data collected from Bavel High School were 58 participates, 37 females, including 2 management team, 22 teachers, 15 females, and students 34, 22 females from the students grade (7th, 8th, 9th and 10$^{th}$) . The researchers conducted both quantitative and qualitative studies, focusing on two research questions: **(1)** what is the difference between the results of students in the old school year (2018-2019) and the results? Students' study in the new school year (2019-202) after the implementation of the Secondary

Education Quality Improvement Program (SEIP)? **(2)** How did the SEIP affect school management, student learning, and teachers?

The results of the research show that the effectiveness of the implementation of the project to improve the quality of education in secondary education, which has helped the teaching and learning at Bavel High School as follows:

1. By comparing the average scores of students for the first semester, 7th grade (2018- (2019 with the 8th grade students ((2019-2020, the researchers observed that the average scores in each subject increased significantly. Note that this also shows the attention paid to the efforts of students to learn well, students have a high degree of self-study, especially shows the management of the school management with good governance, accountability, transparency There is good cooperation with teachers in teaching students with a sense of responsibility for their respective roles and responsibilities well. In particular, there were two subjects with a mean decrease in scores: history and chemistry. How to do each standard monthly subject and may come from many absent students during the monthly test.
2. The total average comparison for the first semester of 7th graders (2018-2019)is 16.62and the average for the first semester of 8th graders ( (2019-2020is .26.65Researchers believe that the increase in the overall average indicates that the implementation of the Secondary Education Improvement Project (SEIP), which has facilitated the teaching and learning at Bavel High School, is very effective.
3. By comparing the average scores of students for the first semester of Grade (2018-2019) 7 with the students of Grade (2019-2020) 7, the researchers observed that both students at this grade level are beginning to enter secondary school and Must pass the entrance test, and for the average score in each subject, there is also a significant increase, this also shows the attention to the students' efforts to learn well from one Year after year, students have a high degree of self-study, especially showing the management of the school management with good governance, accountability, transparency, especially good cooperation with teachers in teaching students with a sense of responsibility. Be on a good role for each of them. In particular, there were two subjects with a mean decrease in scores: history and chemistry. How to do each standard monthly subject and can come from many absent students during monthly tests.
4. The total average comparison for the first semester of 7th graders ( (2018-2019is 16.62and the average for the first semester of 7th graders ( (2019-2020is .22.70Researchers believe that the increase in the overall average indicates that the implementation of the Secondary

Education Improvement Project (SEIP), which has facilitated the teaching and learning at Bavel High School, is very effective.

5. Comparison of the total standard deviation in the first semester for 7th grade students ( (2018-2019is 9.35, while the 8th grade students ( (2019-2020have a total standard deviation of .12.08We see that the increase in the total standard deviation shows that the efficiency of the monthly or semester exams is tighter and clearer, resulting in a larger standard deviation, which means that students have truly demonstrated their ability not to copy. Each can or ask each other. This confirms the effectiveness of the implementation of the project to improve the quality of education in secondary school, which has helped to teach and learn at Bavel High School really effectively.
6. Comparison of the total standard deviation in the first semester between 7th grade students ( (2018-2019is 9.35and 7th grade students ( (2019-2020is .12.49Based on this data, we see that the total standard deviation in all subjects has increased, indicating that all teaching and learning is restricted, especially each monthly exam is transparent, meaning that students can not copy or ask each other Yes, and teachers are diligent in teaching, researching new methods, new knowledge to teach students better. These show us the effectiveness of the implementation of the project to improve the quality of education in secondary school, which helps to teach and learn more at Bavel High School.
7. After the school implemented the SEIP project, it was found that the school received better academic results, better management, and four teachers went to further education to improve their qualifications and change their behavior. Regular work, teaching and student attendance, good timing, teacher planning and directing students to experiment or do activities that support learning and teaching, teachers and school management. Receive additional training on specialized teaching and school management through the project. Every month, there are regular job meetings and regular technical meetings in each subject, especially students must pass the standard monthly exam once at the end of each month. Although the implementation of the SEIP project at Bavel High School is still limited, the school management and teachers and the school support committee continue to work hard to ensure that the students at Bavel High School have access to the work. New knowledge in line with 21st century education teaches students about clear life skills, how to live together in harmony, and good morals in society.

# បញ្ជីអក្សរកាត់

- NPSNDO: ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្រោមថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា
- ESP: ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- RGC: រាជរដ្ឋាភិបាលកម្ពុជា
- SEIP: គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា
- ICT: បច្ចេកវិទ្យាព័ត៌មាន
- STEM: វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា
- IBL: វិធីសាស្ត្របង្រៀនតាមបែបរិះរក
- HEIP: គម្រោងកែលម្អការអប់រំនៅឧត្តមសិក្សា
- HEIs: គណនេយ្យភាពផ្ទៃក្រៅ
- DOEs: ការិយាល័យអប់រំស្រុក
- TPAP: ការគាំទ្រផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន
- SIF: មូលនិធិកែលម្អសាលារៀន
- TA: ជំនួយបច្ចេកទេស
- ADB: ធនាគារអភិវឌ្ឍន៍អាស៊ី

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ........................................ i

**លិខិតបញ្ជាក់** ........................................ ii

**លិខិតថ្លែងអំណរគុណ** ........................................ iii

**មូលន័យសង្ខេប** ........................................ v

Abstract ........................................ x

**បញ្ជីអក្សរកាត់** ........................................ xiii

**ជំពូកទី១. សេចក្តីផ្តើម** ........................................ 1

**១.១ សារតារនៃការស្រាវជ្រាវ** ........................................ 2

**១.២ បញ្ហានៃការស្រាវជ្រាវ** ........................................ 4

**១.៣ គោលបំណង និងវត្ថុបំណងនៃការស្រាវជ្រាវ** ........................................ 6

**១.៤ សំណួរស្រាវជ្រាវ** ........................................ 7

**១.៥ សារៈសំខាន់នៃការស្រាវជ្រាវ** ........................................ 7

**១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** ........................................ 8

**១.៧ រចនាសម្ព័ន្ធស្រាវជ្រាវ** ........................................ 8

**ជំពូកទី២. រំលឹកទ្រឹស្តី** ........................................ 10

**២.១.ពន្យល់ពាក្យគន្លឹះ** ........................................ 11

**២.២ ការវិភាគការបំពេញការងារ ២០១៤-២០១៨** ........................................ 13

**២.៣ ការវិភាគចង្អុលភាពអនុវិស័យ** ........................................ 13

២.៣.១ អនុវិស័យ ការអប់រំកុមារតូច ........................................ 13

២.៣.២ អនុវិស័យ ការអប់រំបឋមសិក្សា ........................................ 14

២.៣.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា ........................................ 15

២.៣.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា ........................................ 15

២.៣.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ ........................................ 16

២.៣.៦ អនុវិស័យ ការអភិវឌ្ឍយុវជន ........................................ 16

២.៣.៧ អនុវិស័យ ការអប់រំកាយ និងកីឡា ...... 16

**២.៤ យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល** ...... 17

**២.៥ ចក្ខុវិស័យ បេសកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា** ...... 17

**២.៦ យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា** ...... 19

២.៦.១ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូ និងកំណែទម្រង់កម្រិតសាលារៀន ...... 19

២.៦.២ អាទិភាពកំណែទម្រង់គោលនយោបាយវិស័យអប់រំក្នុក្របខណ្ឌ សសរស្តម្ភទាំង៥ ...... 19

២.៦.៣ យុទ្ធសាស្រ្តកំណែទម្រង់ឧត្តមសិក្សា ...... 21

២.៦.៤ យុទ្ធសាស្រ្តកំណែទម្រង់ការគ្រប់គ្រងអប់រំ ...... 22

២.៦.៥ កំណែទម្រង់ការអប់រំគ្រូនៅតាមសាលាគរុកោសល្យ ...... 22

២.៦.៦ កំណែទម្រង់សាលារៀន ...... 23

២.៦.៧ ការពិនិត្យតាមដាន និងវាយតម្លៃ ...... 23

**២.៧ គោលនយោបាយស្តីពី គ្រូបង្រៀន** ...... 23

**២.៨ បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា** ...... 24

២.៧.១ ក្របខណ្ឌធានាគុណភាព ...... 25

២.៧.២ អធិការកិច្ចផ្ទៃក្នុង ...... 26

២.៧.៣ អធិការកិច្ចផ្ទៃក្រៅ ...... 26

**២.៨ ផែនការយុទ្ធសាស្រ្តការអប់រំ** ( ESP ) **ឆ្នាំ ២០១៤-២០១៨** ...... 26

**២.៩ គោលនយោបាយជាតិស្តីពី វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០ -២០៣០** ...... 27

**២.១០ គម្រោងកែលម្អគុណភាពអប់រំនៅឧត្តមសិក្សា** ( HEIP ) ...... 28

**២.១១ គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិ**( SEIP ) ...... 29

២.១១.១ ពិពណ៌នាអំពីគម្រោង ...... 29

២.១១.២ សមាសធាតុគម្រោង ...... 29

២.១១.៣ ការជ្រើសរើសសាលា ...... 32

**២.១២ គម្រោងលើកកម្ពស់គុណភាពអប់រំ**( EEQP ) ....................................................33
**២.១៣ សាលាមធ្យមសិក្សាធនធាន** ....................................................33
**២.១៤ ទ្រឹស្តីពាក់ព័ន្ធ** ....................................................34
២.១៤.១ គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សានៅប្រទេសនេប៉ាល់( SEIP at Nepal ) .34
២.១៤.២ គម្រោងកែលម្អគុណភាពអប់រំនៅមត្តេយ្យសិក្សានៅVANUATU In The PACIFIC ( PEIP ) ....................................................36
**ជំពូកទី៣. វិធីសាស្ត្រស្រាវជ្រាវ** ....................................................39
**៣. ១. គម្រោងវិភាគ** ....................................................40
**៣. ២. ការប្រមូលទិន្នន័យ** ....................................................41
**៣.៣. ឧបករណ៍ស្រាវជ្រាវ** ....................................................42
**៣.៤. ការជ្រើសរើសភាគសំណាក** ....................................................44
**៣.៥. ការវិភាគទិន្នន័យ** ....................................................45
**៣.៦. ក្រមសីលធម៌នៃអ្នកស្រាវជ្រាវ** ....................................................46
**ជំពូកទី៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ....................................................47
**៤.១ លទ្ធផលនៃការស្រាវជ្រាវសំណួរទី១៖ តើមានភាពខុសគ្នាដូចម្តេច រវាងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាចាស់(២០១៨-២០១៩) និងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាថ្មី(២០១៩-២០២០) ក្រោយពេលអនុវត្តកម្មវិធីកំណែលម្អគុណភាពអប់រំនៅមធ្យមសិក្សា** ( SEIP )។ ....................................................48
**៤.២ លទ្ធផលនៃការស្រាវជ្រាវសំណួរទី២៖ តើគម្រោង**( SEIP ) **បានជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះ នៅលើការគ្រប់គ្រងសាលារៀន ការរៀនរបស់សិស្ស និងគ្រូបង្រៀន**? ....................................................64
៤.២.១ ការសម្ភាសន៍របស់នាយក និងនាយករង ....................................................64
៤.២.១ ការយល់ឃើញរបស់សិស្ស( កម្រងសំណួរ ) ....................................................66
៤.២.២ ការយល់ឃើញរបស់គ្រូបង្រៀន( កម្រងសំណួរ ) ....................................................73
**ជំពូកទី៥. ការសេចក្តីសន្និដ្ឋាន និងសំណូមពរ** ....................................................83
**៥.១ សេចក្តីសន្និដ្ឋាន** ....................................................84

៥.២ បញ្ហាប្រឈមក្នុងការដំណើរការគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា...90

៥.៣ សំណូមពរ.......................................................................................................90

ឯកសារយោង.......................................................................................................93

ឧបសម្ព័ន្ធ.......................................................................................................94

# ជំពូកទី១. សេចក្តីផ្តើម

# ជំពូកទី១

# សេចក្ដីផ្ដើម

## ១.១ សាវតារនៃការស្រាវជ្រាវ

ការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត ប្រទេសនីមួយៗជានិច្ចកាលត្រូវការធនធានមនុស្សដែលមានចំណេះដឹង និងជំនាញប្រកបដោយសមត្ថភាពខ្ពស់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក៏ ដូចជាកសាងសង្គមជាតិឲ្យបានរឹងមាំផងដែរ។ ការអប់រំតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការធានាការសិក្សាមានគុណភាពប្រកបដោយ សមធម៌ បរិយាបន្ន និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការសិក្សាពេញមួយជីវិត ជាការអប់រំសំដៅជានាសិទ្ធិសេរីភាព និងសុកម្ផលបុគ្គល គ្រួសារ និងសង្គមជាតិ ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ការអប់រំដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាឲ្យក្លាយជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នា ប្រកបដោយសុខដុមនៅក្នុងសង្គម។ បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងបោះជំហានទៅរកដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍ គឺប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ *(គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល ស្តីពី ការសិក្សាពេញមួយជីវិត)*

ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ថាសមត្ថភាពធនធានមនុស្សខាងផ្នែកបំណិនសតវត្សរ៍ទី២១ ជាពិសេសកាប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(បពស) គឺជាកត្តាជំរុញឧត្តមភាពប្រកួតប្រជែងរបស់ប្រទេស។ សមត្ថភាពទាំងនេះជួយឲ្យប្រជាជនបង្កើតចំណេះដឹងថ្មី និងប្រែក្លាយចំណេះដឹងទាំងនោះទៅជាការអនុវត្តថ្មីៗ ដើម្បីគាំទ្រដល់ការធ្វើអន្តរកម្មសេដ្ឋកិច្ច របស់ប្រទេស ពីការធ្វើពាណិជ្ជកម្មជាលក្ខណៈដោះដូរទំនិញ ទៅជាការធ្វើពាណិជ្ជកម្មផលិតផល និងសេវាកម្មដែលប្រើប្រាស់ចំណេះដឹងកម្រិតខ្ពស់។ ដើម្បីពន្លឿនការធ្វើអន្តរកម្មទៅរកសេដ្ឋកិច្ចផ្អែកលើចំណេះដឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឲ្យអនុវត្តនូវគោលនយោបាយជាច្រើនដើម្បីបង្កើតនូវបរិយាកាសអំណោយផលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ។ ស្របពេលជាមួយគ្នា

នេះ វិស័យ បពស នៅកម្ពុជាបានសម្រេចវឌ្ឍនៈភាពគួឲ្យកត់សម្គាល់ក្នុងការពង្រីកសេវាកម្មនៅទូទាំងប្រទេស។ ការអភិវឌ្ឍទាំងនេះផ្តល់នូវកាលានុវត្តភាពសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ធ្វើកំណែទម្រង់ និងទំនើបកម្មវិស័យអប់រំ ដោយរាប់បញ្ចូលទាំងសមត្ថភាពផ្នែក បពស ដល់ប្រជាជនកម្ពុជាគ្រប់រូប។ *(គោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ)*។

ស្របជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ របស់រាជរដ្ឋាភិបាលដើម្បីប្រគល់មុខងារ និងធនធានពីក្រសួងទៅឲ្យអាជ្ញាធរមូលដ្ឋាន ដើម្បីធានាដល់ការគ្រប់គ្រងថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព។ កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NPSNDO) របស់រាជរដ្ឋាភិបាលកម្ពុជា គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់នេះក្នុងរយៈពេល១០ឆ្នាំ។ គោលដៅរួមរបស់កម្មវិធីនេះ គឺដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ សំដៅសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយនិរន្តភាពពន្លឿនកំណើនសេដ្ឋកិច្ច និងផ្តល់ឱកាសប្រកបដោយសមធម៌ដល់ប្រជាជនគ្រប់រូប។ យុទ្ធសាស្ត្រស្នូលរបស់កម្មវិធីនេះ គឺក្រសួងវិស័យត្រូវធ្វើវិមជ្ឈការ ការធ្វើសេចក្តីសម្រេចចិត្តតាមរយៈការផ្ទេរមុខងារ និងធនធានទៅឲ្យថ្នាក់មូលដ្ឋាន។ គោលនយោបាយនេះមានគោលបំណងពង្រឹងការចូលរួម ការទទួលខុសត្រូវជានាតម្លាភាព និងប្រសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ ក្នុងងការពង្រឹងយន្តការស្វ័យភាពគ្រឹះស្ថានសិក្សាសាធារណៈ និងរៀបចំការផ្ទេរមុខងារ និងធនធានវិស័យអប់រំ យុវជន និងកីឡា ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតសេវាអប់រំជូនប្រជាពលរដ្ឋ ស្របតាមចក្ខុវិស័យរបស់រាជដ្ឋាភិបាលក្នុងការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

*(គោលនយោបាយ ស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ)*។

តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួង និងដៃគូអភិវឌ្ឍបានរួមគ្នាសម្រេចកិច្ចការធំៗគួឲ្យកត់សម្គាល់ដូចជា ការបន្តបង្កើនការចូលរៀនប្រកបដោយសមធម៌

នៅគ្រប់កម្រិត ជាពិសេសការអប់រំថ្នាក់មូលដ្ឋានរយៈពេល៩ឆ្នាំ កាបង្កលក្ខណៈសម្បត្តិអនុគ្រោះនានាដើម្បីសិស្សជួបការលំបាកមានលទ្ធភាពចូលសិក្សានៅគ្រប់កម្រិត ការពង្រឹង និងពង្រីកអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការដោះស្រាយតម្រូវការបន្ទាន់ភ្លាមៗ និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតក្រីក្រ។ ការសម្រេចបានសក្តានុពលការអប់រំដើម្បីឈានទៅជំរុញការរីកលូតលាស់ គឺជាអាទិភាពមួយសម្រាប់ប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់កម្ពុជា និងយុទ្ធសាស្ត្រចតុកោណ អំពាវនាវឲ្យបង្កើតសេដ្ឋកិច្ចដែលមានលក្ខណៈប្រកួតប្រជែងមួយ តាមរយៈចំណេះដឹង និងការបង្កើតថ្មី។ ដើម្បីបង្កើតមូលដ្ឋានរឹងមាំ ផែនការយុទ្ធសាស្ត្រការអប់រំ (ESP) ក៏បានផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រីកការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលមធ្យមសិក្សាតាមរយៈការបន្ត និងការពង្រីកភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងមាតាបិតាសិស្ស។ *(សេចក្តីព្រាងចុងក្រោយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣)*

## ១.២ បញ្ហានៃការស្រាវជ្រាវ

ថ្វីបើមានការរីកលូតលាស់យ៉ាងខ្លាំងក្លាអស់រយៈពេលមួយទសវត្សរ៍មកក្តី ប្រទេសកម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសមិនសូវអភិវឌ្ឍក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រជាជនប្រមាណ ២០ភាគរយ រកចំណូលបានតិចជាង១ដុល្លា ក្នុងមួយថ្ងៃ ហើយពលរដ្ឋកម្ពុជាប្រមាណ២៤ភាគរយរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ មួយភាគបួននៃគ្រួសារទាំងអស់ គឺមានស្ត្រីជាមេគ្រួសារ ហើយ៥៩ភាគរយនៃប្រជាជនសរុប គឺរស់ពឹងផ្អែកលើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត។ រាជរដ្ឋាភិបាលកម្ពុជា (RGC) និងសហគមន៍អ្នកផ្តល់ជំនួយកំពុងធ្វើការ រួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមជាច្រើនក្នុងចំណោមបញ្ហាទាំងអស់នេះ ហើយសម្រេចបានជោគជ័យមួយចំនួនក្នុងអំឡុងពេលប្រាំឆ្នាំកន្លមកនេះ។ ក្នុងអំឡុងពេលនេះ ភាពក្រីក្របានកាត់បន្ថយជាង៦០ភាគរយ ក្នុងទីក្រុងភ្នំពេញ និងង៤៤ភាគរយនៅក្នុងតំបន់ទីប្រជុំជនដទៃទៀត។ ទោះបីជាយ៉ាងណាក្តី ការកាត់បន្ថយភាពក្រីក្រមានទំហំតូចគួរជាទីកត់សម្គាល់ក្នុងតំបន់ជនបទនៅឡើយ ពោលគឺប្រមាណតែ ២២ ភាគរយប៉ុណ្ណោះ។

*(ធនាគារពិភពលោកឆ្នាំ ២០១៣)*

ការសម្រេចបានសក្ដានុពលការអប់រំដើម្បីឈានទៅជំរុញការរីកលូតលាស់ គឺជាអាទិភាពមួយសម្រាប់ ប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់កម្ពុជា និយុទ្ធសាស្ត្រចតុកោណ អំពាវនាវឲ្យបង្កើត សេដ្ឋកិច្ចដែលមានលក្ខណៈប្រកួតប្រជែងមួយ តាមរយៈចំណេះដឹង និងការបង្កើតថ្មី។ ដើម្បីបង្កើតមូលដ្ឋានដ៏រឹងមាំ ផែនការយុទ្ធសាស្ត្រការអប់រំ (ESP) ផ្ដោតការយកចិត្តទុកដាក់លើបញ្ហាគន្លឹះចំនួនពីរគឺ៖ ការសម្រេចបាននូវលទ្ធផលទទួលបានការអប់រំកម្រិតមូលដ្ឋានមានគុណភាពខ្ពស់ជាសកល និងការលើកកម្ពស់ឱកាសអប់រំស្មើគ្នា ដើម្បីបង្កើនចំណូល និងមុខរបរ។

ខណៈពេលដែលក្រសួងអប់រំ យុវជន និងកីឡាកំពុងរៀបចំកំណែទម្រង់វិស័យអប់រំថ្មី នៅបឋមសិក្សា និងមធ្យមសិក្សា និងដើម្បីកំណែទម្រង់ការរៀន និងបង្រៀនតាមបែបសតវត្សន៍ទី២១ ក៏នៅមានបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនោះរួមមានការខ្វះខាតផ្នែកសម្ភារៈឧបទេសនៅតាមសាលាភាគច្រើន ខ្វះអគារសិក្សា ការរីករាលដាលនៃសាលាឯកជនកាន់តែច្រើន ចំនួនពលរដ្ឋដែលជាយុវជនមានច្រើនសន្ធឹកសន្ធាប់ និងគំនិតប្រកួតប្រជែងនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន ជាពិសេសខ្វះការចូលរួមពីភាគីពាក់ព័ន្ធ។

ក្រសួងបានផ្ដល់អាទិភាពខ្ពស់ លើការកែលម្អគុណភាពអប់រំទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ។ អស់រយៈពេលជាច្រើនឆ្នាំ ក្រសួងទទួលបានជោគជ័យមួយចំនួនក្នុងផ្នែកនេះ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញបន្ថែម។ ព្រះរាជាណាចក្រកម្ពុជានៅមានធនធានតិចតួច ដូច្នេះការបែងចែកធនធានទាំងនេះឲ្យដល់គ្រប់សាលារៀនទូទាំងប្រទេសបានធ្វើឲ្យគោលដៅលើកកម្ពស់គុណ ភាពអប់រំនៅមានកម្រិត។ ជម្រើសគំរូអភិវឌ្ឍទីពីដែលនឹងអនុញ្ញាតឲ្យមានការវិនិយោគកម្រិតខ្ពស់ ដើម្បីទទួលបានស្តង់ដានៃការអប់រំអតិបរមាសម្រាប់សិស្សានុសិស្ស និងយុវជនកម្ពុជា ដែលត្រូវទាមទារឲ្យមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន។ ***( គោលនយោបាយ ស្ដីពី សាលារៀនជំនាន់ថ្មី)***

ដើម្បីធ្វើឲ្យសាលារៀនមួយមានការរីកចម្រើនលូតលាស់ និងមានស្តង់ដាខ្ពស់អាស្រ័យលើការគ្រប់គ្រងល្អ គ្រូបង្រៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ បរិស្ថានស្អាតជាទីទាក់ទាញ មានទំនាក់ទំនងល្អរវាងសាលារៀន និងមាតា បិតាសិស្ស ឬអាណាព្យាបាលសិស្ស សាលារៀនជាមួយសហគមន៍ ជាពិសេសទំនាក់ទំនងល្អរវាងគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ ចេះសហការគ្នាក្នុងការបំពេញភារកិច្ចការងារទើបធ្វើឲ្យសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ ដូច្នេះហើយទើបធ្វើឲ្យមានការស្រាវជ្រាវដាក់លាក់មួយស្តីពី ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលជួយដល់ការរៀន និងបង្រៀននៅវិទ្យាល័យបវេល ខេត្តបាត់ដំបង ដើម្បីឲ្យកាន់តែមានភាពស៊ីជម្រៅ និងប្រាកដនិយមបន្ថែមទៀត។

## ១.៣ គោលបំណង និងវត្ថុបំណងនៃការស្រាវជ្រាវ

### ក. គោលបំណង

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ចំនួនពីរគឺៈ

- ✓ សិក្សាលើលទ្ធផលសិក្សារបស់សិស្សក្រោយពេលអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP)
- ✓ សិក្សាលើលទ្ធផលនៃការគ្រប់គ្រងសាលារៀនក្រោយពេលការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (SEIP) ។

### ខ. វត្ថុបំណង

ដើម្បីសម្រេចគោលបំណងខាងលើ ទន្ទឹមនឹងនោះក៏មានវត្ថុបំណងសំខាន់ៗមួយចំនួនៈ

- ✓ ប្រៀបលទ្ធផលសិក្សារបស់សិស្សក្នុងឆ្នាំសិក្សាថ្មី(២០១៩-២០២០) និងឆ្នាំសិក្សាចាស់(២០១៨-២០១៩) ក្រោយពេលអនុវត្តគម្រោង(SEIP)។
- ✓ ការពេញចិត្ត និងការចូលរួមក្នុងការអនុវត្តគម្រោង(SEIP) របស់គណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ។

- ✓ ដើម្បីបង្ហាញពីអត្ថប្រយោជន៍នៃគម្រោងកែលម្អសាលារៀននៅមធ្យមសិក្សាទៅដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ។
- ✓ គម្រោង(SEIP) បានជួយបង្កើនគុណវុឌ្ឍិគ្រូបង្រៀនបានកម្រិតណា
- ✓ កត្តាជះឥទ្ធិពលនៃគម្រោង(SEIP) ទៅលើការគ្រប់គ្រងសាលារៀន ការរៀនរបស់សិស្ស និងគ្រូបង្រៀន

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីសម្រេចវត្ថុចំណងខាងលើនេះ មានសំណួរចំនួន២ដែលបានកំណត់ដូចខាងក្រោមៈ

១. តើមានភាពខុសគ្នាដូចម្តេច រវាងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាចាស់(ឆ្នាំដំបូង) និងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាថ្មី(ឆ្នាំបន្ទាប់) ក្រោយពេលអនុវត្តកម្មវិធីកំណែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP)?

២. តើគម្រោង(SEIP) បានជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះ ទៅលើការគ្រប់គ្រងសាលារៀន និងទៅលើការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ ព្រោះវាជួយឆ្លុះបញ្ចាំងឲ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយនៃកិច្ចដំណើរការរបស់សាលារៀនមួយក្នុងការអនុវត្តកម្មវិធីកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា បឋមភូមិ(SEIP) ព្រមទាំងជាបទពិសោធល្អៗ សម្រាប់កិច្ចដំណើរការនៅតាមសាលារៀនផ្សេងទៀត ដែលមានដាក់បញ្ចូលគម្រោង(SEIP) នេះផងដែរ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះ បានចូលរួមចំណែកក្នុងការកៀរគរការចូលរួម ពីគ្រប់មជ្ឈដ្ឋានក្នុងការជួយជ្រោមជ្រែងដល់កិច្ចដំណើរការក្នុងសាលារៀន ក៏ដូចជាការចូលរួមក្នុងការអនុវត្តកម្មវិធីនេះឲ្យកាន់តែមានប្រសិទ្ធភាព ការចូលរួមក្នុងការសាងសង់ និងការអភិវឌ្ឍសាលារៀនមួយឈានដល់កម្រិតស្តង់ដា ដើម្បីជាគ្រឹះក្នុងការជួយជំរុញដល់គុណភាពអប់រំរបស់សិស្សនាពេលអនាគត ។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់លើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) ជាពិសេសដំណើរការគ្រប់គ្រងសាលារៀន និងលទ្ធផលសិក្សារបស់សិស្សប្រចាំឆ្នាំ នៅវិទ្យាល័យបវេល ក្នុងឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ អាស្រ័យហេតុនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសសមាសភាព ដែលត្រូវផ្តល់ព័ត៌មានចំនួន ៥៨នាក់ ដែលក្នុងនោះមានគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ និងសិស្សានុសិស្សថ្នាក់ទី៧, ទី៨, ទី៩។

## ១.៧ រចនាសម្ព័ន្ធស្រាវជ្រាវ

និក្ខេបបទនេះចែកជា ៥ជំពូកៈ

**ជំពូកទី១ៈ សេចក្តីផ្តើម** ដែលមាន៧ផ្នែក រួមមានៈ សាវតា បញ្ហានៃការស្រាវជ្រាវ គោលបំណង និងវត្ថុបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ៈ រំលឹកទ្រឹស្តី** ជាការលើកយកមកបង្ហាញអំពីកិច្ចដំណើរគម្រោង (SEIP) ផលប្រយោជន៍ និងសារៈសំខាន់នៃគម្រោង(SEIP) សមាសធាតុគ្រោង ព្រមទាំងទ្រឹស្តីដែលពាក់ព័ន្ធនៅក្នុងប្រទេស ថ្នាក់តំបន់ និងសកលលោកឲ្យបានទូលំទូលាយ និងច្បាស់លាស់។

**ជំពូកទី៣ៈ វិធីសាស្ត្រស្រាវជ្រាវ** រៀបរាប់ពីវិធីសាស្ត្រនានាដែលយកមកប្រើដើម្បីទទួលបានទិន្នន័យយកមកវិភាគព្រមទាំងវិធីវិភាគទិន្នន័យដែលត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ។

**ជំពូកទី៤ៈ លទ្ធផល និងការពិភាក្សា** បកស្រាយលើទិន្នន័យដែលបានមកពីកម្រងសំណួរព្រមទាំងទិន្នន័យដែលប្រមូលបាន។

**ជំពូកទី៥ៈ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ក្រោយពីបានប្រៀបធៀបលទ្ធផលសិក្សារបស់សិស្សរួចមក អ្នកស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋានទៅលើលទ្ធផល ព្រមទាំងសណ្ណូមពរដល់អ្នកពាក់ព័ន្ធដើម្បីចូលរួម ផ្តល់មតិយោបល់ កែលម្អ និងស្ថាបនាបន្ថែម និងកៀរគរភាគីពាក់ព័ន្ធនានាឲ្យជួយ

ដល់ការអភិវឌ្ឍសាលារៀន ដើម្បីពង្រឹង និងជំរុញដល់កម្មវិធីកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិនេះបន្តទៀត ពិសេសដើម្បីជួយដល់គ្រូ និងសិស្សឲ្យមានសមត្ថភាពខ្ពស់ស្របតាមស្តង់ដាការសិក្សាបែបសតវត្សទី២១។

# ជំពូកទី២. រំលឹកទ្រឹស្ដី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១.ពន្យល់ពាក្យគន្លឹះ

**ប្រសិទ្ធភាព** មានន័យថាភាពដែលល្អ ផ្តល់ផលល្អ ផ្តល់ប្រយោជន៍សមតាមបំណង ឬម្យ៉ាងទៀត ជាកម្រិត ឬសមត្ថភាពដែលសម្រេចបានជាលទ្ធផលតាមការគ្រោងទុក ឬតាមបំណងនៃការអភិវឌ្ឍ របស់កម្មវិធី។

**ការអប់រំ** គឺសំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឲ្យអ្នកសិក្សាទទួលបានចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីធ្វើឲ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។ **ការលើកកម្ពស់គុណភាពអប់រំ** គឺដើម្បីបំពេញសេចក្តីត្រូវការខាងការសិក្សាមូលដ្ឋាន និងសេចក្តីត្រូវការជំនាញ សម្រាប់ធ្វើឲ្យអ្នកសិក្សាមានសមត្ថភាព និងមានលទ្ធភាពចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព។

**មធ្យមសិក្សាបឋមភូមិ** ជាកម្រិសិក្សាបន្តពីបឋមសិក្សាដែលមានកម្រិតថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦។ ចំណែកឯ**មធ្យមសិក្សាបឋមភូមិ**នេះ គឺជាកម្រិតសិក្សាដែលរាប់ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩។ ការសិក្សាកម្រិតនេះ គឺជាការរៀបចំសិស្សឲ្យត្រៀមខ្លួនរួចរាល់ ដើម្បីបន្តកាសិក្សាចូលដល់ថ្នាក់ មធ្យមសិក្សាទុតិយភូមិដែលចាប់ ផ្តើមពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ការអប់រំមធ្យមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការ អភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅថ្នាក់បន្ទាប់ ឬបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គម។ (ច្បាប់ស្តីពីការអប់រំ, ១៩ តុលា ២០០៧)

**ការរៀនៈ** គឺជាទង្វើនៃការទទួលបានអ្វីមួយថ្មី ឬការកែប្រែ និងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិន គុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធ និងការសំយោគព័ត៌មានប្រទេសផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥)។ ការសិក្សា គឺជាសកម្មភាពរបស់សិស្សម្នាក់ៗដែលចង់បានចំណេះដឹងសម្រាប់យកទៅប្រើប្រាស់ក្នុង ជីវភាពរស់នៅរបស់ខ្លួន និងធ្វើយ៉ាងណាឲ្យកាន់តែមានភាពប្រសើរឡើង ពោលគឺធ្វើឲ្យមានការផ្លាស់ប្តូរជីវិតរស់នៅទាំងឥរិយាបថ និងស្មារតី។ ការសិក្សា គឺជាដំណើរការនៃការទទួលបានការផ្លាស់ប្តូរទាំងស្រុងដែលឆ្ពោះទៅរកពលរដ្ឋពេញលេញ។ ការរៀនអាចកើតឡើងបានអាស្រ័យលើគម្រោង ឬកាលវិភាគនៃការសិក្សាដែលជាគ្រឿងជំរុញឲ្យត្រូវតែមករៀន។

**ការបង្រៀនៈ** ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្តឲ្យចេះរៀនដោយខ្លួនឯង ពង្រឹង និងពង្រីកចំណេះដឹង បទពិសោធន៍ដល់សិស្សគ្រប់រូប។ សកម្មភាពនៃការបង្រៀនរួមមាន ការពន្យល់ ការដាក់ចំណោទ ការសួររកហេតុ និងផល ការសួរសំណួរ ការលើកទឹកចិត្ត ការតាមដានសាវតាររបស់សិស្ស ការប្រឡង ឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីមានចិត្តគរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដទៃទៀតផង ចាំបាច់ត្រូវតែបន្តការស្រាវជ្រាវរកអ្វីដែលថ្មី អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងការបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥) ។ Modern Concept បានលើកឡើងថា ការបង្រៀនគឺជាបុព្វហេតុដែលជំរុញឲ្យសិស្សខិតខំរៀនសូត្រ និងទទួលបានចំណេះដឹង បទពិសោធន៍ និងមធ្យោបាយសម្រាប់ការរស់នៅរបស់ខ្លួន ជាមួយសង្គមឲ្យបានសមស្របទៅតាមបំណងប្រាថ្នាដែលពួកគេចង់បានផងដែរ។ ទិដ្ឋភាពដ៏សំខាន់បំផុតនៃដំណើរការបង្រៀនគឺសិស្ស និងអ្វីដែលពួកគេត្រូវរៀន (Dr.A.H.Sequeira,2002)។ ការរៀន គឺជាកិច្ចការរបស់គ្រូក្នុងការប្រើប្រាស់ចំណេះដឹងរបស់ខ្លួនសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់សិស្សឲ្យមានភាពល្អប្រសើរ (Thomas Green)។ ការបង្រៀន គឺជាសកម្មភាពនៃការចែករំលែកការអប់រំដល់អ្នកសិក្សាក្នុងថ្នាក់

រៀនមួយ (Traditional Teaching) ។ ការបង្រៀន គឺជាការយកចិត្តដាក់ទៅលើសកម្មភាពរបស់សិស្សរួមមាន សកម្មភាពលេង និការបង្កើតថ្មី ឬរបកគំហើញ (Paul H.Hirst,2004)។

## ២.២ ការវិភាគការបំពេញការងារ ២០១៤-២០១៨

ដើម្បីឲ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ជាពិសេសឆ្លើយតបនឹងអាទិភាពគោលនយោបាយអប់រំនានា ក្នុងការរួមចំណែកអនុវត្តគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើឲ្យមានកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពសំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិត ជីវភាពរបស់ប្រជាពលរដ្ឋ។ គោលនយោបាយរយៈពេលមធ្យមពីរគឺ៖

- **គោលនយោបាយទី១៖** ធានាឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។
- **គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រប់របស់មន្ត្រីអប់រំគ្រប់លំ ដាប់ថ្នាក់។

## ២.៣ ការវិភាគវឌ្ឍនភាពអនុវិស័យ

### ២.៣.១ អនុវិស័យ ការអប់រំកុមារតូច

លទ្ធភាពទទួលបានសេវាអប់រំរបស់កុមារតូច មានភាពប្រសើឡើងពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈយុទ្ធសាស្ត្រអន្តរាគមន៍នានា ការផ្តល់សេវាអប់រំ និងតម្រូការអប់រំ។ សាលាមត្តេយ្យសិក្សារដ្ឋដែលបានអនុវត្តកម្មវិធី បរិយាបន្នមានការកើនឡើងពី ២៧កន្លែង ឆ្នាំ២០១៣-២០១៤ ដល់ ១៨៣កន្លែង ឆ្នាំ ២០១៧-២០១៨ និងសាលាមត្តេយ្យសហគមន៍ដែលបានអនុវត្តកម្មវិធីរិយាបន្នមានការកើនឡើងពី ១០កន្លែង ឆ្នាំ២០១៣-២០១៤ ដល់ ៦៤កន្លែង ឆ្នាំ២០១៧-២០១៨។

កម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មតត្តេយ្យសិក្សាសហគមន៍: ក្រសួងបានសហការជាមួយជាមួយដៃគូអភិវឌ្ឍ ពង្រីកវិសាលភាពអនុវត្តកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់នឹងមត្តេយ្យសិក្សាសហគមន៍ ៣៨៤ភូមិ

មានមាតាបិតាបង្គោល៣៤៤នាក់ ស្រី៣១២នាក់ ដោយសហការជាមួយមេភូមិ និងគ្រូមត្តេយ្យសិក្សាសហគមន៍។

២.៣.២ អនុវិស័យ ការអប់រំបឋមសិក្សា

អត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់បានថយចុះជាបន្តបន្ទាប់ពី ១៥.៣ភាគរយ មក ១០.៦ ភាគរយ ក្នុងរយៈពេល៥ឆ្នាំចុក្រោយនេះ។ ការត្រួតថ្នាក់ ត្រូវបានកែលម្អបន្ថែមទៀត ពីព្រោះបានថយចុះឃើត ដោយថយចុះពី៦.៧ ភាគរយ ឆ្នាំសិក្សា២០១៥-២០១៦ មក ៦.៥ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨(ចំណុចដៅ ៤.២ ភាគរយ)។ ទោះយ៉ាងណា ការបោះបង់ការសិក្សាមានកាន់ច្រើនឡើងនៅថ្នាក់ទី៦ (ដោយសារអាហារូបករណ៍នៅមានកម្រិត ៨០០០០នាក់ កុមារលើសអាយុ ខ្វះសាលារៀនគ្រប់កម្រិតនៅស្រុកមួយចំនួន ភាពលំបាក ក្នុងការអាន និងសរសេរសម្រាប់មុខវិជ្ជាទាំងអស់នៅថ្នាក់បន្ទប់) ប៉ុន្តែអត្រាឆ្លងភូមិសិក្សារបស់សិស្សស្រី ខ្ពស់ជាងសិស្សប្រុស និងកាន់តែជិតចំណុចដៅ។

ដើម្បីឆ្លើយតបនឹងវត្ថុបំណងគោនយោបាយទី២ ក្រសួងបានផ្សព្វផ្សាយ និងការអនុវត្តការគ្រប់គ្រងតាម សាលារៀនដែលមាន៤ផ្នែកៈ ១) ការគ្រប់គ្រងរដ្ឋបាលសាលា ២) ការងាររៀន-បង្រៀន និងការអនុវត្តកម្មវិធីសិក្សា ៣) ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងការងារអធិការកិច្ច ៤) ការរៀបចំផែនការអភិវឌ្ឍសាលារៀន និង ការគ្រប់គ្រងថវិកាសាលារៀន។

ដើម្បីធានាបាននូវការអប់រំបរិយាបន្ន ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័ត និងអនុវត្តផែនការ សកម្មភាព ពហុភាសា និងបានផ្ទេរសាលាពហុភាសាសហគមន៍ ៨០ ឲ្យទៅជាគ្រឹះស្ថានសិក្សារដ្ឋ និងមានផែន ការបង្កើនការបង្រៀន ភាសាជនជាតិដើមភាគតិចពី៥ ទៅ៦។ ទន្ទឹមនឹងនេះ ក្រសួង បានដាក់ចេញនូវវិធានការ បង្កើនចំនួនថ្នាក់ពន្លឿន និងការចូលរៀនឡើងវិញ ដើម្បីធានាបាននូវការអប់រំប្រកបដោយសមធម៌។ ការអប់រំពហុភាសាបានកំពុងនិងពង្រីក ក៏ដូចជាថ្នាក់ពន្លឿនការអប់រំផងដែរ។ សាលារៀនបឋមសិក្សាចំនួន៣ បានអនុវត្ត សាកល្បងការរៀនពេញមួយថ្ងៃ ដោយផ្តល់

អាហាថ្ងៃត្រង់ តាមរយៈការប្រើប្រាស់ស្បៀងអាហារកសិផលសហគមន៍។ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីរៀបចំឲ្យមានសង្គតិភាព នូវវិធីសាស្ត្រ អំណាន និងគណិតវិទ្យាដំបូង និងការរៀបចំកញ្ចប់សម្ភារអំណាន និងបានអនុវត្តសាកល្បងនៅខេត្តចំនួនគឺ កំពង់ធំ និងសៀមរាប។

២.៣.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិមានការថយចុះគួរឲ្យកត់សម្គាល់ពី ២១.២ ភាគរយ មក ១៥.៤ ភាគរយ ប៉ុន្តែអត្រានេះនៅខ្ពស់នៅឡើយ បណ្តាលមកពី សាលារៀនខ្លះនៅឆ្ងាយពីផ្ទះ កង្វះគ្រូ ដែលមានសមត្ថភាព សៀវភៅសិក្សាគោល វិធីបង្រៀន និងអាហារូបករណ៍ ដូចជាកម្មវិធីប្រឹក្សាអាជីព និងការដាក់ឲ្យអនុវត្តកម្មវិធីប្រព័ន្ធរំលឹកឡើងជាមុន (កំណត់សញ្ញាណសិស្សរៀនយឺត ការបង្រៀនបំប៉នបន្ថែម ការតាមដាន ការសិក្សារបស់សិស្ស និងការជួយសិស្សដែលរៀនយឺត សិស្សប្រឈមនឹងការបោះបង់ការសិក្សា។

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិនៅតែខ្ពស់ ដែលនៅឆ្នាំ២០១៧-២០១៨ មាន ១៨.៣ ភាគយ។ ចំនួនសិស្សវិទ្យាល័យចំណេះទូទៅនិងការអប់រំបច្ចេកទេសបានកើនឡើងជាបន្តបន្ទាប់ តាមរយៈកម្មវិធីផ្តល់អាហារូបករណ៍ អន្តេវាសិកដ្ឋានសម្រាប់សិស្ស និងការពង្រឹងការផ្សព្វផ្សាយឲ្យយល់ពីសារៈសំខាន់ និងតម្លៃនៃការអប់រំបច្ចេកទេស។

កម្មវិធីលម្អិតបានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សាទាំងថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់ វិទ្យាសាស្ត្រសង្គម។ ទី១ កំណែទម្រង់កម្មវិធីសិក្សា ទី២ កម្មវិធីសិក្សាលម្អិត ទី៣ ចំនួនម៉ោង ICT and STEM ទី៤ ក្រសួងអប់រំ យុវជន និងកីឡាកំពុងជ្រើសរើស និងបំប៉នគ្រូឧទ្ទេស IBL ថ្នាក់ជាតិ និងវិធីបង្រៀន(ប្រឡង)។

២.៣.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

ការចូលរៀននៅឧត្តមសិក្សាមានស្ថានភាពមិនសូវប្រែប្រួល ដោយអត្រារួមនៃការសិក្សា(១៨-២២ឆ្នាំ) ស្ថិតក្នុងរង្វង់១១ភាគរយ ធៀបនឹងចំណុចដៅ ១៦ ភាគយ។ ការចូរៀនបានប្រមូលផ្តុំលើ

មុខវិជ្ជាវិទ្យាសាស្ត្រ សង្គម ធុរកិច្ច ច្បាប់ និងមនុស្សសាស្ត្រ ដែលមាន៣ភាគរយនៃចំនួននិស្សិតចូលរៀននៅឧត្តមសិក្សា ហើយនិស្សិត ចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាមានតិចតួចនៅឡើយ។ (បង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ និងកំពង់ឈើទាល បណ្តុះបណ្តាលបណ្ឌិត ពង្រឹងយេនឌ័រនៅមានគម្លាតជំនាញ ផ្តល់ប្រឹក្សាអាជីព កង្វះសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិ និងប្រព័ន្ធធានាគុណភាពនៅឧត្តមសិក្សា)។

២.៣.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

ដំណាក់កាលថ្មីនៃការអភិវឌ្ឍអនុវិស័យអប់ក្រៅប្រព័ន្ធ គឺផ្តោតលើការសិក្សាពេញមួយជីវិតតាមរយៈការ អនុវត្តគោលនយោបាយជាតិស្តីពី ការសិក្សាពេញមួយជីវិតក្នុងគោលបំណងផ្តល់ឱកាស និងគាំទ្រឲ្យប្រជាជន គ្រប់រូបទទួលបានការសិក្សាតាមគ្រប់រូបភាព និងប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបាន ដើម្បីបង្កើន ប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូលស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងសង្គមពុទ្ធិ។

២.៣.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

ការអភិវឌ្ឍយុវជនកម្ពុជាក៏កាន់តែមានភាពសកម្ម តាមរយៈការទទួលបាននូវអន្តរាគមន៍ និងការគាំទ្រនានាពីគ្រប់អ្នកពាក់ព័ន្ធ ដូចជាដំណើរការរបស់ក្រុមប្រឹក្សាយុវជន យុវជនស្ម័គ្រចិត្ត យុវជនកាកបាទក្រហម និង យុវជនកាយរឹទ្ធិ ព្រមទាំងទទួលបានការផ្តល់ជំនាញបច្ចេកទេសនិងជំនាញទន់ ការផ្តល់ព័ត៌មាន ទីផ្សារការងារ ការប្រឹក្សាអាជីព និងការតម្រង់ទិសសិក្សា។

២.៣.៧ អនុវិស័យ ការអប់រំកាយ និងកីឡា

កំណែទម្រង់អប់រំកាយនិងកីឡា បានលើកកម្ពស់កិត្តិស័ព្ទនិងកិត្តិនាមរបស់កីឡាល្បីៗ ដែលបានទទួល មេដាយមាសពីការប្រកួតកីឡាស៊ីហ្គេមលើកទី១៧ នៅប្រទេសកូរ៉េ មេដាយមាសក្នុងការប្រកួតកីឡាប៉េតង់ជើងឯកពិភពលោក និងមេដាយក្នុងការប្រកួតកីឡាផ្សេងទៀតជាច្រើនផងដែរ។ ប្រការនេះ អនុវិស័យអប់រំកាយ និង កីឡាត្រូវបានយកចិត្តទុកដាក់លើការធ្វើកំណែទម្រង់ការប្រកួត

កីឡា ដូចជា ការរៀបចំយន្តការអនុវត្តផែនការគោលនៃការអភិវឌ្ឍកីឡាឆ្ពោះទៅការប្រកួតកីឡាស៊ីហ្គេម ឆ្នាំ២០២៣។

## ២.៤ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

គោលដៅជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល គឺអភិវឌ្ឍ **ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន** ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និងការយកចិត្ត ទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះរាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើះ ១) យកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនឲ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុង ជ្រោយ និង៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។ ជាពិសេសនោះគឺ យុវជនម្នាក់ ត្រូវមានជំនាញមួយយ៉ាងតិចប្រចាំជីវិត។

## ២.៥ ចក្ខុវិស័យ បេសកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមដែលមានការរីកចម្រើន លើផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡា មានបេសកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឲ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើនក្នុងតំបន់ និងសកលលោក។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជនយុវតីកម្ពុជាគ្រប់រូបឲ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ ព្រមទាំងមានសុទ្ធិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជន និងកុមារតូចកម្ពុជាគ្រប់រូប មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់ រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ភូមិសាស្ត្រ ពូជសាស៍ សាសនា ភាសា យេនឌ័រ និងងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយ សមស្រប ព្រមទាំងអាចប្រកួតប្រជែងលើទីផ្សារការងារក្នុងតំបន់ និងក្នុងសកលលោក និងអាចក្លាយជាកម្លាំង ស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ការធ្វើសមាហរណកម្មនៅក្នុងសហគមន៍អាស៊ានឆ្នាំ២០១៥ និងការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសដែលមានចំណូលមធ្យម ឆ្នាំ២០៣០ ទាមទារឲ្យមានការវិនិយោគបន្ថែមទៀតទៅលើវិស័យអប់រំ។ ធនធានមនុស្សដែលមានវិជ្ជាជីវៈត្រឹមត្រូវ និងមានគុណភាព ព្រមទាំងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក៏ត្រូវបានដាក់ក្នុងវិស័យអប់រំផងដែរ (ប្រទេសអាស៊ានដែលជោគជ័យ ក៏ទទួលបានបទពិសោធពីការបង្កើនការវិនិយោគទៅ ក្នុងវិស័យអប់រំ ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប)។

ក្រសួងទទួលស្គាល់ពីសារៈសំខាន់ក្នុងការជំរុញឲ្យវិស័យទាំងមូលអាចធ្វើជាមួយគ្នា ដើម្បីឆ្លើយតបនឹងតម្រូវការសង្គម និងសេដ្ឋកិច្ច។ ចំណុចផ្តោតរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ គឺប្រមូលផ្តុំសមិទ្ធផលដែលមានកន្លងមក ការឈានទៅដល់ក្រុមជួបការលំបាក ការផ្តល់ការអប់រំប្រកបដោយគុណភាព និងភាពពាក់ព័ន្ធដល់ការអភិវឌ្ឍប្រទេស។ ការផ្តល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ និងគណេយ្យភាពជាមូលដ្ឋាន សម្រាប់ការកសាងសង្គមមួយប្រកបដោយចំណេះដឹង និងជំនាញ។ វិស័យអប់រំនឹងរៀបចំនូវក្របខណ្ឌជានា គុណភាពទូទាំងវិស័យ ដោយផ្អែកលើការសិក្សារៀនសូត្រ និងការផ្តល់សេវាតាមស្តង់ដារឆ្លើយតបទៅនឹងតម្រូវ ការរបស់កុមារ សហគមន៍ និងទីផ្សាការងារ។

## ២.៦ យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា

២.៦.១ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូ និងកំណែទម្រង់កម្រិតសាលារៀន

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកំណែទម្រង់គ្រប់កម្រិត ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកំណែទម្រង់៣កម្រិត៖

១). ការអនុវត្តកំណែទម្រង់គោលនយោបាយអប់រំកម្រិតជាតិ ក្នុងក្របខណ្ឌ សសរស្តម្ភទាំង៥

២). ការអនុវត្តកំណែទម្រង់គ្រូបង្រៀននៅតាមសាលាគរុកោសល្យ

៣). ការអនុវត្តកំណែទម្រង់សាលារៀន

២.៦.២ អាទិភាពកំណែទម្រង់គោលនយោបាយវិស័យអប់រំក្នុក្របខណ្ឌ សសរស្តម្ភទាំង៥

ផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតអាទិភាពលើកំណែទម្រង់វិស័យអប់រំក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ ដូចខាងក្រោម៖

**សសរស្តម្ភទី១៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន**

- លើកទឹកចិត្តដល់គ្រូបង្រៀន និងនាយកសាលាដែលមានស្នាដៃល្អ ជាពិសេសគ្រូបង្រៀនភាសាខ្មែរថ្នាក់ទី១ និងគណិតវិទ្យាថ្នាក់ទី១
- អនុវត្តគោលនយោបាយស្តីពី គន្លងអាជីពគ្រូបង្រៀន
- អនុវត្តគោលនយោបាយស្តីពី ការអភិវឌ្ឍវិជ្ជាជីៈជាប្រចាំ សម្រាប់នាយកសាលា និងគ្រូបង្រៀន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងអភិវឌ្ឍសម្ភារៈគ្រូឧទ្ទេស
- ពិនិត្យសនិទានកម្មគ្រូបង្រៀន និងជំរុញការបែងចែកគ្រូបង្រៀនចេញថ្មីឲ្យកាន់តែមានប្រសិទ្ធភាព។

**សសរស្តម្ភទី២៖ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា**

- អភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា និងគ្រប់ភូមិសិក្សា
- ពង្រឹងវិធីសាស្ត្រអំណាននិងវិធីសាស្ត្របង្រៀនលេខនព្វន្តនៅបឋមសិក្សា និងពង្រឹងវិធីសាស្ត្របង្រៀននៅមធ្យមសិក្សា
- បណ្តុះទម្លាប់អាននៅក្នុងថ្នាក់រៀននិងក្នុងបណ្ណាល័យ ការប្រារព្ធទិវាអំណាន ការកែលម្អបណ្ណាល័យនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- ជំរុញការអនុវត្តគោលនយោបាយអប់រំវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា ឬការអប់រំតាមបែបឌីជីថល
- សាងសង់ជំនួស និងជួសជុលអគារសិក្សាដែលទ្រុឌទ្រោម រៀបចំទឹកស្អាត កន្លែងលាងដៃ និងបង្គន់ អនាម័យ និងសាងសង់បន្ទប់ពិសោធវិទ្យាសាស្ត្រ និងបន្ទប់កុំព្យូទ័រ។

**សសរស្តម្ភទី៣៖ ការដាក់ឲ្យអនុវត្តអធិការកិច្ច**

- បណ្តុះបណ្តាលអធិការអប់រំបន្ថែម និងធ្វើអធិការកិច្ចតាមកាលកំណត់ នៅតតាមគ្រឹះស្ថានសិក្សាទាំង ២៥ រាជធានី-ខេត្ត
- ធ្វើអធិការកិច្ចតាមប្រធានបទសំខាន់ៗ ទាក់ទងនឹងកំណែទម្រង់អប់រំ។

**សសរស្តម្ភទី៤៖ ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ**

- ពង្រឹងការប្រឡងគ្រប់ប្រភេទ ជាពិសេសការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- ធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្ស តេស្តវង្វាយតម្លៃថ្នាក់កម្រិតបឋមសិក្សា កម្មវិធីអន្តរជាតិស្តីពីតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សនៅកម្ពុជា។

**សសរស្តម្ភទី៥៖ ការកែទម្រង់ឧត្តមសិក្សា**

- បង្កើនធនធានសម្រាប់ដំណើរការបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា ឆ្លើយតបនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥

- បង្កើតមូលនិធិសម្រាប់កាស្រាវជ្រាវ
- វាយតម្លៃការទទួលស្គាល់គុណភាពអប់រំតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន និង ពិនិត្យ តាមដានលើការបណ្តុះបណ្តាលរបស់គ្រឹះស្ថាន។

២.៦.៣ យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា

- លើកកម្ពស់ការចូលរៀននៅឧត្តមសិក្សាប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត
  - ផ្តល់ថវិកាជាកញ្ចប់ដល់គ្រឹះស្ថានឧត្តមសិក្សាដែលមានកម្មវិធីបណ្តុះបណ្តាលអាទិភាពនៅឧត្តមសិក្សា ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
  - សាងសង់អន្តេវាសិកដ្ឋាន ដើម្បីលើកកម្ពស់ការចូលរៀន និងសមធម៌នៅឧត្តមសិក្សា
- កែលម្អសមត្ថភាពបង្រៀន និងរៀននៅឧត្តមសិក្សា
  - អភិវឌ្ឍកម្មវិធីសិក្សាឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងសង្គម
  - បង្កើនចំនួនសាស្ត្រាចារ្យមានគុណវុឌ្ឍិថ្នាក់បណ្ឌិត ២០ ភាគរយ និងបរិញ្ញាបត្រជាន់ខ្ពស់ ៦០ ភាគរយ
- កែលម្អសមត្ថភាពស្រាវជ្រាវនៅឧត្តមសិក្សា
  - បង្កើតមូលនិធិស្រាវជ្រាវនៅឧត្តមសិក្សា
  - បង្កើតគម្រង់ស្រាវជ្រាវដោយសហការជាមួយផ្នែកឧស្សាហកម្ម
- កែលម្អប្រព័ន្ធធានាគុណភាពអប់រំនៅឧត្តមសិក្សា
  - រៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង សម្រាប់គ្រឹះស្ថានឧត្តមសិក្សា
  - កែលម្អប្រព័ន្ធវាយតម្លៃ ផ្តល់ការទទួលស្គាល់គុណភាពអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សា
- កែលម្អបហារព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងនៅឧត្តមសិក្សា
  - ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
  - កែលម្អប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនៅឧត្តមសិក្សា

២.៦.៤ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ

នៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំផ្តោតសំខាន់លើសមាសធាតុ៤៖

១) កំណែទម្រង់ការគ្រប់គ្រងការសិក្សាៈ ផ្តោតលើការវាយតតម្លៃការសិក្សារបស់សិស្សជាប្រចាំ លើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។

២) កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលៈ ផ្តោតលើការធានាការចូលរួមរបស់អាណាព្យាបាលសិស្ស ឬសហគមន៍តាមមូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងការអនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

៣) កំណែទម្រង់កាគ្រប់គ្រងហិរញ្ញវត្ថុៈ ផ្តោតលើការបង្កើនស្វ័យភាពនិងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ការធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ និងបង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ។

៤) កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សៈ ផ្តោតលើការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំជាក់លាក់បុគ្គលិកជាន់ខ្ពស់ ការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀននិងកម្មវិធីបំប៉នផ្សេងៗ ការវាយតម្លៃការបំពេញការងារបុគ្គលិកទូទាំងប្រទេស ការលើកទឹកចិត្តគ្រូបង្រៀន។

២.៦.៥ កំណែទម្រង់ការអប់រំគ្រូនៅតាមសាលាគរុកោសល្យ

*ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងមជ្ឈមណ្ឌលអប់រំគ្រូបង្រៀន*

- ការពិនិត្យឡើងវិញលើកម្មវិធីបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងមជ្ឈ មណ្ឌលគរុគោសល្យភូមិភាគ និងការធានាសមមូលនៃការបណ្តុះបណ្តាល ជាពិសេសដោយផ្តោតលើ មុខវិជ្ជា STEM, ICT និងភាសាបរទេស
- ពង្រឹងសមត្ថភាពគ្រូឧទ្ទេសលើមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មានវិទ្យា
- ពិនិត្យឡើងវិញនូវដំណើរការសាលាគរុកោសល្យខេត្ត
- រៀបចំការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ សាលារៀន និងការបណ្តុះបណ្តាលនាយកសាលា

- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់សម្ភារៈឧបទ្ទេស ដើម្បីឲ្យការបណ្តុះបណ្តាលមានប្រសិទ្ធភាព។

២.៦.៦ កំណែទម្រង់សាលារៀន

ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការផ្តល់សេវាអប់រំនៅកម្រិតសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់សាលារៀន ដែលមានសមាសភាគដូចតទៅៈ

- ការបង្កើតសាលារៀនជំនាន់ថ្មី
- ការបង្កើតសាលារៀនគំរូចំនួន ១៥០ តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន
- ការលើកទឹកចិត្តឲ្យអនុវត្តការគ្រប់គ្រងតាមសាលារៀន នៅតាមគ្រឹះស្ថានសិក្សាដែលមានលក្ខខណ្ឌសមស្រប។

២.៦.៧ ការពិនិត្យតាមដាន និងវាយតម្លៃ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តទី៦ ដោយផ្ទេធនធានមនុស្ស និងផ្ទេរធនធានហិរញ្ញវត្ថុ ជាបណ្តើរៗទៅថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសាលារៀន ឲ្យស្របតាមក្របខណ្ឌច្បាប់ គ្រប់គ្រងរដ្ឋបាលផែនដី ក្របខណ្ឌយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ។

(សេចក្តីព្រាងចុងក្រោយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣, ឧសភា ២០១៩)

## ២.៧ គោលនយោបាយស្តីពី គ្រូបង្រៀន

គោលនយោបាយនេះមានចក្ខុវិស័យកសាងគ្រូបង្រៀនឲ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមាន សមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។

គោលនយោបាយស្តីពីគ្រូបង្រៀនមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឲ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។

គោលដៅនៃគោលនយោបាយស្តីពីគ្រូបង្រៀននេះមានដូចជា៖១) ទាក់ទាញនិងលើកទឹកចិត្តអ្នកដែលមានសម្ថភាពឲ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ២) ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន ៣) ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ ៤) ធានាលក្ខខណ្ឌចាំបាច់ ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ គោលនយោបាយនេះបានរៀបចំយុទ្ធសាស្ត្រសំខាន់ៗសម្រាប់យកទៅអនុវត្តសំដៅសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់។

គោលនយោបាយស្តីពីគ្រូបង្រៀនបានកំណត់ពីចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់យកទៅអនុវត្តសំដៅសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់ និងជាទស្សនទានថ្មីៗសម្រាប់ការអភិវឌ្ឍគ្រូបង្រៀន ឈានទៅរកការពង្រឹងគុណភាពនៃការបង្រៀន និងរៀន ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព។ ប្រការនេះទាមទារឲ្យមានការរៀបចំផែនការសកម្មភាពច្បាស់លាស់ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ និងការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។

(គោលនយោបាយស្តីពីគ្រូបង្រៀន, ២៧ ឧសភា ២០១៣)

## ២.៨ បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា

ការអភិវឌ្ឍធនធានមនុស្សទាមទារធ្វើការត្រួតពិនិត្យ ការតាមដាន និងវង្វាយតម្លៃជាប់ជាប្រចាំសំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ សេចក្តីណែនាំគោលកណ៍ឲ្យសម្រេចតាមផែនកាយុទ្ធសាស្ត្រវិស័យអប់រំ និងវិធានការកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា។

ដើម្បីឆ្លើយតបនឹងបរិបទប្រទេស និងបរិបទសកលភាវូបនីយកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា ក្នុងគោលបំណងកំណត់អំពីភារកិច្ច និងតួនាទីរបស់អធិការសម្រាប់ធ្វើអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីលើកកម្ពស់គុណភាពអប់រំឲ្យមានភាពឆ្លើយតប និងទទួលយកបានសម្រាប់ឈានចូលទៅសិក្សានៅតាមសាលាមធ្យមសិក្សាឯកទេស គ្រឹះស្ថានឧត្តមសិក្សា និងក្នុងទីផ្សារការងារ។

ការកសាងបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា មានវិសាលភាពលើការងារអធិការកិច្ចអប់រំសាធារណៈ និងឯកជនចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការលើកកម្ពស់គុណភាពអប់រំសំដៅបង្កើនគុណភាពប្រសិទ្ធភាព ភាពស័ក្តិ សិទ្ធិ ជំនឿទុកចិត្ត និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការនៃការដឹកនាំ និងការគ្រប់គ្រង ការរៀន និងការបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។

២.៧.១ ក្របខណ្ឌធានាគុណភាព

ការធានាគុណភាព គឺសំដៅលើសកម្មភាពទាំងឡាយដែលបានគ្រោង និងមានលក្ខណៈជាប្រព័ន្ធ ហើយត្រូវបានអនុវត្តក្នុងប្រព័ន្ធមួយ ឬអង្គភាពមួយ ដើម្បីធ្វើឲ្យតម្រូវការផ្នែកគុណភាពត្រូវបានបំពេញ ហើយអង្គភាពនោះត្រូវផ្តល់ផលិតផលដែលល្អបំផុត។ សកម្មភាពធានាគុណភាព មានន័យថាធ្វើឲ្យកុមារ ឬសិស្សទាំងអស់ទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសមធម៌ សំដៅជំរុញឲ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។ សកម្មភាពសំខាន់ៗក្នុងដំណើរការធានាគុណភាពមាន៖

- **ការពិនិត្យតាមដាន និងការត្រួតពិនិត្យ** ជារឿយៗសកម្មភាពនេះត្រូវផ្តោតលើលទ្ធផលជាស្ថិតិ។
- **ការវិភាគ** ប្រើប្រាស់ទិន្នន័យដែលបានប្រមូលទាំងអស់ ដើម្បីធ្វើការសន្និដ្ឋានលើដំណើរការពិនិត្យតាមដាន និងការត្រួតពិនិត្យ

- **សេចក្តីសន្និដ្ឋាន** ធ្វើការសម្រេចចិត្តថាចំណុចណាខ្លះដែលមិនទាន់បានល្អ ហើយត្រូវបង្កើតវិធានការណ៍ដើម្បីកែលម្អ
- **ការផ្តល់ព័ត៌មានត្រឡប់** អនុវត្តសកម្មភាពដើម្បីកែប្រែឥរិយាបថ និងកែលម្អលទ្ធផល

២.៧.២ អធិការកិច្ចផ្ទៃក្នុង

**អធិការកិច្ចផ្ទៃក្នុង** គឺផ្អែកលើការធ្វើស្វ័យវាយតម្លៃសាលារៀន ដែលអនុវត្តដោយនាយកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស។

នាយកសាលារៀនមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំធ្វើស្វ័យតម្លៃសាលារៀន។ ប្រព័ន្ធនេះត្រូវតែអភិវឌ្ឍដោយរួមបញ្ចូលនូវសកម្មភាពចាំបាច់ដូចជា ១) ការរៀបចំឯកសារ ២) ការបន្តពិនិត្យតាមដាន ៣) ការវិភាគ និងវាយតម្លៃតម្រូវការអភិវឌ្ឍ ៤)ការកសាងផែនការ និងការអនុវត្ត។

២.៧.៣ អធិការកិច្ចផ្ទៃក្រៅ

**អធិការកិច្ចផ្ទៃក្រៅ** គឺជាការធ្វើអធិកាកិច្ចរយៈពេលខ្លីណាមួយដោយអ្នកមកពីខាងក្រៅសាលារៀន។ ការធ្វើអធិការកិច្ចនេះ គឺជាការសាកសួរដើម្បីរកឲ្យឃើញនូវផ្នែកទាំងឡាយណា ដែលសាលារៀនបំពេញបានល្អ ឬមិនទាន់បានល្អ រួចរិះរកវិធានការណ៍ ឬផ្តល់អនុសាសន៍ដើម្បីស្វែងរកតម្រូវការនានាសម្រាប់កែលម្អចំណុចមិនទាន់បានល្អទាំងនោះ។

(បញ្ញត្តិនៃការធានាគុណភាពអប់រំ, កុម្ភៈ ២០២៥)

## ២.៨ ផែនការយុទ្ធសាស្ត្រការអប់រំ (ESP) ឆ្នាំ ២០១៤-២០១៨

មានបំណងបន្តផ្តល់អាទិភាពខ្ពស់បំផុតដល់លទ្ធភាពប្រកបដោយសមធម៌ ក្នុងការទទួលបានការអប់រំមានគុណភាពខ្ពស់ ជាពិសេសគឺការអប់រំថ្នាក់មូលដ្ឋាន(ថ្នាក់ទី១ ដល់ទី៩) ដើម្បីសម្រេចនូវសសរស្តម្ភជាតិ ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា។ ផែនការយុទ្ធសាស្ត្រការអប់រំ (ESP) ឆ្នាំ២០១៤-២០១៨ ក៏ផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រីកការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីៈ និងឱកាសទទួលបានការអប់រំថ្នាក់មធ្យម

សិក្សា និងក្រោយមធ្យមសិក្សាតាមរយៈការបន្ត និងការពង្រីកភាពជាដៃគូរវាងភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងមាតាបិតាសិស្ស។ ជាពិសេស ដើម្បីបង្កើតមូលដ្ឋានដ៏រឹងមាំ ផែនការយុទ្ធសាស្ត្រការអប់រំ ផ្តោតការយកចិត្តទុកដាក់លើ បញ្ហាគន្លឹះចំនួនពីរគឺ ១) ការសម្រេចបានលទ្ធភាពទទួលបាន ការអប់រំកម្រិតមូលដ្ឋានមានគុណភាពខ្ពស់ជាសកល ២) ការលើកកម្ពស់ឱកាសអប់រំស្មើគ្នាដើម្បីបង្កើនចំណូល និងមុខរបរ។

(ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨, មីនា ២០១៤)

## ២.៩ គោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០ -២០៣០

ចក្ខុវិស័យរបស់គោលនយោបាយនេះគឺ កែប្រែប្រទេសកម្ពុជាឲ្យមានសក្ខានុភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាកម្លាំងជំរុញល្បឿននៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាពធ្វើឲ្យសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

គោលនយោបាយនេះក៏មានគោលបំណងពង្រឹងមូលដ្ឋានគ្រឹះ និងកែលម្អបរិយាកាសនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់គុណភាពជីវិតប្រជាជនឲ្យកាន់តែប្រសើរ និងអភិវឌ្ឍប្រព័ន្ធអេកូនវានុវត្តន៍នៅគ្រប់កម្រិត និងគ្រប់វិស័យ។

សរុបមកគោលនបាយជាតិ វ.ប.ន នេះត្រូវបានបង្កើតឡើងដើម្បីគាំទ្ររបៀបវារៈអភិវឌ្ឍជាតិសំដៅឈានដល់ការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ តាមរយៈកាពង្រឹងមូលដ្ឋាននិងកសាងសមត្ថភាព វ.ប.ន.ជាតិ ដើម្បីបង្កើតបាននូវបច្ចេកវិទ្យាប្រកបដោយសក្តានុពលសម្រាប់ការអភិវឌ្ឍ បង្កើនសមត្ថភាពនវានុវត្តន៍ សំដៅឆ្លើយតបបានទៅនឹងសេចក្តីត្រូវការជាមូលដ្ឋានរបស់ជាតិ លើកស្ទួយគុណភាពជីវិតរបស់ប្រជាជន បង្កើនធនធានជាតិ កសាងខឿនឧស្សាហកម្មប្រកបដោយការប្រកួតប្រជែងក៏ដូចជាពង្រឹងអភិបាលកិច្ចកាន់តែប្រសើរ។

## ២.១០ គម្រោងកែលម្អគុណភាពអប់រំនៅឧត្តមសិក្សា (HEIP)

ដោយទទួលស្គាល់ថា សក្តានុពលនៃការអប់រំរួមចំណែកជំរុញការអភិវឌ្ឍ ដែលជាកត្តាអាទិភាពទីមួយសម្រាប់កម្ពុជា។ ផែនការជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច(២០១៤-២០១៨) និងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម (២០១៥-២០២៥) អំពាវនាវឲ្យបង្កើតសេដ្ឋកិច្ចប្រកួតប្រជែងមួយតាមរយៈចំណេះដឹង និងនវានុវត្តន៍។ ដើម្បីរក្សាចក្ខុវិស័យសេដ្ឋកិច្ចយូរអង្វែង ប្រទេសកម្ពុជានឹងត្រូវរក្សាការប្រកួតប្រជែងរបស់ខ្លួន និងបង្កើនខ្សែសង្វាក់ផលិតកម្មក្នុងការផលិត ផលិតផលបែបទំនើបដោយប្រើប្រាស់ចំណេះដឹងដ៏ឈ្លាវៃ។

គោលបំណងអភិវឌ្ឍរបស់គម្រោង គឺដើម្បីលើកកម្ពស់គុណភាព ភាពពាក់ព័ន្ធ និងសមធម៌នៃការអប់រំ និងស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ កែលម្អអភិបាលកិច្ចក្នុងវិស័យនេះ និងដើម្បីផ្តល់នូវការ ឆ្លើយតបជាបន្តបន្ទាប់ និងប្រកបដោយប្រសិទ្ធភាពក្នុងករណីមានវិបត្តិ ឬការបន្ទាន់សមប្រកបណាមួយនោះ។ សមាសភាគសំខាន់ៗចំនួនពីរ ត្រូវបានស្នើរឡើងនៅក្នុងគម្រោងរួមមាន៖

**សមាសភាគទី១៖** កែលម្អការស្រាវជ្រាវ ការបង្រៀន និងការរៀនសូត្រក្នុងមុខវិជ្ជា STEM និងកសិកម្ម

- សមាសភាគរង១.១៖ ការកែលម្អការបង្រៀន និងការរៀន គឺជួយលើកកម្ពស់ កម្មវិធីសិក្សា សាស្ត្រាចារ្យ និងសម្ភាររូបវន្ត។
- សមាសភាគរង១.២៖ កែលម្អការស្រាវជ្រាវ គឺជួយលើកកម្ពស់ការស្រាវជ្រាវមុខវិជ្ជា STEM និងវិស័យកសិកម្ម។
- សមាសភាគរង១.៣៖ ការបង្កើនសមត្ថភាពស្ថាប័ន គឺជួយលើកកម្ពស់គណនេយ្យភាពផ្ទៃក្នុង និងផ្ទៃខាងក្រៅរបស់ HEIs គោលដៅទាំង៦ និងបង្កើនសមធម៌។

**សមាសភាគទី២៖** ពង្រឹងអភិបាលកិច្ចតាមវិស័យ និងការគ្រប់គ្រងគម្រោង

- សមាសភាគរង២.១៖ ពង្រឹងអភិបាលកិច្ចតាមវិស័យ គឺពង្រឹងប្រព័ន្ធឧត្តមសិក្សាតាមរយៈការកែលម្អយន្តការធានាគុណភាព ការពង្រីកប្រព័ន្ធព័ត៌មាន និងគាំទ្រការបង្កើននីតិកម្មសម្រាប់ភាពស្វ័យ័តនៃ HEIs។

- សមាសភាគរង២.២៖ ការគ្រប់គ្រងគម្រោង និងការតាមដាននិងវាយតម្លៃ គឺគាំទ្រដល់ការប្រតិបត្តិការជាប្រចាំថ្ងៃ ការសម្របសម្រួល និងការគ្រប់គ្រងសកម្មភាពគម្រោងលើការធ្វើផែនការ និងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ ការងារលទ្ធកម្ម ការត្រួតពិនិត្យនិងរាយការណ៍ ការធ្វើសវនកម្មផ្ទៃក្នុងនិងខាងក្រៅ ការគ្រប់គ្រងកិច្ចគាំពារសុវត្ថិភាពសង្គមនិងបរិស្ថាន និងការត្រួតពិនិត្យ និងវាយតម្លៃ។

## ២.១១ គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិ(SEIP)

### ២.១១.១ ពិពណ៌នាអំពីគម្រោង

គម្រោងនេះត្រូវបានរចនាឡើងពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា។ ជាពិសេសគម្រោងនេះ នឹងគាំទ្រដល់ការបង្កើនកម្រិតរបស់គ្រូបង្រៀន ថ្នាក់មធ្យមសិក្សាបឋមភូមិដែលបច្ចុប្បន្នពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រក្នុងមុខវិជ្ជាដែលពួកគេបង្រៀន។ បន្ថែមលើនេះទៀត គម្រោងនឹងគាំទ្រក្នុងការអភិវឌ្ឍរចនាសម្ព័ន្ធគ្រប់គ្រងសាលារៀនថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់ការគាំទ្របន្ថែមដល់សាលារៀន ចំនួន១០០សាលារៀន ការិយាល័យអប់រំស្រុក(DOEs) នៅទីតាំងសាលារៀនទាំងនោះ និងមន្ទីរអប់រំខេត្ត ក្រុងទាំង២៥។ ការគាំទ្ររបស់គម្រោងនេះនឹងបង្កើនការគ្រប់គ្រងនៅថ្នាក់សាលារៀន និងសមត្ថភាពផ្នែកហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវតម្រូវការអភិវឌ្ឍសាលារៀនជាក់លាក់ ក៏ដូចជាស្ថាបនាប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៅតាមការិយាល័យអប់រំថ្នាក់ក្រោមជាតិផងដែរ។

### ២.១១.២ សមាសជាតុគម្រោង

**ក. សមាសធាតុទី១**

ការកែលម្អការអប់រំថ្នាក់មធ្យមសិក្សាបឋមភូមិ ដើម្បីឆ្លើយតាមបទដ្ឋាន ហើយសមាសជាតុនេះមានបំណងគាំទ្រគោលដៅ ESP និងTPAP តាមរយៈការបង្កើតនូវសាលារៀនមធ្យមសិក្សាបឋមភូមិ

ប្រកបដោយប្រសិទ្ធភាពចំនួន ១០០ សាលា។ សមាសធាតុនេះអាចសម្រេចបានតាមរយៈអនុសមាសធាតុចំនួនបីៈ

**១) ការពង្រឹងការគ្រប់គ្រងសាលារៀន** តាមរយៈការផ្តល់មូលនិធិកែលម្អសាលារៀន (SIF) នៅកម្រិតមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក សាលាមធ្យមសិក្សាបឋមភូមិគោលដៅទាំង១០០ សាលា។ ក្នុងអនុវិស័យនេះ មានគោលបំណងដើម្បីពង្រឹងការផ្តល់សេវាក្នុងកិច្ចខិតខំដើម្បីៈ

i. ពង្រឹងការគ្រប់គ្រងសាលារៀន តាមរយៈការធ្វើផែនការអភិវឌ្ឍសាលារៀន ការពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលការងាររបស់គ្រូបង្រៀននិងសិស្ស និងការចូលរួមរបស់សហគមន៍។

ii. គាំទ្រគ្រូបង្រៀនក្នុងការកែលម្អការបង្រៀន និងការអនុវត្តក្នុងការគ្រប់គ្រងថ្នាក់រៀន រួមទាំងការធ្វើកិច្ចតែងការបង្រៀន ការដាក់កិច្ចការផ្ទះ ឯកសារធ្វើតេស្តសិស្សប្រចាំខែ និងការវាយតម្លៃ/ការផ្តល់យោបល់ត្រឡប់ដល់សិស្ស។

**២) ការបង្កើនកម្រិតគុណវុឌ្ឍិគ្រូបង្រៀនថ្នាក់មធ្យមសិក្សាបឋមភូមិ** គណិតវិទ្យា រូបវិទ្យា ជីវវិទ្យា គីមីវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា និងនាយកសាលាឲ្យឈានដល់បរិញ្ញាបត្រ។ ការបង្កើនកម្រិតគុណវុឌ្ឍិគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រផ្សារភ្ជាប់ជាមួយគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ជាពិសេសទាក់ទងជាមួយវិស័យរបស់ STEM។ ក្នុងអនុវិស័យនេះមានគោលបំណងបង្កើនកម្រិតគុណវុឌ្ឍិគ្រូបង្រៀនចំនួន ២០០០នាក់ ព្រមទាំងនាយក នាយករងសាលាចំនួន ៣១០ នាក់ឲ្យឈានដល់កម្រិតបរិញ្ញាបត្រដែលមកពីសាលាគោលដៅទាំង១០០។

**៣) ការកែលម្អបរិក្ខាសាលារៀន** តាមរយៈការសាងសង់ និងការស្តារឡើងវិញនូវសាលារៀនដែលមានស្រាប់ចំនួន ១០០ និងសាលារៀនថ្មីចំនួន៣០ ដើម្បីផ្តល់លក្ខខណ្ឌអំណោចផលដល់ការបង្រៀន និងការរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចអនុវិស័យទាំងពីរខាងលើ អនុវិស័យនេះនឹងគាំទ្រការកែលម្អសម្ភារៈរូបវន្តរបស់សាលាមធ្យមសិក្សាបឋមភូមិនៃគោលដៅទាំង១៣០រួមមានៈ

i. ការសាងសង់ និងការស្តារឡើងវិញនូវសាលារៀនដែលមានស្រាប់ចំនួន១០០សាលា

ii. ការសាងសង់សាលារៀនថ្មីចំនួន៣០ថែមទៀតនៅក្នុងឃុំនានា ដែលកំពុងខ្វះខាតសាលាមធ្យមសិក្សាបឋមភូមិដោយរួមបញ្ចូលទាំងកន្លែងស្នាក់របស់គ្រូតាមការចាំបាច់ ហើយនឹងត្រូវអនុវត្តតាមរយៈវិធីសាស្រ្តការសាងសង់ដោយមានការចូលរួមពីសហគមន៍។

ខ. សមាសធាតុទី២៖ ការពង្រឹងការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ

សមាសធាតុនេះនឹងគាំទ្រការអនុវត្តជាប្រចាំថ្ងៃ ការសម្របសម្រួល និងការគ្រប់គ្រងសកម្មភាពគម្រោង លើការធ្វើផែនការ និងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ការមើលខុសត្រូវ និងការរាយការណ៍ សវនកម្មផ្ទៃក្នុង និងសវនកម្មពីខាងក្រៅ ការផ្ទៀងផ្ទាត់ដោយភាគីទីបីសម្រាប់ DLIs ការគ្រប់គ្រងការការពារសុវត្ថិភាពបរិស្ថាននិងសង្គម និងការពិនិត្យតាមដាន និងវាយតម្លៃ។

គ. សមាសធាតុទី៣៖ ការឆ្លើយតបនឹងគ្រាអាសន្ន

តារាងទី១. តារាងផែនការដំណើរការគម្រោង SEIP

| ការពិពណ៌នា | តម្លៃ (លានដុល្លា) | វិធីសាស្រ្ត | ឯកសារក្នុងស្រុក |
|---|---|---|---|
| **លទ្ធកម្មការងារ** | | | |
| ការកសាងសាលារៀនថ្មីចំនួន ៣០<br>ការជួសជុលលារៀនដែលមានស្រាប់ចំនួន ១០០<br>កន្លែងស្នាក់នៅរបស់គ្រូចំនួន ៣០<br>ការស្តារនីតិសម្បទាចំនួន ១០០ ដែល២៥ សម្រាប់ POE, ៩៩ សម្រាប់ DOE ហើយនិងគរុកោសល្យភូមិ ភាគចំនួន ៣ | ១៣.៦០ | ការចូលរួមពីសហគមន៍មូលដ្ឋាន | គ្មាន |

| | | | |
|---|---|---|---|
| **ដំណើរការសម្ភារៈ** | | | |
| មានដូចជាយានជំនិះ សម្ភារៈការិយាល័យ ឧបករណ៍ការិយាល័៧ ម៉ូតូ។ល។ | ២.២ | NCB | |
| **សេវាកម្មផ្តល់ប្រឹក្សា** | | | |
| ការជ្រើសរើសសេវាកម្មសម្រាប់ការផ្តល់ប្រឹក្សា៖<br>១) ត្រូវផ្ទៀងផ្ទាត់ដោយDLI<br>២) ការស្ទង់មតិតាមមូលដ្ឋាន និងបន្តបន្ទាប់<br>៣)ការធ្វើសវនកម្មហិរញ្ញវត្ថុព្រមទាំងការពិគ្រោះយោបល់ | <br>0.១<br>0.៤<br>0.៥ | <br>CQS<br>CQS<br>SSS | |
| អ្នកពិគ្រោះយោបល់ជាតិនិងអន្តរជាតិជាលក្ខណៈបុគ្គលសម្រាប់ការគាំទ្រការអនុវត្តគម្រោងនៅថ្នាក់ជាតិ និងកម្រិតសហគមន៍នៅតាមសាលា(Chief TAដំណើរការហិរញ្ញវត្ថុ ការត្រួតពិនិត្យសំណង់ អ្នកជំនាញគ្រប់គ្រងគម្រោងមន្ត្រីជំនាញខាង TA និង វិស្វករ...) | ២.៥៥ | ការជ្រើសរើសអ្នកប្រឹក្សាផ្ទាល់ | |

២.១១.៣ ការជ្រើសរើសសាលា

ការជ្រើសរើសាលារៀនចំនួន ១០០សាលា ដែលមានស្រាប់ និងសាលារៀនថ្មីចំនួន ៣០ សាលាគឺផ្អែកលើ៖

១) សាលារៀនដែលបង្ហាញនូវការប្តេជ្ញាចិត្តរឹងមាំ ចំពោះទស្សនទានគម្រោង ហើយឆ្លើយតបតាមបុរេលក្ខខណ្ឌក្នុងការជ្រើសរើសរបស់គម្រោង។

២) សាលារៀនដែលមានអត្រាបោះបង់ការសិក្សាខ្ពស់ មានអត្រាចុះឈ្មោះចូលរៀនទាប និងមានសមាមាត្រសិស្ស/គ្រូខ្ពស់។

ការជ្រើសរើសសាលារៀនដែលមានស្រាប់ទាំង១០០ មិនរួមបញ្ចូលនូវសាលារៀនធូរជារ ឬទទួលបានការឧបត្ថមល្អនោះទេ (ឧទាហរណ៍ សាលារៀនដែលមានគ្រូគ្រប់គ្រាន់ សាលារៀនគំរូនៅក្នុងមជ្ឈមណ្ឌលខេត្ត។ល។ ឬសាលារៀនដែលទទួលបានការគាំទ្រពីកម្មវិធីរបស់ម្ចាស់ជំនួយផ្សេងទៀតនោះឡើយ។

## ២.១២ គម្រោងលើកកម្ពស់គុណភាពអប់រំ(EEQP)

គម្រោងនេះមានគោលដៅ ១) ពង្រឹងគុណភាពអប់រំនៅតាមសាលារៀន ដោយផ្តោតលើការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធអប់រំយ៉ាងប្រុងប្រយ័ត្ន។ ២) ការអភិវឌ្ឍវិជ្ជាជីៈគ្រូបង្រៀន ៣) ការពង្រឹងការអប់រំនៅមធ្យមសិក្សា។

ឥទ្ធិពលនៃគម្រោងនេះ គឺជាកំណើននៃចំនួនប្រជាជនដែលទទួលបានការអប់រំ និងជំនាញកាន់តែប្រសើរឡើងនៅគ្រប់មជ្ឈដ្ឋានទូទាំងអស់នៃប្រជាជនកម្ពុជា ជាពិសេសសិស្សនារីនិងសិស្សដែលមកពីតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

លទ្ធផលនៃគម្រោង គឺជាការលើកស្ទួយគុណភាព និងសមធម៌នៃការអប់រំនៅកម្ពុជា ជាមួយការអប់រំនៅមធ្យមសិក្សាកាន់តែមានប្រសិទ្ធភាព សមត្ថភាពគ្រូបង្រៀនកាន់តែប្រសើរឡើង និងប្រព័ន្ធគ្រប់គ្រងអប់រំកាន់តែរឹងមាំ។

(https://www.moeys.gov.kh/index.php/kh/eeqp/project-information.html)

## ២.១៣ សាលាមធ្យមសិក្សាធនធាន

### គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន

- ថែរក្សា និងប្រើប្រាស់អគារធនធានឲ្យអស់លទ្ធភាព

- ជំរុញការតម្រង់ទិសវិជ្ជាជីវៈដល់សិស្ស និងបង្កើនចំណេះដឹងផ្សេងៗ តាមរយៈបច្ចេកវិទ្យាព័ត៌មាន និងសាគមនាគមន៍(ICT) ជាមួយសហគមន៍សិក្សា។
- ផ្តល់នូវការដឹកនាំតម្រង់ទិសក្នុងការជួយគាំទ្រ និងការប្រើប្រាស់វិធីសាស្រ្តបង្រៀននិងរៀនដែលល្អ ដើម្បីគាំទ្រការអភិវឌ្ឍការផ្តួចផ្តើមថ្មីរបស់ក្រសួង អ.យ.ក ដូចជា ពង្រឹងការអនុវត្តកម្មវិធីសិក្សា និងការពិនិត្យតាមដាន។
- ក្នុងអំឡុងពេលជាក់លក់មួយនឹងក្លាយជាមជ្ឈមណ្ឌលឧត្តមភាពមួយនៃការបង្រៀន និងរៀន ការប្រតិបត្តិ អប់រំនិងគំរូនៃលទ្ធផលសិក្សា និងការបង្រៀនដែលអាចផ្សព្វផ្សាយបន្តទៅសាលារៀនដទៃទៀត។
- បង្ហាញថាគ្រប់ផ្នែកទាំងអស់នៃដំណើរការសាលារៀន និងទំនាក់ទំនងសាលារៀន-សហគមន៍មានការអភិវឌ្ឍទៅមុខ ដោយយកការអភិវឌ្ឍគុណភាពសាលារៀនធ្វើជាមូលដ្ឋាន។
- សរសេរចង់ក្រងឯកសារ ចែករំលែកឯកសារនិងបទពិសោធនៃការអភិវឌ្ឍធនធានមនុស្សនិងធនធាន សម្ភារៈជាមួយសាលារៀនដទៃទៀត ព្រមទាំងជួយសាលារៀនទាំងនោះឲ្យចេះតាក់តែងនិងអនុវត្តការផ្លាស់ប្តូរក្នុងបរិបទផ្ទាល់ខ្លួនរបស់ពួកគេ។
- ខិតខំឲ្យស្មើនឹងសាលារៀនដែលមានការប្រតិបត្តិ និងលទ្ធផលលេចធ្លោរបស់ប្រទេសមួយចំនួនក្នុងតំបន់។
- កៀរគរមូលនិធិពីគ្រប់អ្នកពាក់ព័ន្ធ និងពីគ្រប់មជ្ឈដ្ឋានដើម្បីជានានិរន្តភាពរបស់សាលារៀនដោយមានភាពយុត្តធម៌និងតម្លាភាព។

## ២.១៤ ទ្រឹស្តីពាក់ព័ន្ធ

២.១៤.១ គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សានៅប្រទេសនេប៉ាល់(SEIP at Nepal)

ប្រទេសនេប៉ាល់កំពុងដំណើរការ គម្រោងកែលម្អគុណភាពអប់រំកម្រិតមធ្យមសិក្សា (SEIP) ដើម្បីកែលម្អបរិយាកាសសិក្សាក៏ដូចជាដើម្បីពង្រឹងគុណភាពទូទៅនៃអនុវិទ្យាល័យចំនួន ៧ នៅសូលូគូបា អនុវត្តវិធិសាស្រ្ត សាលាគំរូ។ ដើម្បីធច្វើឲ្យបរិយាកាសរៀនសូត្រ បរិក្ខាអានដោយខ្លួនឯងបន្ថែម

និងសមស្របតាមអាយុ ត្រូវអនុវត្តដើម្បីលើកកម្ពស់ទំលាប់នៃការអាន និងចំណាប់អារម្មណ៍ក្រោមកម្មវិធីបណ្ណាល័យ។ ស្វ័យភាពដ៏ធំទាក់ទងនឹងការបែងចែកធនធាន ការធ្វើផែនការ និងការអនុវត្ត SEIP ត្រូវបានផ្តល់ជូនដើម្បីធានាបាននូវស្តង់ដារគុណភាពអប្បបរមាទាក់ទងនឹងបរិស្ថាន និងដំណើរការបង្រៀន ស្របតាមតម្រូវការ និងភាពចម្រុះនៃសាលារៀន ជាមួយសហគមន៍មូលដ្ឋាន។ ដូច្នេះការអភិវឌ្ឍគ្រូបង្រៀនផ្អែកលើការអនុវត្ត និងគណនេយ្យភាពក៏ជាធាតុសំខាន់មួយទៀតនៅក្នុងគម្រោង SEIP នេះដែលគ្រូបង្រៀនត្រូវបានលើកទឹកចិត្តឲ្យធ្វើវាយតម្លៃខ្លួនឯង និងពីមិត្តភក្តិជាប្រចាំ ដើម្បីកំណត់ការអភិវឌ្ឍជំនាញដែលពួកគេពេញចិត្តដោយផ្អែកលើសមត្ថភាព និងតម្រូវការ ដើម្បីធានាបាននូវកិច្ចការទាន់ពេលវេលា។

បច្ចុប្បន្នប្រទេសនេប៉ាល់ បានកំពុងដំណើរការកម្មវិធីគម្រោងកែលម្អគុណភាពអប់រំកម្រិតមធ្យមសិក្សាដូចជា:

- ❖ **ការកសាងសមត្ថភាពនៃការគ្រប់គ្រងសាលារៀន**
  - ➢ សិក្ខាសាលាពង្រឹងសមត្ថភាពនៃការគ្រប់គ្រងសាលារៀន
  - ➢ ជំនួយក្នុងការប្រជុំ SMC / PTA ប្រចាំខែ ដើម្បីធានាគណនេយ្យភាព និងអភិបាលកិច្ចល្អ
  - ➢ គាំទ្រឲ្យអនុវត្តសវនកម្មសង្គមជាប្រចាំ
  - ➢ យុទ្ធនាការសម្រាប់ការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពសាលារៀន
  - ➢ ការប្រឹក្សាជាមួយឪពុកម្តាយ និងការចុះទៅដល់លំនៅស្ថានរបស់សិស្ស
- ❖ **ការបណ្តុះបណ្តាលការវាយតម្លៃរវាងគ្រូ និងគ្រូ**
  - ➢ ការបណ្តុះបណ្តាលលើការវាយតម្លៃការអនុវត្តរបស់គ្រូ និងគ្រូ
  - ➢ ការអភិវឌ្ឍឧបករណ៍វាយតម្លៃ
- ❖ **កម្មវិធីបណ្ណាល័យ**
  - ➢ បណ្តុះបណ្តាលការគ្រប់គ្រងបណ្ណាល័យ

- ការអភិវឌ្ឍគោលការណ៍ណែនាំសម្រាប់លើកកម្ពស់អក្ខរកម្ម និងការស្រាវជ្រាវនៅតាមសាលារៀន
- គាំទ្រសៀវភៅ និងសំណុំឯកសារផ្សេងៗ
- ការត្រួតពិនិត្យ និងការតាមដាន

( http://www.reednepal.org/secondary-education-improvement-project/ )

២.១៤.២ គម្រោងកែលម្អគុណភាពអប់រំនៅមត្តេយ្យសិក្សានៅVANUATU In The PACIFIC (PEIP)

VANUATU ជាកោះមួយក្នុងចំណោមកោះជាច្រើននៅប្រទេសប៉ាស៊ីហ្វិក ដែលការអប់រំនៅបឋមសិក្សាមានការលំបាកព្រោះមានការជាប់ទាក់ទងពីភាសាបារាំង-អង់គ្លេសដែលកំពុងមានការលំបាកក្នុងការគ្រប់គ្រងប្រព័ន្ធអប់រំ។ VANUATU ត្រូវបានចាប់ផ្តើមមូលនីធិដោយម្ចាស់ជំនួយគម្រោងអភិវឌ្ឍអភិក្រមលើវិស័យ (SWAp) ដើម្បីលើកកម្ពស់គុណភាពអប់រំ។ គោលដៅអភិវឌ្ឍ (MDGs) ដែលបានកំណត់គោលដៅកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់មនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

PEIP ជាគម្រោងមួយដែលមានគោលជំហដ៏រឹងមាំសម្រាប់ការអប់រំនៅប៉ាស៊ីហ្វិក។ ការគិតឡើងវិញអំពី ប្រព័ន្ធអប់រំរបស់ VANUATU ដែលជួយនាំមកនូវអាទិភាពសម្រាប់ការអភិវឌ្ឍវិស័យអប់រំ (Sanga 2004) ។ Nirua (2004) បាននិយាយថា "យើងជាអ្នកអប់រំ ជាអ្នករៀបចំផែនការ ជាអ្នករដ្ឋបាល ជាអ្នកគ្រប់គ្រង ជាអ្នកបង្កើតគោលនយោបាយ និងជាក្រុមប្រឹក្សាត្រូវតែអនុវត្តជានិច្ច"។ អ្នករៀបចំផែនការបានទទួលស្គាល់ថា គ្រូបង្រៀន គឺជាសមាសធាតុសំខាន់មួយនៅក្នុងការកែទម្រង់ការអប់រំ ហើយការភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាល ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន និងការៀនសូត្រជាអាទិភាពទីមួយ។

ប្រសិនបើទទួលបានជោគជ័យក្នុប្រព័ន្ធបែបនេះ អាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឯកសារគុណភាពនៃ ការអប់រំទៅទៅនៅក្នុងសហគមន៍ តាមរយៈការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់គ្រូសាធារណៈ និងគ្រូដែលមិនទាន់បានទទួលការបណ្តុះបណ្តាលចំនួន ៣៣ភាគរយ ដែលកំពុងបម្រើការងារនៅសាលាបឋមសិក្សា VANUATU (VANUATU 2004)។ គោលបំណងនៃគម្រោងកែលម្អគុណភាពអប់រំនៅបឋមសិក្សា មានគោលបំណងសំខាន់ៗ ៣ គឺ៖

- **គោលបំណងទី១៖** សុខដុមនីយកម្មភាសា ដោយសារវ៉ានូអាទូ មានប្រព័ន្ធអប់រំពីរផ្សេងគ្នា គឺបារាំងមួយ និងអង់គ្លេសមួយ។ ជាប្រវត្តិសាស្ត្រ ប្រព័ន្ធអប់រំពីរបានដំណើរការដាច់ដោយឡែកពីគ្នារួមទាំង កម្មវិធីបណ្តុះបណ្តាលគ្រូ។ ការធ្វើសុខដុមនីយកម្ម នៃប្រព័ន្ធពីរភាសាគឺ ត្រូវការជាចាំបាច់ដើម្បីសម្រេចបានអាណត្តិVESS នៃស្តង់ដារជាតិសម្រាប់ការបង្រៀន និងការរៀនសូត្រ។ ដូច្នេះ PEIP នឹង៖
    - ✓ រួមបញ្ចូលទាំងគ្រូភាសាអង់គ្លេស និងគ្រូភាសាបារាំងនៅក្នុងសកម្មភាពទាំងអស់
    - ✓ ការប្រើសម្ភារៈបណ្តុះបណ្តាលពីរភាសា
    - ✓ អនុវត្តសកម្មភាពបណ្តុះបណ្តាលទាំងអស់នៅ Bislama
    - ✓ រាប់បញ្ចូលទាំងសាស្ត្រាចារ្យFrancophone និងAnglophone ជាអ្នកផ្តល់ព័ត៌មានសំខាន់ៗសម្រាប់សកម្មភាពទាំងអស់។
- **គោលបំណងទី២៖** បង្កើនគុណវុឌ្ឍិគ្រូដែលបង្រៀននៅសាលាសាធារណៈ
  បច្ចុប្បន្នមិនមានប្រព័ន្ធអប់រំ ឬកម្មវិធីសិក្សារបស់ក្រសួងអប់រំណាដែលជួយធ្វើឲ្យគ្រូបង្រៀនមានភាពប្រសើរឡើងនោះទេ។ បើគ្រូបង្រៀនបានចូលរួមក្នុងការបណ្តុះបណ្តាលនៅកន្លែងណាមួយ ក៏មិនមានការលើកទឹកចិត្តសម្រាប់ការកែលម្អការអនុវត្តរបស់ពួកគេនោះទេ។ ដូច្នេះគម្រោងកំណែទម្រង់ PEIP មានគោលបំណងផ្តល់ក្របខណ្ឌសម្រាប់ការកែលម្អគ្រូបង្រៀន និងបង្ហាញយុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធ អប់រំបែបនេះ។
- **គោលបំណងទី៣៖** វិញ្ញាបនបត្ររបស់គ្រូដែលមិនទាន់ទទួលបានការបណ្តុះបណ្តាល

ក្រសួងអប់រំ យុវជន និងកីឡា បានរាយការណ៍ថាមាន ៣៣ ភាគរយនៃគ្រូបឋមសិក្សាទាំងអស់គឺមិន មានការបណ្តុះបណ្តាលទេ និងជាគ្រូបង្រៀនតាមសហគមន៍។ មានមូលហេតុពីរចំពោះបញ្ហានេះ គឺ

- ✓ ចំនួនប្រជាជននៅជនបទមានការកើនឡើងយ៉ាងរហ័ស
- ✓ គ្រូត្រូវបានតែងតាំងដោយសហគមន៍របស់ពួកគេ (លក្ខខណ្ឌគឺ មានទីលំនៅក្នុងភូមិកំណើត និយាយភាសាកំណើត និងបានបញ្ចប់ថ្នាក់អនុវិទ្យាល័យ)

# ជំពូកទី៣. វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣. ១. គម្រោងវិភាគ

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានជ្រើសរើសយកប្រភេទនៃការស្រាវជ្រាវតាមការវិភាគបែបចម្រុះ(Mixed-Methods) ដែលក្នុងនោះមាន ការវិភាគតាមបែបបរិមាណវិស័យផង និងគុណវិស័យផង ដែលត្រូវបានរៀបចំឡើងដើម្បីយកមកស្វែងរកស្ថានភាព និងដំណើរការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលជួយដល់ការរៀន និងបង្រៀន នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ដែលជាគោលដៅនៃការស្រាវជ្រាវ។

ដើម្បីឆ្លើយតបទៅនិងវត្ថុបំណង និងសំណួរស្រាវជ្រាវដែលបានកំណត់នៅក្នុងជំពូក១ខាងលើនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបចម្រុះ ព្រោះក្នុងវិធីសាស្ត្រចម្រុះនេះ រួមមានវិធីសាស្ត្រវិភាគ តាមបែបបរិមាណវិស័យ និងគុណវិស័យផង ដែលធ្វើឲ្យអ្នកស្រាវជ្រាវងាយស្រួលក្នុងការប្រមូលទិន្នន័យបាន ច្បាស់លាស់ និងមានភាពស៊ីជម្រៅជាងការប្រើប្រាស់វិធីសាស្ត្រតែមួយប្រភេទ។

ក្នុងការសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវនឹងប្រើប្រាស់កម្រងសំណួរដែលមានទម្រង់បិទ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការជ្រើសរើសចម្លើយដែលមានស្រាប់ ហើយងាយស្រួលបំពេញកម្រងសំណួរផ្សេងៗទៀត ជាពិសេសប្រើប្រាស់រយៈពេលខ្លីក្នុងការឆ្លើយសំណួរ ឬបំពេញចម្លើយ។ ម្យ៉ាងវិញទៀតការប្រើប្រាស់វិធីតាមបែបបរិមាណវិស័យនេះ ធ្វើឲ្យអ្នកស្រាវជ្រាវចំណេញពេលវេលាក្នុងការប្រមូលទិន្នន័យ និងបញ្ចូលទិន្នន័យដើម្បីវិភាគផងដែរ។

ចំណែកឯការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យវិញ អ្នកស្រាវជ្រាវនឹងប្រើប្រាស់កម្រងសំណួរសម្រាប់សម្ភាសន៍ ព្រមទាំងកម្រងសំណួរបែបទម្រង់បើកសម្រាប់ធ្វើការបំពេញ ដើម្បីស្វែងរកព័ត៌មានកាន់តែជាក់ច្បាស់ថែមទៀត។ លើសពីនេះទៅទៀត ការសិក្សាតាមបែបគុណវិស័យ ធ្វើឲ្យអ្នកស្រាវជ្រាវ

បានសិក្សាកាន់តែមានភាពស៊ីជម្រៅទៅលើស្ថានភាពជាក់ស្តែង និងស្វែងយល់កាន់តែច្បាស់អំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោង កែលម្អគុណភាបអប់រំនៅមធ្យមសិក្សា ដែលជួយដល់ការបង្រៀន និងរៀន។ ជាពិសេស អ្នកស្រាវជ្រាវអាចស្វែងរកចំណុចខ្វះខាតទៅលើការកែលម្អគុណភាពអប់រំបន្ថែមទៀត ម្យ៉ាងវិញទៀត វិធីសាស្ត្រនេះក៏អាចផ្តល់ឱកាស ឲ្យមានការចូលរួម(ភាគសំណាក) បានបង្ហាញនូវចំណាប់អារម្មណ៍ផ្ទាល់របស់ពួកគេ។

## ៣. ២. ការប្រមូលទិន្នន័យ

បន្ទាប់ពីបានទទួលការណែនាំពីលោកគ្រូដឹកនាំ និងលោកគ្រូដឹកនាំរង ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំលេខៈ ១៨៦ ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័កព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំឲ្យចុះធ្វើការប្រមូលទទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៅតាមរាជធានី-ខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីបានទទួលការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង តាមរយៈកំណត់បង្ហាញ ចុះថ្ងៃព្រហស្បត្តិ ៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការសម្រួលដល់កាចុះប្រមូលទិន្នន័យ នៅវិទ្យាល័យបវេល ក្នុងខេត្តបាត់ដំបង។ អ្នកស្រាវជ្រាវ បានជួបជាមួយលោកប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ដើម្បីសុំការអនុញ្ញាតចុះប្រមូលទិន្នន័យនៅវិទ្យាល័យបវេល។ ក្នុងពេលដែលបានជួបជាមួយលោកប្រធានការិយាល័យ លោកមានការទទួលដោយក្តីរីករាយ ព្រមទាំងបានជួយក្នុងការចេញលិខិតដល់អ្នកស្រាវជ្រាវបានយ៉ាងឆាប់រហ័ស។ លោកប្រធានការិយាល័យបានជូនសេចក្តីណែនាំនេះទៅលោកស្រីអនុប្រធានមន្ទី ដើម្បីចុះហត្ថលេខាអនុញ្ញាតឲ្យចុះប្រមូលទិន្នន័យនៅវិទ្យាល័យបវេលដោយក្តីរីករាយ និងមានភាពកក់ក្តៅបំផុត។ បន្ទាប់ពីអ្នកស្រាវជ្រាវបានការអនុញ្ញាតពីលោកស្រីប្រធានមន្ទីរួចមក អ្នកស្រាវជ្រាវបានយកលិខិតអនុញ្ញាតធ្វើដំណើរទៅកាន់ការិយាល័យអប់រំស្រុកបន្តទៀត ដើម្បីជូនជាដំណឹងដល់ការិយាល័អប់រំស្រុក អំពីការស្នើសុំការសហការចុះប្រមូលទិន្នន័យ

នៅសលាគោលដៅដែលបានកំណត់ខាងលើ។ ក្រោយពេលអ្នកស្រាវជ្រាវ ទទួលបានកាអនុញ្ញាតពីលោកប្ធានការិយាល័យអប់រំស្រុករួចមកអ្នកស្រាវជ្រាវក៏បានធ្វើដំណើរទៅកាន់វិទ្យាល័យបវេលតែម្តង។ វិទ្យាល័យបវេល ជាសាលារៀនមួយ ដែលស្ថិតនៅក្នុងភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។

នៅពេលដែលអ្នកស្រាវជ្រាវបានមកដល់បរិវេណសាលាវិទ្យាល័យបវេល អ្នកស្រាវជ្រាវបានការទទួលស្វាគមន៍ពីសំណាក់លោកនាយក លោកគ្រូ អ្នកគ្រូដោយភាពរីករាយ និងមានភាពស្និទ្ធស្នាលបំផុត។ បន្ទាប់មក អ្នកស្រាវជ្រាវបានសុំជួបជាមួយលោកនាយកសាលា ដើម្បីជូនលិខិតសុំចុះប្រមូលទិន្នន័យសម្រាប់បញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ និងដើម្បីសុំសម្ភាសន៍ជាមួយលោកនាយកសាលាព្រមទាំងបំពេញកម្រងសំណួរបន្ថែម ព្រោះដើម្បីបានទិន្នន័យដែលច្បាស់លាស់និងមានភាពស៊ីជម្រៅ។

បន្ទាប់ពីបានជួបជាមួយលោកនាយកសាលា និងបានបង្ហាញពីគោលបំណងក្នុងការចុះប្រមូលទិន្នន័យរួចមក អ្នកស្រាវជ្រាវបានជួបជាមួយលោកគ្រូ អ្នកគ្រូ និងពន្យល់ពីគោលបំណងនៃការប្រមូលទិន្នន័យដល់លោកគ្រូ អ្នកគ្រូ ដើម្បីឲ្យពួកគាត់បានដឹងអំពីគោលបំណងរបស់អ្នកស្រាវជ្រាវ។ មុននឹងចែកកម្រងសំណួរ អ្នកស្រាវ ជ្រាវបានធ្វើការណែនាំពីគោលបំណង និងវិធីបំពេញកម្រងសំណួរដល់លោកគ្រូ អ្នកគ្រូ ដែលក្នុងនោះអ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួន២២ច្បាប់សម្រាប់លោកគ្រូ អ្នកគ្រូដើម្បីបំពេញ។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតទម្រង់សំណួរស្រាវជ្រាវចំនួន៣ប្រភេទ ដើម្បីឆ្លើយតបនឹងវត្ថុបំណងនៃការស្រាវជ្រាវរួមមាន៖ ទី១ ទម្រង់សំណួរសម្រាប់សិស្ស ទី២ ទម្រង់សំណួរសម្រាប់គ្រូបង្រៀន ទី៣ ទម្រង់សំណួរសម្រាប់សម្ភាសន៍និងសម្រាប់នាយកសាលាបំពេញ។

ទម្រង់សំណួរី១៖ ទម្រង់សំណួរសម្រាប់សិស្ស អ្នកស្រាវជ្រាវបានរៀបចំជា៦ផ្នែក៖ **ផ្នែកទី១** ព័ត៌មានទូទៅរបស់សិស្ស មាន៣ចំណុចគឺ(១) ឈ្មោះស្រុក (២) ឈ្មោះសាលា (៣) ភេទ។ **ផ្នែកទី២** គុណវុឌ្ឍិគ្រូ បង្រៀន មាន៣ចំណុចគឺ(១) កម្រិតចំណេះដឹងលើមុខវិជ្ជា (២) សមត្ថភាពរបស់គ្រូ

ជួយសិស្សរៀនយឺត (៣) គុណភាពនៃការបង្រៀនរបស់គ្រូ។ **ផ្នែកទី៣** កម្មវិធីសិក្សា មាន៥ចំណុចគឺ (១) ខ្លឹមសារសៀវភៅសិក្សាគោល គ្រប់មុខវិជ្ជា (២)កម្រិតនៃការយកចិត្តទុកដាក់ទៅលើសៀវភៅពុម្ព (៣)ការធ្វើតេស្តស្តង់ដា (៤)ចំណាប់អារម្មណ៍ចំពោះការធ្វើតេស្តស្តង់ដា (៥)ការជួយរបស់គម្រោងSEIPទៅលើសិស្ស ។ **ផ្នែកទី៤** សម្ភារៈទ្រទ្រង់ការបង្រៀន មាន២ចំណុចគឺ (១) កម្រិតនៃការប្រើប្រាស់សម្ភារៈឧបទេសក្នុងការរៀន (២) កម្រិតនៃការលើកទឹកចិត្តរបស់លោកគ្រូ អ្នកគ្រូទៅកាន់សិស្ស។ **ផ្នែកទី៥** សកម្មភាពសិស្សក្នុងថ្នាក់ មាន២ចំណុចគឺ (១)ចំនួនសិស្សក្នុងថ្នាក់ (២)ឥទ្ធិពលអវិជ្ជមានចំពោះសិស្សច្រើនក្នុងថ្នាក់។ **ផ្នែកទី៦** បរិមាណសិស្សក្នុងថ្នាក់ មាន២ចំណុចគឺ(១)កម្រិតនៃការប្រឹងប្រែងរៀនសូត្ររបស់សិស្ស (២)សំណូមពរទាក់ទងបញ្ហាប្រឈម។

ទម្រង់សំណួរទី២៖ ទម្រង់សំណួរសម្រាប់គ្រូបង្រៀន អ្នកស្រាវជ្រាវបានរៀបចំជា៨ផ្នែក៖ **ផ្នែកទី១** អំពីព័ត៌មានទូទៅរបស់គ្រូ មាន៤ចំណុចគឺ(១)ឈ្មោះស្រុក (២)ឈ្មោះសាលា (៣)មុខវិជ្ជា (៤)ភេទ។ **ផ្នែកទី២** អំពីគុណវុឌ្ឍិគ្រូបង្រៀន មាន៧ចំណុចគឺ(១)ក្របខណ្ឌ (២)សញ្ញាបត្រ (៣)សមត្ថភាពគ្រូ (៤)បទពិសោធបង្រៀន (៥) ការចូលរួមវគ្គបំប៉ន (៦)សារៈសំខាន់នាំការចូលរួមវគ្គបំប៉ន (៧) ការជ្រើសរើសវគ្គបំប៉ន ។ **ផ្នែកទី៣** អំពីកម្មវិធីសិក្សា មាន១៥ចំណុចគឺ(១)បំណែងចែកកម្មវិធីសិក្សា (២)ផលប្រយោជន៍នៃកម្មវិធីសិក្សា (៣)បន្ទប់ពិសោធន៍ (៤)ម៉ោងពិសោធន៍ ឬអនុវត្ត (៥)បណ្ណាល័យ (៦)ម៉ោងស្រាវជ្រាវក្នុងបណ្ណាល័យ (៧)ការធ្វើតេស្តសិស្ស (៨)គោលវិធីសម្រាប់បង្រៀន (៩)វិធីសាស្ត្របង្រៀន (១០)ការធ្វើកិច្ចតែងការបង្រៀន (១១)ការរៀបចំកិច្ចតែងការ (១២)ការដាក់កិច្ចការផ្ទះ (១៣)ភាគរយសិស្សធ្វើកិច្ចការផ្ទះ (១៤)ចំនួនម៉ោងតាមមុខវិជ្ជា (១៥)ចំនួនម៉ោងបន្ថែម ។ **ផ្នែកទី៤** សកម្មភាពរបស់សិស្សក្នុងថ្នាក់ មាន២ចំណុចគឺ (១) កម្រិតនៃការប្រើប្រាស់សកម្មភាព (២)ការលើកទឹកចិត្តសិស្ស។ **ផ្នែកទី៥** បរិមាណសិស្សក្នុងថ្នាក់ មាន២ចំណុចគឺ(១)ចំនួនសិស្សក្នុងថ្នាក់រៀន (២)ឥទ្ធិពលសិស្សច្រើនក្នុងថ្នាក់។ **ផ្នែកទី៦** វិន័យ មាន៣ចំណុចគឺ (១)វិធានការចំពោះសិស្សយឺត (២)ចំនួនអវត្តមានរបស់សិស្ស (៣)ភាគរយនៃការមករៀនទៀងពេល។ **ផ្នែកទី៧** បរិស្ថានសិក្សា មាន៣ចំណុចគឺ(១)ការចុះកម្មសិក្សា (២)ទីកន្លែងសិក្សា (៣)ទំនាក់ទំនងសិស្សនិង

គ្រូ។ **ផ្នែកទី៨** ប្រសិទ្ធភាព មាន៥ចំណុចគឺ (១)កម្រិតវប្បធម៌របស់គ្រូ (២)បទពិសោធន៍បង្រៀន (៣)កម្រិតថ្នាក់ដែលគ្រូត្រូវបង្រៀន (៤)ការប្រជុំបច្ចេកទេស (៥)ចំណុចខ្លាំង និងចំណុចខ្សោយរបស់គម្រោងSEIP។

ទម្រង់សំណួរទី៣៖ កម្រងសំណួរសម្រាប់ការសម្ភាសន៍នាយក ឬនាយិកាសលា។ នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៤ផ្នែក។ **ផ្នែកទី១** ព័ត៌មានទូទៅ មាន៤ចំណុចគឺ (១) ឈ្មោះស្រុក (២) ឈ្មោះសាលា (៣) ឋានតួនាទី (៤) ភេទ។ **ផ្នែកទី២** គុណវុឌ្ឍិនាយក ឬនាយិកា មាន៥ចំណុចគឺ(១) រយៈ ពេលប្រើការងារ (២) ក្របខណ្ឌនាយក (៣)សញ្ញាបត្រចុងក្រោយ (៤) ការចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនឹងការគ្រប់គ្រង (៥) ការចូលរួមបណ្តុះបណ្តាលទាក់ទងនឹងគម្រោងSEIP។ **ផ្នែកទី៣** ការគ្រប់គ្រងសាលា មាន៨ចំណុចគឺ(១) ចំនួនគ្រូសរុប (២) ចំនួនគ្រូបឋមភូមិ និងចំនួនគ្រូទុតិយភូមិ (៣) ចំនួនគ្រូដែលចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈគម្រោងSEIP (៤) ការចែករំលែកចំណេះដឹងថ្មី (៥) ការអនុវត្តការងាររបស់គ្រូបង្រៀន (៦) លទ្ធផលសិក្សារបស់សិស្សឆ្នាំចាប់ផ្តើមគម្រោងSEIP (៧) ការជួយសិស្សដែលរៀនយឺត (៨) ការជួយសិស្សដែលជួបការលំបាក។ **ផ្នែកទី៤** សម្ភារូបវន្ត មាន៥ចំណុចគឺ(១) សៀវភៅសិក្សាគោល (២) បណ្ណាល័យគាំទ្រការរៀន និងបង្រៀន (៣) អគារសិក្សា និងថ្នាក់ (៤) កន្លែងស្នាក់នៅសម្រាប់គ្រូ និងសិស្ស (៥) សំណូមពររបស់នាយកសាលា

## ៣.៤. ការជ្រើសរើសគំរូតំណាង

ក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានជ្រើសរើសយកមកធ្វើការសិក្សាសរុបចំនួន ៥៨ នាក់ គឺគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូដែលបង្រៀនថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ នៃវិទ្យាល័យបវេល ចំនួន២២នាក់ ស្រី១៥ នាក់ និងសិស្សានុសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ចំនួន ១៥ នាក់ ។ វិទ្យាល័យបវេល ជាសាលារៀនមួយដែលមានទីតាំងស្ថិតនៅក្នុងភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ វិទ្យាល័យបវេលនៅឆ្នាំ ២០១៩-២០២០ មានបុគ្គលិកទាំងអស់ចំនួន៨៩នាក់ រួមមាន៖ នាយក ១នាក់ នាយករង ១នាក់ នាយិការង១នាក់ និងលោកគ្រូ អ្នកគ្រូចំនួន ៨៦នាក់ ស្រី ៣៩នាក់ និងមានសិស្ស

សរុបចំនួន ២៩៣០ នាក់ ស្រី ១៦៣៧ នាក់ ដែលសិស្សានុសិស្សភាគច្រើនមកពីគ្រួសារកសិករ ហើយខ្លះមកពីគ្រួសារដែលជួបការលំបាក និងមានទីលំនៅឆ្ងាយពីសាលារៀន។

ការជ្រើសរើសយកគណៈគ្រប់គ្រង និងលោកគ្រូ-អ្នកគ្រូនៃវិទ្យាល័យបវេលយកមកសិក្សានេះ ដោយសារ អ្នកស្រាវជ្រាវបានបម្រើការងារនៅទីនោះ ហើយវិទ្យាល័យបវេលកំពុងបង្កើតគំរូអភិវឌ្ឍថ្មី ក្នុងប្រព័ន្ធអប់រំស្វ័យ័តដែលមានការចូលរួមពី ថ្នាក់មន្ទី ការិយាល័យអប់រំស្រុក សហគមន៍មូលដ្ឋាន អាជ្ញាធរ ព្រមទាំងមាតាបិតាសិស្ស។ម្យ៉ាងទៀត វិទ្យាល័យបវេលជាសាលារៀនមួយដែលមានផល ធៀបសិស្ស-គ្រូខ្ពស់ សិស្សបោះបង់ការសិក្សាខ្ពស់។ល។

**តារាងទី១៖ ទិន្នន័យភាគសំណាក**

| ភាគសំណាក | សរុប | ស្រី |
|---|---|---|
| គណៈគ្រប់គ្រងសាលា | ២ នាក់ | - |
| លោកគ្រូ-អ្នកគ្រូបង្រៀនថ្នាក់ទី៧,៨,៩,១០ | ២២នាក់ | ១៥នាក់ |
| សិស្សថ្នាក់ទី៧ | ៥នាក់ | ៣នាក់ |
| សិស្សថ្នាក់ទី៨ | ៥នាក់ | ៣នាក់ |
| សិស្សថ្នាក់ទី៩ | ២៤នាក់ | ១៦នាក់ |
| **សរុប** | **៥៨នាក់** | **៣៧នាក់** |

## ៣.៥. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែប បរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធ ទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទភាគសំណាកនីមួយៗ (គ្រូបង្រៀន និង សិស្ស)។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅលើលទ្ធផលសិក្សា

របស់សិស្ស គុណវុឌ្ឍិគ្រូបង្រៀន កម្មវិធីសិក្សា សម្ភារៈទ្រទ្រង់ការបង្រៀន និងរៀន វិធីសាស្ត្របង្រៀន ការរៀបចំមេរៀន បរិមាណសិស្សក្នុងថ្នាក់ និងស្ថានភាពនៃការសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់សង់ក្រាប តារាង និងបកស្រាយព័ត៌មាន។ ការវិភាគបែបគុណវិស័យវិញ ជាការប្រមូលផ្តុំគំនិតទស្សនៈនៃការយល់ឃើញនានារបស់អ្នកផ្តល់បទសម្ភាសន៍ ដោយចាប់បញ្ចូលនូវចំណុចដែលដូច ឬប្រហាក់ប្រហែលគ្នា ដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រ ចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរចំពោះ ចំណុចដែលខ្វះខាត និងកែលម្អបន្ថែមនូវចំណុចខ្វះខាតទាំងនោះឲ្យបានប្រសើរឡើង។

## ៣.៦. ក្រមសីលធម៌នៃអ្នកស្រាវជ្រាវ

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ពិតជាមានសារៈសំខាន់ណាស់ ព្រោះដើម្បីធានាប្រសិទ្ធភាពនៃការស្រាវជ្រាវ ក៏ដូចជាការបង្កើននូវការយកចិត្តទុកដាក់ និងការជឿជាក់សម្រាប់អ្នកចូលរួមក្នុងការផ្តល់ចម្លើយ ក៏ដូចជាទិន្នន័យផ្សេងៗសម្រាប់ការប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ ការដែលព្រមព្រាងគ្នារវាងអ្នកដែលផ្តល់ចម្លើយ និងអ្នកដែលស្វែងរកព័ត៌មានច្បាស់លាស់ និងមានប្រសិទ្ធភាព ហើយអាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគឲ្យបានស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបាន រក្សាទុកជាការសំងាត់ លើកលែងតែឈ្មោះសាលារៀនដែលត្រូវបង្ហាញ ប៉ុន្តែក៏មានការឯកភាពពីនាយកសាលា គោលដៅនីមួយៗផងដែរ។ អ្នកស្រាវជ្រាវបាននាំយកនូវលិខិតសុំការអនុញ្ញាតទៅជាមួយ ហើយសុំការអនុញ្ញាត ពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលពួកគេបំពេញកម្រងសំណួរ និងផ្តល់បទសម្ភាសន៍។ ការធ្វើបែបនេះមានន័យថា អ្នកផ្តល់ចម្លើយយល់ពីគោលបំណងនៃការស្រាវជ្រាវជាមុន ហើយអ្នកសិក្សាស្រាវជ្រាវក៏រំពឹងថានឹងទទួលបានចម្លើយ ឬព័ត៌មានពិប្រាកដផងដែរ។ ការធ្វើដូច្នេះ ធ្វើឲ្យអ្នកស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងពិតបញ្ជាក់អំពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូកទី៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញបកស្រាយ និងការវិភាគទិន្នន័យដែលបានមកពីលទ្ធផលសិក្សារបស់សិស្សឆមាសទី១ ឆ្នាំ២០១៨-២០១៩ និងឆ្នាំ២០១៩-២០២០ យកមកប្រៀបធៀប ព្រមទាំងទិន្នន័យដែលបានមកពីកម្រងសំណួរ ដើម្បីឲ្យដឹងអំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) ដែលបានជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលសម្រាប់ពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគតផងដែរ។

## ៤.១ លទ្ធផលនៃការស្រាវជ្រាវសំណួរទី១៖ តើមានភាពខុសគ្នាដូចម្ដេច រវាងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាចាស់(២០១៨-២០១៩) និងលទ្ធផលសិក្សារបស់សិស្សនៅឆ្នាំសិក្សាថ្មី(២០១៩-២០២០) ក្រោយពេលអនុវត្តកម្មវិធីកំណែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP)។

ក្នុងជំពូកទី៤ នេះបង្ហាញអំពីលទ្ធផលសិក្សារបស់សិស្សឆមាសទី១ ថ្នាក់ទី៧ ឆ្នាំ២០១៨-២០១៩(ឆ្នាំចាស់) និងលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៧ និងទី៨ ឆ្នាំ២០១៩-២០២០(ឆ្នាំថ្មី) ព្រមទាំងបង្ហាញអំពីព័ត៌មានទូទៅរបស់អ្នកចូលរួមទាំងអស់ដែលមាននាយកសាលា១នាក់(ប្រុស) នាយករង ១នាក់ និងលោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ចំនួន ២២ នាក់ ស្រី ១៥ នាក់ និងសិស្សានុសិស្សចំនួន ៣៤ នាក់ ស្រី ២២ នាក់ ។ តារាងខាងក្រោមនេះ ជាលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៧ នៅឆមាសទី១ ឆ្នាំ២០១៨-២០១៩ និងលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៧ និងទី៨ ឆមាសទី១ ឆ្នាំ២០១៩-២០២០។

**តារាងទី២.ការប្រៀបលទ្ធផលសិក្សា មធ្យម គម្លាតស្តង់ដា របស់សិស្សឆមាសទី១ ថ្នាក់ទី៧(២០១៨-២០១៩) និងលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៨(២០១៩-២០២០)**

| មុខវិជ្ជា | លទ្ធផលសិក្សា | | | | | |
|---|---|---|---|---|---|---|
| | ថ្នាក់ទី៧ | | ថ្នាក់ទី៨ | | ថ្នាក់ទី៧ | |
| | ឆ្នាំ២០១៨-២០១៩ | | ឆ្នាំ២០១៩-២០២០ | | ឆ្នាំ២០១៩-២០២០ | |
| | មធ្យម | គម្លាតស្តង់ដា | មធ្យម | គម្លាតស្តង់ដា | មធ្យម | គម្លាតស្តង់ដា |
| តែងសេចក្តី | 18.52 | 13.77 | 27.98 | 15.50 | 33.44 | 15.39 |
| សរសេរតាមអាន | 22.41 | 9.15 | 24.48 | 10.56 | 24.58 | 10.67 |
| សីលធម៌ | 27.41 | 11.43 | 35.66 | 14.40 | 34.21 | 18.77 |
| ភូមិវិទ្យា | 20.04 | 13.77 | 30.24 | 15.87 | 23.05 | 18.24 |
| ប្រវត្តិវិទ្យា | 25.90 | 10.80 | 24.78 | 12.96 | 23.66 | 10.88 |
| គណិតវិទ្យា | 25.37 | 19.82 | 44.60 | 24.31 | 39.57 | 25.52 |
| ផែនដីវិទ្យា | 15.50 | 7.78 | 32.86 | 15.77 | 38.51 | 38.87 |
| រូបវិទ្យា | 15.06 | 11.28 | 22.07 | 15.27 | 22.89 | 15.77 |
| គីមីវិទ្យា | 30.16 | 8.96 | 24.06 | 12.75 | 25.51 | 12.81 |
| ជីវវិទ្យា | 29.29 | 9.40 | 29.73 | 15.02 | 31.48 | 16.05 |
| អង់គ្លេស | 20.09 | 13.47 | 23.28 | 13.39 | 25.99 | 13.18 |

ក្រាបទី១៖ ការប្រៀបធៀបមធ្យមតាមមុខវិជ្ជានីមួយៗរបស់សិស្សនៅឆមាសទី១ ថ្នាក់ទី៧(២០១៧-២០១៩) និងថ្នាក់ទី៨ (២០១៩-២០២០)




តាមទិន្នន័យក្នុងខាងបង្ហាញឲ្យឃើញថា លទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) ដែលបានឆ្លងកាត់ការធ្វើតេស្តស្តង់ដាប្រចាំខែ តាមរយៈគម្រោងSEIP ត្រូវបានឡើងថ្នាក់ទី៨(២០១៩-២០២០) ដោយផ្អែកលើតារាងទិន្នន័យខាងលើ អ្នកស្រាវជ្រាវសង្កេតឃើញថា មធ្យមពិន្ទុតាមមុខវិជ្ជានីមួយៗភាគច្រើនមានការកើនឡើងគួរឲ្យកត់សំគាល់ដូចខាងក្រោម៖

- មធ្យមពិន្ទុតែងសេចក្តីមានការកើនពី ១៨.៨២ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ២៧.៩៨ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុសរសេរតាមអានមានការកើនពី ២២.៤១ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ២៤.៤៨ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុសីលធម៌កើនពី ២៧.៤១ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ៣៥.៦៦ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុភូមិវិទ្យាកើនពី ២០.០៤ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ៣០.២៤ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។

- មធ្យមពិន្ទុប្រវត្តិវិទ្យាមានការថយចុះពី ២៥.៩០ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ មធ្យមពិន្ទុ ២៤.៧៨ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុគណិតវិទ្យាពី ២៥.៣៧ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ៤៤.៦០ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុផែនដីវិទ្យាកើនពី ១៥.៥០ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ៣២.៨៦ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុរូបវិទ្យាកើនពី ១៥.០៦ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ២២.០៧ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុគីមីវិទ្យាមានការថយចុះពី ៣០.១៦ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ មធ្យមពិន្ទុ ២៤.០៦ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុជីវវិទ្យាកើនពី ២៩.២៩ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ២៩.៧៣ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។
- មធ្យមពិន្ទុភាសាអង់គ្លេសកើនពី ២០.០៩ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅមធ្យមពិន្ទុ ២៣.២៨ សម្រាប់ថ្នាក់ទី៨(២០១៩-២០២០)។

សរុបជាមួយ តាមរយៈទិន្នន័យខាងលើយើងឃើញថា មធ្យមពិន្ទុរបស់សិស្សទាំងពីរកម្រិតនេះ មានការកើនឡើងស្ទើរគ្រប់មុខវិជ្ជា មានន័យថាសិស្សានុសិស្ស មានស្មារតីឧស្សាព្យាយាមរៀនសូត្របានច្រើនជាងមុនបន្ទាប់ពីបានអនុវត្តគម្រោងកែលម្អគុណភាពអប់រំ(SEIP) ហើយក៏បង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូដែលបានខិតខំបំពេញការងារបានល្អ ទើបធ្វើឲ្យលទ្ធផលសិក្សារបស់សិស្សទទួលបានផលល្អ ហើយក៏បង្ហាញឲ្យឃើញផងដែរអំពីការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) នៃវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាពជាងពេលមុន។

ប៉ុន្តែទន្ទឹមនឹងនោះផងដែរ ចំពោះមុខវិជ្ជាប្រវត្តិវិទ្យា មធ្យមពិន្ទុថ្នាក់ទី៧(២០១៨-២០១៩) គឺ២៥.៩០ ចំណែកឯមធ្យមពិន្ទុថ្នាក់ទី៨(២០១៩-២០២០) គឺ២៤.៧៨ និងមុខវិជ្ជាគីមីវិទ្យាមានមធ្យមពិន្ទុថ្នាក់ទី៧(២០១៨-២០១៩) គឺ៣០.១៦ ចំណែកឯមធ្យមពិន្ទុថ្នាក់ទី៨(២០១៩-២០២០) គឺ២៤.០៦ ដូច្នេះមុខវិជ្ជាទាំងពីរខាងលើនេះមានការថយចុះមធ្យមពិន្ទុ។ អ្នកស្រាវជ្រាវយល់ឃើញថាការធ្លាក់ចុះនេះ អាចបណ្តាលមកពីការធ្វើវិញ្ញាសាតេស្ត ឬអាចមកពីការកែសន្លឹកកិច្ចការសិស្ស និងអាចមកពីមូលហេតុសិស្សអវត្តមានក្នុងពេលប្រឡងប្រចាំខែជាដើម។

ម្យ៉ាងវិញទៀត ហេតុផលដែលអ្នកស្រាវជ្រាវជ្រើសរើសការប្រៀបធៀបថ្នាក់ទី៧(២០១៨-២០១៩) ជាមួយថ្នាក់ទី៨(២០១៩-២០២០) ព្រោះសិស្សទាំងពីកម្រិតនេះ ជាសិស្សដដែល ដែលបានឆ្លងកាត់ការធ្វើតេស្តជាប់ និងត្រូវបានឡើងថ្នាក់ទី៨(២០១៩-២០២០)។ ទាំងនេះបង្ហាញឲ្យឃើញពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅ មធ្យមសិក្សា(SEIP) ដែលជួយដល់ការរៀន និងបង្រៀននៃវិទ្យាល័យបវេល។

**ក្រាបទី២៖ ការប្រៀបធៀបមធ្យមសរុប(គ្រប់មុខវិជ្ជា)របស់សិស្សនៅឆមាសទី១ ថ្នាក់ទី៧(២០១៧-២០១៩) និងថ្នាក់ទី៨ (២០១៩-២០២០)**



តាមក្រាបទី២ខាងលើនេះ អ្នកស្រាវជ្រាវសង្កេតឃើញថាមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) **គឺ ១៦.៦២** និងមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៨(២០១៩-២០២០) **គឺ ២៦.៦៥ ។** តាមរយៈទិន្នន័យនេះ សិស្សទាំងពីរកម្រិតថ្នាក់នេះ ជាសិស្សដដែល និងបានឆ្លងកាត់ការធ្វើតេស្តស្តង់ដារាល់ខែ ហើយលទ្ធផលមធ្យមរបស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) ទាបជាងលទ្ធផលមធ្យមរបស់សិស្សថ្នាក់ទី៨(២០១៩-២០២០)។ ដូច្នេះ អ្នកស្រាវជ្រាវយល់ថា ការអនុវត្តគម្រោងSEIP នៅឆ្នាំ២០១៨-២០១៩ មិនទាន់បានល្អនៅឡើយ ដោយសារការតាក់តែងវិញ្ញាសាតេស្តស្តង់ដាប្រចាំខែរបស់លោកគ្រូ អ្នកគ្រូ នៅមានកម្រិតនៅឡើយ ម្យ៉ាងទៀតអាចមកពីការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមិនទាន់ស៊ីជម្រៅទៅលើមេរៀន ជាពិសេសមុខវិជ្ជាមួយដែលមានគ្រូបង្រៀនតែម្នាក់ ធ្វើឲ្យពិបាកក្នុងការធ្វើការវាយតម្លៃទៅលើសមត្ថភាពរបស់សិស្សច្រើនថ្នាក់បាន រីឯសិស្សក៏មិនទាន់បានរៀបចំឥរិយាបថក្នុងការប្រឡងប្រចាំខែជាលក្ខណៈស្តង់ដានៅឡើយ និងមិនសូវខិតខំរៀនសូត្រ ដូច្នេះហើយបានជាលទ្ធផលមធ្យមសរុបឆមាសទី១ សម្រាប់សិស្សថ្នាក់ទី៧(២០១៨-២០១៩)នៅទាប**គឺ១៦.៦២។** ចំណែកឯ សិស្សថ្នាក់ទី៨(២០១៩-២០២០)**គឺ ២៦.៦៥** មានមធ្យមសរុបខ្ពស់ជាងថ្នាក់ទី៧(២០១៨-២០១៩) ដោយសារសិស្សនេះគឺជាសិស្សឆ្នាំចាស់ដដែល ដែលបានឡើងថ្នាក់ទី៨ ហើយពួកគាត់បានយល់ច្បាស់អំពីការប្រឡងស្តង់ដាប្រចាំខែ និងមានការខិតខំរៀនសូត្រ មានការស្វ័យសិក្សាល្អជាងមុន ចំណែកលោកគ្រូ អ្នកគ្រូក៏មានការកែប្រែឥរិយាបថក្នុងការបង្រៀនឲ្យបានល្អ បង្រៀនដោយមានកិច្ចតែងការ និងយកចិត្តទុកដាក់ទៅលើការសិក្សារបស់សិស្ស ហើយមានការតាក់តែងវិញ្ញាសាតេស្តស្តង់ដាយ៉ាងមានប្រសិទ្ធជាងពេលមុនៗ និងចេះវាស់ពីសមត្ថភាពសិស្សដែលរៀនថ្នាក់ខុសគ្នា លោកគ្រូ អ្នកគ្រូ មានការសហការគ្នាល្អជាមួយគ្រូបង្រៀនដូចគ្នា និងជាមួយគណៈគ្រប់គ្រងក្នុងការរៀបចំសិស្សធ្វើតេស្តជារៀងរាល់ខែបានយ៉ាងល្អ ដូច្នេះហើយបានជាការសិក្សារបស់សិស្សថ្នាក់ទី៨(២០១៩-២០២០)ទទួលបានមធ្យមខ្ពស់គឺ

២៦.៦៥។ ទាំងនេះបង្ហាញឲ្យឃើញថា ការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP)ដែល

បានជួយដល់ការបង្រៀន និងការរៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាពជាមុនពីមួយឆ្នាំទៅមួយឆ្នាំ។

**តារាងទី៣. ការប្រៀបលទ្ធផលសិក្សា មធ្យម គម្លាតស្តង់ដា របស់សិស្សឆមាសទី១ ថ្នាក់ទី៧ (២០១៨-២០១៩)និងលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៧(២០១៩-២០២០)**

| មុខវិជ្ជា | លទ្ធផលសិក្សា | | | | | |
|---|---|---|---|---|---|---|
| | ថ្នាក់ទី៧ | | ថ្នាក់ទី៨ | | ថ្នាក់ទី៧ | |
| | ឆ្នាំ២០១៨-២០១៩ | | ឆ្នាំ២០១៩-២០២០ | | ឆ្នាំ២០១៩-២០២០ | |
| | មធ្យម | គម្លាតស្តង់ដា | មធ្យម | គម្លាតស្តង់ដា | មធ្យម | គម្លាតស្តង់ដា |
| តែងសេចក្តី | 18.52 | 13.77 | 27.98 | 15.50 | 33.44 | 15.39 |
| សរសេរតាមអាន | 22.41 | 9.15 | 24.48 | 10.56 | 24.58 | 10.67 |
| សីលធម៌ | 27.41 | 11.43 | 35.66 | 14.40 | 34.21 | 18.77 |
| ភូមិវិទ្យា | 20.04 | 13.77 | 30.24 | 15.87 | 23.05 | 18.24 |
| ប្រវត្តិវិទ្យា | 25.90 | 10.80 | 24.78 | 12.96 | 23.66 | 10.88 |
| គណិតវិទ្យា | 25.37 | 19.82 | 44.60 | 24.31 | 39.57 | 25.52 |
| ផែនដីវិទ្យា | 15.50 | 7.78 | 32.86 | 15.77 | 38.51 | 38.87 |
| រូបវិទ្យា | 15.06 | 11.28 | 22.07 | 15.27 | 22.89 | 15.77 |
| គីមីវិទ្យា | 30.16 | 8.96 | 24.06 | 12.75 | 25.51 | 12.81 |
| ជីវវិទ្យា | 29.29 | 9.40 | 29.73 | 15.02 | 31.48 | 16.05 |
| អង់គ្លេស | 20.09 | 13.47 | 23.28 | 13.39 | 25.99 | 13.18 |

**ក្រាបទី៣៖ ការប្រៀបធៀបមធ្យមតាមមុខវិជ្ជានីមួយៗរបស់សិស្ស ឆមាសទី១ ថ្នាក់ទី៧(២០១៨-២០១៩) និងថ្នាក់ទី៧(២០១៩-២០២០)**




ដោយយោងតាមតារាងទិន្នន័យខាងលើ អ្នកស្រាវជ្រាវសង្កេតឃើញថាលទ្ធផលសិក្សារបស់សិស្សពីមួយឆ្នាំទៅមួយឆ្នាំ មានការកើនឡើងនូវមធ្យមពិន្ទុ ស្ទើរគ្រប់មុខវិជ្ជាដែលបានបង្ហាញដូចខាងក្រោម៖

- មុខវិជ្ជាតែងសេចក្ដីថ្នាក់ទីព(២០១៨-២០១៩) មានមធ្យមពិន្ទុ គឺ១៨.៥២ រីឯតែងសេចក្ដីថ្នាក់ទីព(២០១៩-២០២០) មានមធ្យមពិន្ទុ គឺ៣៣.៤៤ ។
- សរសេរតាមអាន មានមធ្យមពិន្ទុកើនពី ២២.៤១ សម្រាប់ថ្នាក់ទីព(២០១៨-២០១៩) ទៅ ២៤.៨ សម្រាប់ថ្នាក់ទីព(២០១៩-២០២០)។
- សីលធម៌ មានមធ្យមពិន្ទុកើនពី ២៧.៤១ សម្រាប់ថ្នាក់ទីព(២០១៨-២០១៩) ទៅ ៣៤.២១ សម្រាប់ថ្នាក់ទីព(២០១៩-២០២០)។
- ភូមិវិទ្យា មានមធ្យមពិន្ទុកើនពី ២០.០៤ សម្រាប់ថ្នាក់ទីព(២០១៨-២០១៩) ទៅ ២៣.០៥ សម្រាប់ថ្នាក់ទីព(២០១៩-២០២០)។
- ប្រវត្តិវិទ្យា បែរជាមានការធ្លាក់ចុះមធ្យមពិន្ទុពី ២៥.៩០ សម្រាប់ថ្នាក់ទីព(២០១៨-២០១៩) ទៅ ២៣.៦៦ សម្រាប់ថ្នាក់ទីព(២០១៩-២០២០)។

- គណិតវិទ្យា មានមធ្យមពិន្ទុកើនពី ២៥.៣៧ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ ៣៩.៥៧ សម្រាប់ថ្នាក់ទី៧(២០១៩-២០២០)។
- ផែនដីវិទ្យា មានមធ្យមពិន្ទុកើនពី ១៥.៥០ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ ៣៩.៥១ សម្រាប់ថ្នាក់ទី៧(២០១៩-២០២០)។
- រូបវិទ្យា មានមធ្យមពិន្ទុកើនពី ១៥.០៦ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ ២២.៨៩ សម្រាប់ថ្នាក់ទី៧(២០១៩-២០២០)។
- គីមីវិទ្យា បែជាមានការធ្លាក់ចុះមធ្យមពិន្ទុពី ៣០.១៦ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ ២៥.៥១ សម្រាប់ថ្នាក់ទី៧(២០១៩-២០២០)។
- ជីវវិទ្យា មានមធ្យមពិន្ទុកើនពី ២៩.២៩ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ ៣១.៤៨ សម្រាប់ថ្នាក់ទី៧(២០១៩-២០២០)។
- ភាសាអង់គ្លេស មានមធ្យមពិន្ទុកើនពី ២០.០៩ សម្រាប់ថ្នាក់ទី៧(២០១៨-២០១៩) ទៅ ២៥.៩៩ សម្រាប់ថ្នាក់ទី៧(២០១៩-២០២០)។

តាមទិន្នន័យខាងលើបានបញ្ជាក់ថា ការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP) ដែលជួយដល់ការរៀន និងបង្រៀននៃវិទ្យាល័យបវេលពិតជាមានប្រសិទ្ធភាព ព្រោះយើងឃើញថាតាមរយៈ លទ្ធផលសិក្សារបស់សិស្សពីមួយឆ្នាំទៅមួយឆ្នាំមានការកើនមធ្យមពិន្ទុ នេះបញ្ជាក់ថាសិស្សបានត្រៀមខ្លួន និងមានស្មារតីយកចិត្តទុកដាក់ក្នុងការរៀនសូត្រច្រើនជាងមុន ហើយលោកគ្រូអ្នកគ្រូក៏មានការយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្សបានល្អជាងមុន។ លើកលែងមុខវិជ្ជាប្រវត្តិវិទ្យាថ្នាក់ទី៧(២០១៨ -២០១៩) មានមធ្យមពិន្ទុគឺ២៥.៩០ ឯថ្នាក់ទី៧(២០១៩-២០២០) មានមធ្យមពិន្ទុគឺ ២៣.៦៦ និងមុខវិជ្ជាគីមីវិទ្យា សម្រាប់ថ្នាក់ទី៧(២០១៨ -២០១៩) មានមធ្យមពិន្ទុគឺ៣០.១៦ ឯថ្នាក់ទី៧(២០១៩-២០២០) មានមធ្យមពិន្ទុគឺ ២៥.៥១។ ការថយចុះនៃមធ្យមពិន្ទុរវាងថ្នាក់ទី៧(២០១៨-២០១៩) និងថ្នាក់ទី៧(២០១៩-២០២០) អាចមកពីកំហុសបច្ចេកទេសក្នុងការធ្វើវិញ្ញាសាតេស្ត និងអាចមកពីមានសិស្សអវត្តមានច្រើនក្នុងពេលប្រឡងតេស្តប្រចាំខែជាដើម។

**ក្រាបទី៤៖ ការប្រៀបធៀបមធ្យមសរុប(គ្រប់មុខវិជ្ជា) របស់សិស្សនៅឆមាសទី១ ថ្នាក់ទី៧(២០១៨-២០១៩) និងថ្នាក់ទី៧(២០១៩-២០២០)**




តាមរយៈក្រាបទី៤ខាងលើនេះ បង្ហាញថាលទ្ធផលមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៨-២០១៩)**គឺ១៦.៦២** និងមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៩-២០២០)**គឺ២២.៧០** ។ តាមលទ្ធផលខាងលើនេះ ត្បិតថាសិស្សទាំងពីរកម្រិតមានកម្រិតដូចគ្នា ប៉ុន្តែឆ្នាំសិក្សារបស់ពួកគាត់ខុសគ្នា អ្នកស្រាវជ្រាវយល់ថា ការអនុវត្តគម្រោង SEIP នៅវិទ្យាល័យបវេល មានប្រសិទ្ធភាពពីមួយឆ្នាំទៅមួយឆ្នាំ ព្រោះកាលណាលទ្ធផលសិក្សារបស់សិស្សដែលបានឆ្លងកាត់ការប្រឡងស្តង់ដា ដែលមានការរៀបចំពីសាលារៀនមានលក្ខណៈតឹងរឹង សមធម៌ និងមានតម្លាភាព ហើយទិន្នន័យនេះក៏បង្ហាញឲ្យឃើញពីការខិតខំរៀនសូត្ររបស់សិស្ស និងការបង្រៀនយ៉ាងយកចិត្តទុកដាក់របស់លោកគ្រូ អ្នកគ្រូបានស៊ីជម្រៅទៅតាមមេរៀននីមួយៗ ដែលធ្វើឲ្យសិស្សអាចធ្វើកិច្ចការនោះបានល្អ ជាពិសេសការរៀបចំការប្រឡងប្រចាំខែមានលក្ខណៈតឹងរឹងច្បាស់លាស់ និងបង្ហាញអំពីកិច្ចសហការរវាងគណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូក្នុងការបំពេញការងារបានល្អប្រសើរ ទើប

ធ្វើឲ្យលទ្ធផលសិក្សារបស់សិស្សកើនខ្ពស់។ ទាំងនេះបញ្ជាក់ថា ការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP ) ដែលបានជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលមានប្រសិទ្ធភាព។

**ក្រាបទី៥. ការប្រៀបធៀបគម្លាតស្តង់ដាតាមមុខវិជ្ជានីមួយៗនៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧ (២០១៨-២០១៩) និងសិស្សថ្នាក់ទី៨(២០១៩-២០២០)**




តាមក្រាបខាងលើ **(សិស្សដដែល ប៉ុន្តែកម្រិតថ្នាក់ខុសគ្នា)** បង្ហាញអំពីគម្លាតស្តង់ដាគ្រប់មុខវិជ្ជានៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧ (២០១៨-២០១៩) និងសិស្សថ្នាក់ទី៨(២០១៩-២០២០) ដូចខាងក្រោម៖

- តែងសេចក្តីថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១៣.៧៧ ឯថ្នាក់ទី៨ (២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៥.៥០។
- សរសេរតាមអានថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ៩.១៥ ឯថ្នាក់ទី៨ (២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១០.៥៧ ។
- សីលធម៌ថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ១១.៤៣ ឯថ្នាក់ទី៨(២០១៩-២០២០)មាន គម្លាតស្តង់ដា គឺ១៤.៤០ ។

- ភូមិវិទ្យាថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ១៣.៧៧ ឯថ្នាក់ទី៨(២០១៩-២០២០)មានគម្លាតស្តង់ដា គឺ១៥.៨៧។
- ប្រវត្តិវិទ្យាថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ១០.៨០ ឯថ្នាក់ទី៨(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១២.៩៦។
- គណិតវិទ្យាថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ១៩.៨២ ឯថ្នាក់ទី៨(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ២៤.៣១។
- ផែនដីវិទ្យាថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ៧.៧៨ ឯថ្នាក់ទី៨(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៥.៧៧។
- រូបវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១១.២៨ ឯថ្នាក់ទី៨(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៥.២៧។
- គីមីវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ៨.៩៦ ឯថ្នាក់ទី៨(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១២.៧៥។
- ជីវវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ៩.៤០ ឯថ្នាក់ទី៨(២០១៩-២០២០) មានមធ្យមពិន្ទុ គឺ១៥.០២។
- អង់គ្លេសថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១៣.៤៧ ឯថ្នាក់ទី៨(២០១៩-២០២០) មានមធ្យមពិន្ទុ គឺ១៣.៣៧។

តាមទិន្នន័យខាងលើនេះបញ្ជាក់ថា ការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលពិតជាមានប្រសិទ្ធ ពីព្រោះគម្លាតស្តង់ដាតាមមុខវិជ្ជានីមួយៗមានការកើនឡើងស្ទើគ្រប់មុខវិជ្ជា លើកលែងភាសាអង់គ្លេស។ មានន័យថារាល់ការប្រឡងប្រចាំខែគឺមានការរិតបន្តឹងយ៉ាងតឹងរឹង និងម៉ត់ចត់ ហើយសិស្សមិនអាចចម្លងគ្នា ឬសួរគ្នាបានពេលប្រឡង ដូច្នេះសិស្សមានការប្រឹងប្រែងរៀនសូត្រជាងមុខ ហើយក៏បង្ហាញឲ្យឃើញថាលោកគ្រូ

អ្នកគ្រូមានការខិតខំប្រឹងប្រែងក្នុងការបង្រៀនសិស្សយ៉ាងយកចិត្តទុកដាក់ ក៏ដូចជាការស្រាវជ្រាវរកវិធីសាស្ត្រថ្មីសម្រាប់ផ្ដល់ទៅដល់សិស្សបន្ថែមទៀត។

**ក្រាបទី៦.ការប្រៀបធៀបគម្លាតស្តង់ដាសរុបគ្រប់មុខវិជ្ជានៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧(២០១៨-២០១៩) និងសិស្សថ្នាក់ទី៨(២០១៩-២០២០)**




តាមក្រាបទី៦នេះ (**សិស្សដដែល ប៉ុន្តែនកម្រិតថ្នាក់ខុសគ្នា**) បង្ហាញអំពីការប្រៀបធៀបគម្លាតស្តង់ដាសរុប នៅឆមាសទី១ សម្រាប់សិស្ស ថ្នាក់ទី៧(២០១៨-២០១៩)គឺ៩.៣៥ ឯសិស្សថ្នាក់ទី៨(២០១៩-២០២០)មានគម្លាតស្តង់ដាសរុបគឺ ១២.០៨។ យើងឃើញថា គម្លាតស្តង់ដាសរុបមានការកើនឡើង នេះបង្ហាញឲ្យឃើញថាប្រសិទ្ធភាពនៃការប្រឡងប្រចាំខែឬឆមាសកាន់តែតឹងរឹង និងច្បាស់លាស់ នោះធ្វើឲ្យមានគម្លាតស្តង់ដាកាន់តែធំដែរ មានន័យថាសិស្សពិតជាបានបញ្ចេញសមត្ថភាពផ្ទាល់ខ្លួន មិនអាចចម្លងគ្នាបាន ឬសួរគ្នាបាន។ ទាំងនេះបញ្ជាក់ថា ការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលបានជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលពិតជាមានប្រសិទ្ធភាព។

ក្រាបទី៧. **ការប្រៀបធៀបគម្លាតស្តង់ដាតាមមុខវិជ្ជានីមួយៗនៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧(២០១៨-២០១៩) និងសិស្សថ្នាក់ទី៧(២០១៩-២០២០)**




តាមក្រាបខាងលើ **(សិស្សផ្សេងគ្នា ប៉ុន្តែកម្រិតថ្នាក់ដូចគ្នា)** បង្ហាញអំពីគម្លាតស្តង់ដាគ្រប់មុខវិជ្ជានៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧ (២០១៨-២០១៩) និងសិស្សថ្នាក់ទី៧(២០១៩-២០២០) ដូចខាងក្រោម៖

- តែងសេចក្តីថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដាគឺ១៣.៧៧ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៥.៣៩។
- សរសេរតាមអានថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ៩.១៥ ឯថ្នាក់ទី៧(២០១៩-២០២០)មានគម្លាតស្តង់ដា គឺ១០. ៦៧។
- សីលធម៌ថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ១១.៤៣ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៨. ៧៧។
- ភូមិវិទ្យាថ្នាក់ទី៧(២០១៨-២០១៩)មានគម្លាតស្តង់ដា គឺ១៣.៧៧ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៨.២៤។

- ប្រវត្តិវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១០.៨០ ឯថ្នាក់ទី៧(២០១៩-២០២០)មានគម្លាតស្តង់ដា គឺ១០.៨៨។
- គណិតវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១៩.៨២ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ២៥.៥២។
- ផែនដីវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ៧.៧៨ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ៣៨.៨៧។
- រូបវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១១.២៨ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៥.៧៧។
- គីមីវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ៨.៩៦ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១២.៨១។
- ជីវវិទ្យាថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ៩.៤០ ឯថ្នាក់ទី៧(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៦.០៥។
- អង់គ្លេសថ្នាក់ទី៧(២០១៨-២០១៩) មានគម្លាតស្តង់ដា គឺ១៣.៤៧ ឯថ្នាក់ទី៨(២០១៩-២០២០) មានគម្លាតស្តង់ដា គឺ១៣.១៨។

យោងតាមទិន្នន័យខាងលើ យើងឃើញថាគម្លាតស្តង់ដាតាមមុខវិជ្ជានីមួយៗមានការកើនឡើងស្ទើរគ្រប់មុខមុខវិជ្ជា លើកលែងតែមុខវិជ្ជាភាសាអង់គ្លេសមានការធ្លាក់ចុះ។ ទោះបីជាយ៉ាងណាការកើនឡើងនេះ គឺបង្ហាញពីប្រសិទ្ធភាពនៃការប្រឡងប្រចាំខែ ក៏ដូចជាការប្រឡងឆមាសផងដែរ ដូច្នេះកាលណាការប្រឡងកាន់តែរឹតបន្តឹង មានន័យថាសិស្សមិនអាចចម្លងគ្នា ឬសួរគ្នាបានទេ គឺសិស្សត្រូវតែបញ្ចេញសមត្ថភាពពិតរបស់ខ្លួនក្នុងពេលប្រឡង នោះធ្វើឲ្យគម្លាតស្តង់ដាកាន់តែធំដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនក៏កាន់តែខិតខំបង្រៀន និងស្រាវជ្រាវចំណេះដឹងថ្មីៗ ព្រមទាំងវិធីសាស្ត្របង្រៀនថ្មីដើម្បីយកមកបង្រៀនសិស្សឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមផងដែរ។ ដោយឡែកចំពោះមុខវិជ្ជា

អង់គ្លេសមានការធ្លាក់ចុះនេះ អាចឲ្យអ្នកស្រាវជ្រាវបន្តយកមកសិក្សាបន្ថែម ដើម្បីស្វែងរកមូលហេតុដែលធ្វើឲ្យមានការធ្លាក់ចុះនៃគម្លាតស្តង់ដានេះ។

**ក្រាបទី៨. ការប្រៀបធៀបគម្លាតស្តង់ដាសរុបគ្រប់មុខវិជ្ជានីមួយៗនៅឆមាសទី១ រវាងសិស្សថ្នាក់ទី៧ (២០១៨-២០១៩) និងសិស្សថ្នាក់ទី៧(២០១៩-២០២០)**




តាមក្រាបខាងលើនេះ(**សិស្សផ្សេងគ្នា ប៉ុន្តែកម្រិតថ្នាក់ដូចគ្នា**) បង្ហាញពីគម្លាតស្តង់ដាសរុបឆមាសទី១ រវាងសិស្សថ្នាក់ទី៧(២០១៨-២០១៩)គឺ៩.៣៥ និងសិស្សថ្នាក់ទី៧(២០១៩-២០២០)គឺ១២.៤៩។ យោងតាមទិន្នន័យនេះ យើងឃើញថាគម្លាតស្តង់ដាសរុបគ្រប់មុខវិជ្ជាមានការកើនឡើងបញ្ជាក់ថារាល់ការរៀន និងបង្រៀនគឺមានការរឹតបន្តឹង ជាពិសេសការប្រឡងប្រចាំខែនីមួយៗមានតម្លាភាព មានន័យថាសិស្សមិនអាចចម្លងគ្នា ឬសួរគ្នាបានទេ ហើយគ្រូបង្រៀនវិញគឺមានការបំពេញការងារបង្រៀនយ៉ាងយកចិត្តទុកដាក់ ខិតខំស្រាវជ្រាវវិធីសាស្ត្រថ្មី ចំណេះដឹងថ្មីៗសម្រាប់យកមកបង្រៀនសិស្សឲ្យកាន់តែប្រសើរថែមទៀត។ ទាំងនេះបង្ហាញឲ្យយើងឃើញពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាព។

## ៤.២ លទ្ធផលនៃការស្រាវជ្រាវសំណួរទី២៖ តើគម្រោង(SEIP) បានជះឥទ្ធិពលយ៉ាងដូចម្ដេចខ្លះ នៅលើការគ្រប់គ្រងសាលារៀន ការរៀនរបស់សិស្ស និងគ្រូបង្រៀន?

### ៤.២.១ ការសម្ភាសន៍របស់នាយក និងនាយករង

តាមការសម្ភាសន៍បង្ហាញថា លោកនាយកបានបំពេញការងារជានាយកតាំងពីឆ្នាំ២០០៦ រហូតមកដល់សព្វថ្ងៃ ពោលគឺមានរយៈពេល ១៤ឆ្នាំមកហើយ។ លោកនាយកមានក្របខណ្ឌជាគ្រូកម្រិតឧត្តម ឯកទេសគណិតវិទ្យា ហើយលោកនាយកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យបាត់ដំបង។

កិច្ចសម្ភាសន៍ជាមួយនាយករងបានបង្ហាញថា គាត់ក៏ជាគ្រូបង្រៀនកម្រិតឧត្តមឯកទេស អក្សរសាស្ត្រខ្មែរ ហើយគាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរនៅសាកលវិទ្យាល័យភ្នំពេញ ក្នុងឆ្នាំ ១៩៩៦។ លោកនាយករងបានបំពេញការងារជានាយករងតាំងពីឆ្នាំ២០០៨ ពោលគឺមានរយៈពេល ១២ មកហើយ។

លោកនាយក និងនាយករងមានប្រសាសន៍ស្រសៀងគ្នាអំពីដំណើរការគម្រោង (SEIP) ៖

- ដំបូងប្រជុំជ្រើសរើសគណៈគ្រប់គ្រងសាលាចេញពីមាតាបិតាសិស្ស ប៉ូលីស មេឃុំ និងព្រះសង្ឃ
- បន្ទាប់មកប្រជុំបោះឆ្នោតជ្រើសរើស និងណែនាំអំពីតួនាទីដែលគណៈគ្រប់គ្រងសាលាត្រូវធ្វើ។
- សិស្សដែលត្រូវឡើងថ្នាក់ពីទី៦ ឡើងទី៧ ត្រូវឆ្លងកាត់ការធ្វើតេស្តជាមុន ហើយវិញ្ញាសាតេស្តគឺភាសាខ្មែរ និងគណិតវិទ្យា ដើម្បីចង់ដឹងពីកម្រិតសមត្ថភាពសិស្សរៀនលឿន និងរៀនយឺត។
- ក្រោយពេលធ្វើតេស្តរួច និងរកឃើញលទ្ធផលសិស្សដែលរៀនយឺត ត្រូវយកពួកគាត់មកបំប៉ន ២ ទៅ ៣ ខែបន្ថែមបន្ទាប់មកធ្វើតេស្តម្តងទៀត។
- សាលារៀនបានរៀបចំកម្មវិធីសិក្សា និងវិញ្ញាសាតេស្តស្តង់ដាក្នុង ១ខែម្តង។

- លោកនាយកមានប្រសាសន៍បន្ថែមផងដែរអំពី បញ្ហាប្រឈមក្នុងសាលារៀន គឺសព្វថ្ងៃសាលារៀននៅខ្វះអគារសិក្សា ខ្វះបន្ទប់សិក្សា ខ្វះគ្រូបង្រៀន និងមានចំនួនសិស្សច្រើនតាមបន្ទប់រៀននីមួយៗ។
- ទន្ទឹមនឹងនោះលោកនាយកក៏បាន រៀបរាប់អំពីអត្ថប្រយោជន៍នៃគម្រោង (SEIP) ដែលបានជួយដល់សាលាដូចជា៖
  - សិស្ស និងគ្រូមានការផ្លាស់ប្តូរឥរិយាបថច្រើនទាំងការរៀន និងការបង្រៀន
  - មានការចូលរួមពីមាតាបិតាសិស្សបានច្រើន ព្រមទាំងអជ្ញាធរផងដែរ
  - លទ្ធផលសិក្សាសិស្សនៅកម្រិតមធ្យមនៅឡើយ
  - ចំនួនសិស្សមានការកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ
- គម្រោង (SEIP) បានផ្តល់ឱកាសដល់លោកគ្រូ អ្នកគ្រូទៅរៀនបន្តនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២ឆ្នាំ ដើម្បីបង្កើនគុណវុឌ្ឍិគ្រូបង្រៀនបន្ថែម ទៅលើឯកទេសរបស់ពួកគាត់បន្ថែម
- ចំណែកនាយក និងនាយករងក៏ត្រូវទៅសិក្សាបន្ថែមទៅលើឯកទេសផ្នែកគ្រប់គ្រងអប់រំ នៅសាកលវិទ្យាល័យវិទ្យាល័យភូមិន្ទភ្នំពេញ ២ឆ្នាំបន្ថែមដែរ និងចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗមួយចំនួនទៀតដែលស្តីអំពី ការបណ្តុះបណ្តាលនាយកសាលា (SBM)
- ម្យ៉ាងវិញទៀត លោកនាយកមានប្រសាសន៍ថា ទាំងសិស្ស និងគ្រូបង្រៀន មកសាលារៀនបានទៀងទាត់
- គ្រូបង្រៀនមានកិច្ចតែងការ មានការពង្រឹងចំណេះដឹង និងជំនាញទាក់ទងនឹងមុខវិជ្ជាកំពុងបង្រៀន
- លោកគ្រូ អ្នកគ្រូមានការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស
- សាលារៀនបានរៀបចំការបំប៉នសិស្សដែលរៀនយឺតទៅលើមុខវិជ្ជាចំនួនប្រាំគឺ ភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យាបន្ថែម។
- សាលាមានបណ្ណាល័យសម្រាប់គាំទ្រដល់ការរៀនសូត្ររបស់សិស្សបន្ថែមផងដែរ

- ❖ លោកគ្រូ អ្នកគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រមានការធ្វើពិសោធន៍ ចំណែកឯការប្រើប្រាស់សម្ភារៈឧបទេសនៅមានកម្រិតនៅឡើយ(ឧទាហរណ៍ដូចជា LCD Projector សម្រាប់បញ្ចាំងស្លាយ) ព្រោះសាលាមិនទាន់មានបំពាក់តាមបន្ទប់នៅឡើយ។
- ❖ លោកនាយក និងលោកនាយករងមានប្រសាសន៍ទៀតថា ក្រោយពេលដែលគម្រោងបានកែលម្អបរិស្ថានសាលា និងជួសជុលអគារសិក្សាចាស់ៗឡើងវិញ និងបានសាងសង់អគារថ្មីបានចំនួន ២ខ្នង ស្មើនឹង១០ បន្ទប់ បានជួយសម្រួលដល់ការលំបាកសិស្ស និងគ្រូបានមួយចំនួន។
- ❖ លោកនាយក និងនាយករង បានសំណូមពរសុំឲ្យក្រសួងអប់រំ ជួយសាងសង់អគារសិក្សាបន្ថែមសម្រាប់សិស្ស និងសុំអគារស្នាក់នៅសម្រាប់គ្រូបង្រៀន និងសិស្សដែលមកពីឆ្ងាយ។

៤.២.១ ការយល់ឃើញរបស់សិស្ស(កម្រងសំណួរ)

ក្រោយពីបានប្រមូលទិន្នន័យសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ចំនួន ៣៤នាក់ ស្រី២២នាក់ តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវនឹងយកទិន្នន័យទាំងនោះមកធ្វើការបកស្រាយពន្យល់នូវអ្វីដែលរកឃើញជាក់ស្តែងប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP) ដែលជួយដល់ការបង្រៀន និងការរៀននៅវិទ្យាល័យបរវេល តាមចំណុចសំខាន់ៗទាក់ទង នឹងចំណុចដូចជា **គុណវុឌ្ឍិគ្រូបង្រៀន កម្មវិធីសិក្សា សកម្មភាពសិស្សរៀនក្នុងថ្នាក់ បរិមាណសិស្សក្នុងថ្នាក់ ស្ថានភាពសិក្សារបស់សិស្ស** ។

៤.៣.១.១ គុណវុឌ្ឍិគ្រូបង្រៀន

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួន៣សំណួរ និងទទួលបានអ្នកចូលរួមគឺជាសិស្សថ្នាក់ទី៧ ទី៨ ទី៩ ចំនួន ៣៤នាក់ ស្រី២២នាក់។ អ្នកស្រាវជ្រាវនឹងធ្វើបកស្រាយតាមសំណួរនីមួយៗដូចខាងក្រោមៈ

១. តើលោកគ្រូ អ្នកគ្រូរបស់ប្អូនមានចំណេះដឹងកម្រិតណា?

នៅក្នុងសំណួរនេះ អ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅលើកម្រិតចំណេះដឹងរបស់គ្រូបង្រៀន តាមរយៈកម្រង សំណួរ ដែលមានអ្នកចូលរួមគឺជាសិស្សថ្នាក់ទី៧ ទី៨ និងទី៩ បានឆ្លើយចំនួន៣៤ នាក់ ហើយអ្នកដែលឆ្លើយថា ខ្លាំងណាស់មានចំនួន៣១នាក់ ស្មើនឹង៩១.២% ខ្លាំងចំនួន២នាក់ ស្មើនឹង៥.៩% និងមធ្យមចំនួន១នាក់ ស្មើនឹង២.៩%។

យោងតាមទិន្នន័យខាងលើ ចំពោះកម្រិតចំណេះដឹងរបស់គ្រូបង្រៀនដែលខ្លាំងណាស់គឺមានភាគរយច្រើនជាងគេគឺចំនួន៣១នាក់ នៃចំនួនអ្នកចូលរួម៣៤នាក់ ដែលពិតជាអាចទទួលចំណេះដឹងថ្មីពីគ្រូបង្រៀនរបស់គេ ហើយទទួលបានលទ្ធផលខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីបញ្ជាក់អំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាឲ្យកាន់ល្អថែមទៀត។

២. តើលោកគ្រូ អ្នកគ្រូដែលមានសមត្ថភាពខ្ពស់ ជួយប្អូនឲ្យធាប់យល់មេរៀនបានកម្រិតណា?

បន្ទាប់ពីធ្វើការវិភាគសំណួរទី១ រួចមក យើងធ្វើការវិភាគសំណួរទី២ ដែលសំដៅទៅលើកម្រិតសមត្ថភាព ដែលគ្រូអាចជួយឲ្យសិស្សធាប់យល់មេរៀន ដែលមានសិស្សចូលរួមឆ្លើយចំនួន៣៤នាក់ ស្រី២២នាក់ ហើយអ្នកដែលឆ្លើយថាខ្លាំងមានចំនួន១៥នាក់ ស្មើនឹង៤៤.១% ហើយកម្រិតមធ្យមមានចំនួន១៩នាក់ ស្មើនឹង៥៥.៩%។

យោងតាមលទ្ធផលខាងលើនេះ យើងសង្កេតឃើញថា ទោះជាគ្រូមានសមត្ថភាពកម្រិតមធ្យមក្នុងការ ជួយឲ្យសិស្សធាប់យល់មេរៀនក៏ដោយ ក៏លោកគ្រូ អ្នកគ្រូនៅតែខិតខំបំពេញកាតួកិច្ចរបស់ខ្លួនអស់សមត្ថភាពក្នុងការជួយសិស្ស ឲ្យសម្រេចបានលទ្ធផលដែល អាចទទួលយកបាន ដើម្បីបង្ហាញថាការអនុវត្តគម្រោងSEIP ពិតជាមានប្រសិទ្ធភាព និងសំរេចបានជោគជ័យប្រែក្លាយសាលាទៅជាសាលារៀនគំរូប្រចាំស្រុកក្នុង២ឆ្នាំទៀតខាងមុខនេះ។

៣. តើប្អូនយល់ឃើញយ៉ាងណា ចំពោះការបង្រៀនរបស់លោកគ្រូ អ្នកគ្រូរបស់ប្អូន?

នៅក្នុងសំណួរនេះ យើងសង្កេតឃើញថា ល្អណាស់ចំនួន៧នាក់ ស្មើនឹង២០.៦% ល្អមានចំនួន២៦នាក់ ស្មើនឹង៧៦.៥% និងកម្រិតមធ្យមចំនួន១នាក់ ស្មើនឹង២.៩%។

តាមទិន្នន័យខាងលើបង្ហាញថា ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានកម្រិតល្អមានចំនួន២៦នាក់ នៃចំនួន អ្នកចូលរួម៣៤នាក់ ដែលមានភាគរយខ្ពស់ជាងគេ នេះបញ្ជាក់ថាលោកគ្រូ អ្នកគ្រូបង្រៀនបានដើរតាមជំហាន ទាំង៥ក្នុងកិច្ចតែងការ និងសម្រេចគោលបំណងតាមការកំណត់ក្នុងមេរៀននីមួយៗ។

៤.៣.១.២ កម្មវិធីសិក្សា

នៅក្នុងផ្នែកកម្មវិធីសិក្សានេះ អ្នកស្រាវជ្រាវមានសំណួរចំនួន៥ គឺចាប់ពីសំណួរទី៧ ដល់សំណួរទី១១សម្រាប់ឲ្យសិស្សបំពេញៈ

៧.តើខ្លឹមសារមេរៀនក្នុងសៀវភៅពុម្ព សមស្របទៅនឹងកម្រិតសមត្ថភាពរបស់ប្អូនៗឬទេ?

ក្នុងសំណួរទី៧នេះ អ្នកស្រាវជ្រាវទទួលបានសិស្សដែលបានឆ្លើយថាខ្លឹមសារមេរៀនក្នុងសៀវភៅពុម្ព សមស្របតាមសមត្ថភាពរបស់សិស្សមានចំនួន២១នាក់ ស្មើនឹង៦១.៨% និងមានកម្រិតខ្ពស់ជាងសមត្ថភាពរបស់សិស្សមានចំនួន១៣នាក់ ស្មើនឹង៣៨.២%។ ត្រង់ចំណុចមានន័យថា សិស្សភាគច្រើនពេញចិត្តនឹងខ្លឹមសារមេរៀនក្នុសៀភៅពុម្ព ហើយវាមានលក្ខណៈងាយស្រួលយល់មេរៀន និងជួយឲ្យពួកគាត់បានរៀនបន្ថែមនៅផ្ទះ។

៨.តើប្អូនចាប់អារម្មណ៍ ដូចម្ដេចចំពោះសៀវភៅពុម្ពដែលកំពុងរៀនសព្វថ្ងៃ?

អ្នកចូលរួម បានជ្រើសរើសថាគួរឲ្យចាប់អារម្មណ៍ខ្លាំងមានចំនួន៣០នាក់ ស្មើនឹង៨៨.២% និងមិនសូវគួរ ឲ្យចាប់អារម្មណ៍ខ្លាំងមានចំនួន៤នាក់ ស្មើនឹង១១.៨%។ មានន័យថា សិស្សភាគច្រើនចាប់អារម្មណ៍ខ្លាំងជាមួយ សៀវភៅសិក្សាគោល និងធ្វើឲ្យពួកគាត់ចូលចិត្តអានសៀនភៅបន្ថែមផងដែរ។

៩. តើក្នុងមួយខែ ប្អូនត្រូវឆ្លងកាត់ការធ្វើតេស្តស្ទង់ជាប៉ុន្មានដង?

សិស្សភាគច្រើនបានឆ្លងកាត់ការធ្វើតេស្តស្ទង់ជា១ដង មានចំនួន២៥នាក់ ស្មើនឹង៧៣.៥% និងបានធ្វើតេស្តស្ទង់ជា២ដង ចំនួន១នាក់ ស្មើនឹង២.៩% ធ្វើតេស្តស្ទង់ជា៣ដង ចំនួន៧នាក់ ស្មើនឹង២០.៦% និងធ្វើតេស្តស្ទង់ជា៤ដង១នាក់ ស្មើនឹង ២.៩%។ ជាក់ស្ដែងសិស្សភាគច្រើន ពួកគាត់ត្រូវឆ្លងការធ្វើតេស្តប្រចាំខែចំនួន១ដង គ្រប់មុខវិជ្ជាទាំងអស់ និង គ្រប់កម្រិតថ្នាក់ ដោយខាងសាលាជាអ្នក

កំណត់ថ្ងៃធ្វើតេស្ត និងមានការរឹតបន្តឹងច្បាប់វិន័យក្នុងការធ្វើតេស្តរៀងរាល់១ខែម្តង។ ដោយឡែកសិស្សដែលឆ្លើយថាធ្វើច្រើនដង ឬលើសពី១ដងនោះ អាចតាមមុខវិជ្ជាខ្លះគ្រូត្រូវការ ពង្រឹងចំណេះដឹងសិស្ស ឬអាចជាកិច្ចការផ្សេងៗដែលគ្រូដាក់ឲ្យ មិនមែនជាការធ្វើតេស្តដែលគម្រោងបានកំណត់នោះទេ ប៉ុន្តែវាក៏អាចជួយជាស់តឿនសិស្សឲ្យខិតខំរៀនផងដែរ។

១០. តើប្អូនយល់យ៉ាងណា ចំពោះការធ្វើតេស្តស្តង់ដារាល់ខែនោះ?

សិស្សចំនួន២នាក់ ស្មើនឹង៥.៩% បានឆ្លើយថាការធ្វើតេស្តមានលក្ខណៈល្អណាស់ ឯសិស្សចំនួន២៦នាក់ ស្មើនឹង៧៦.៥% ឆ្លើយថាល្អ និងសិស្សចំនួន៦នាក់ ស្មើនឹង១៧.៦% បានឆ្លើយថាមធ្យម។ មានន័យថា ការធ្វើតេស្តស្តង់ដារាល់ខែមានលក្ខណៈល្អ បាន៧៦.៥% ទោះជាយ៉ាងណាក៏ដោយការធ្វើតេស្តប្រចាំខែនេះ នៅតែបន្តកែលម្អជារៀងរាល់ខែ ដើម្បីធានាថាការអនុវត្តគម្រោងSEIP ដែលជួយដល់ការរៀន និងបង្រៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាពថែមទៀត និងបានលទ្ធផលខ្ពស់ផងដែរ។

១១. តើគម្រោងSEIP នេះ បានជួយដល់ការសិក្សារបស់ប្អូនៗកម្រិតណាដែរ?

សិស្ស១នាក់ ស្មើនឹង២.៩% បានឆ្លើយថាគម្រោងSEIP បានជួយដល់ការសិក្សារបស់ខ្លាំងណាស់ សិស្ស១៧នាក់ ស្មើនឹង៥០% ឆ្លើយថាបានជួយដល់ការសិក្សារបស់សិស្សខ្លាំង និងសិស្ស១៦នាក់ ស្មើនឹង៤៧.១% បានឆ្លើយថា បានជួយដល់ការសិក្សារបស់សិស្សកម្រិតមធ្យម។ មានន័យថាគម្រោងSEIP បានជួយដល់កាសិក្សាបស់កម្រិតខ្លាំង និងមធ្យមមានភាគយប្រហាក់ប្រហែលគ្នាក៏ដោយ យើឃើញថាសិស្សភាគច្រើនមានការប្តូរឥរិយាបថខិតខំរៀនសូត្រច្រើនជាងមុន។

### ៤.៣.១.៣ សកម្មភាពរៀនក្នុងថ្នាក់របស់សិស្ស

នៅក្នុងចំណុចនេះមាន២សំណួរ ចាប់ពីសំណួរទី១២ ដល់ទី១៣ និងមានសិស្សចូលួមចំនួន៣៤នាក់៖

១២.តើលោកគ្រូ អ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការបង្រៀនបានកម្រិតណា?

- **សិស្សធ្វើកិច្ចការម្នាក់ឯង:** សិស្សចំនួន១០នាក់ ស្មើនឹង២៩.៤% ថាធ្វើគ្រប់ពេល សិស្សចំនួន៩នាក់ ស្មើនឹង២៦.៥% ថាធ្វើញឹកញាប់ សិស្សចំនួន១១នាក់ ស្មើនឹង៣២.៤% ថាធ្វើពេលខ្លះ ហើយសិស្សចំនួន៤នាក់ ស្មើនឹង១១.៨% ថាកម្រធ្វើណាស់។
- **សិស្សធ្វើកិច្ចការជាដៃគូ:** សិស្សចំនួន០នាក់ ស្មើនឹង០% ថាធ្វើគ្រប់ពេល សិស្សចំនួន៩នាក់ ស្មើនឹង២៦.៥% ថាធ្វើញឹកញាប់ សិស្សចំនួន២១នាក់ ស្មើនឹង៦១.៨% ថាធ្វើពេលខ្លះ ហើយសិស្សចំនួន៤នាក់ ស្មើនឹង១១.៨% ថាកម្រធ្វើណាស់។
- **សិស្សធ្វើកិច្ចការជាក្រុម:** សិស្សចំនួន១នាក់ ស្មើនឹង២.៩% ថាធ្វើគ្រប់ពេល សិស្សចំនួន១០នាក់ ស្មើនឹង២៩.៤% ថាធ្វើញឹកញាប់ សិស្សចំនួន២០នាក់ ស្មើនឹង៥៨.៨% ថាធ្វើពេលខ្លះ ហើយសិស្សចំនួន២នាក់ ស្មើនឹង៥.៩% ថាកម្រធ្វើណាស់ និងសិស្សចំនួន១នាក់ ស្មើនឹង២.៩% ថាអត់សោះ។
- **សិស្សធ្វើកិច្ចការរួមគ្នា:** សិស្សចំនួន២នាក់ ស្មើនឹង៥.៩% ថាធ្វើគ្រប់ពេល សិស្សចំនួន៤នាក់ ស្មើនឹង១១.៨% ថាធ្វើញឹកញាប់ សិស្សចំនួន២៣នាក់ ស្មើនឹង៦៧.៦% ថាធ្វើពេលខ្លះ ហើយសិស្សចំនួន៣នាក់ ស្មើនឹង៨.៨% ថាកម្រធ្វើណាស់ និងសិស្សចំនួន២នាក់ ស្មើនឹង៥.៩% ថាអត់សោះ។

សរុបជារួម យើងឃើញថា ក្នុងសកម្មភាពទាំង៤នៃការសិក្សារបស់សិស្សក្នុងថ្នាក់ សិស្សចំនួន២៣នាក់ ស្មើនឹង៦៧.៦% គឺពួកគាត់ធ្វើកិច្ចការរួមគ្នានៃសិស្សសរុបក្នុងថ្នាក់ ចំណែកឯសិស្សចំនួន២១នាក់ ស្មើនឹង៦១.៨% ពេលខ្លះពួកគាត់ធ្វើកិច្ចការជាដៃគូ ហើយសិស្សចំនួន២០នាក់ ស្មើនឹង៥៨.៨% ពេលខ្លះពួកគាត់ធ្វើ ជាក្រុម និងសិស្សចំនួន១១នាក់ ស្មើនឹង៣២.៤% ពេលខ្លះពួកគាត់ធ្វើកិច្ចការម្នាក់ឯង។ មានន័យថា រាល់សកម្មភាពសិក្សារបស់សិស្សក្នុងថ្នាក់គឺមានភាពបត់បែនតាមកាលៈទេសៈនៃមេរៀន និងពេលវេលារៀន។

១៣. តើលោកគ្រូ អ្នកគ្រូបានព្យាយាមលើកទឹកចិត្តសិស្សដល់កម្រិតណានៅពេលបង្រៀន?

សិស្សចំនួន២០នាក់ ស្មើនឹង៥៨.៨% ឆ្លើយថាមានការលើកទឹកចិត្តក្នុងការសិក្សាពីគ្រូបង្រៀនគ្រប់ពេល និងសិស្សចំនួន១២នាក់ ស្មើនឹង ៣៥.៣% ឆ្លើយថាពួកគាត់តែងតែទទួលបានការលើកឹកចិត្តពីគ្រូបង្រៀនញឹកញាប់ និងសិស្សចំនួន២នាក់ ស្មើនឹង៥.៩% ថាពួកគាត់ទទួលបានការលើកទឹកចិត្តពីគ្រូបង្រៀនម្តងម្កាល។ មានន័យថា សិស្សភាគច្រើនទទួលបានការលើកទឹកចិត្តពីគ្រូក្នុងការសិក្សាគ្រប់ពេល ហើយលោកគ្រូ អ្នកគ្រូយកចិត្តទុកដាក់ដល់ការសិក្សារបស់សិស្ស ដើម្បីឲ្យមានការខិតខំប្រឹងប្រែងរៀនសូត្រទទួលបានលទ្ធផលល្អ។

៤.៣.១.៤ បរិមាណសិស្សក្នុងថ្នាក់

១៤. តើជាមធ្យម ថ្នាក់រៀនដែលលោកគ្រូ អ្នកគ្រូបង្រៀនមានសិស្សចំនួនប៉ុន្មាននាក់?

សិស្សចំនួន១នាក់ ស្មើនឹង២.៩% ថាសិស្សក្នុងថ្នាក់មានចំនួនចន្លោះពី៣០នាក់ ទៅ៤០នាក់ សិស្សចំនួន២នាក់ ស្មើនឹង២៣.៥% ថាសិស្សក្នុងថ្នាក់មានចំនួនចន្លោះពី៤១នាក់ ទៅ៤៥នាក់ សិស្សចំនួន១០នាក់ ស្មើនឹង២៩.៤% ថាសិស្សក្នុងថ្នាក់មានចំនួនចន្លោះពី៤៦នាក់ ទៅ៥០នាក់ និងសិស្សចំនួន១៥នាក់ ស្មើនឹង ៤៤.១% ថាសិស្សក្នុងថ្នាក់មានច្រើនជាង៥០នាក់។ មានន័យថាសិស្ស១៥នាក់ នៃសិស្សចូលរួម៣៤នាក់ ថាការរៀននៅថ្នាក់មានចំនួនសិស្សច្រើនជាង៥០នាក់ ដូច្នេះអាចប៉ះពាល់ដល់ការសិក្សា ការគ្រប់គ្រងថ្នាក់រៀនផងដែរ។

១៥. តើប្អូនៗយល់ថាចំនួនសិស្សច្រើនក្នុងថ្នាក់ធ្វើឲ្យជះឥទ្ធិពលអវិជ្ជមានដល់ការរៀន និងការបង្រៀនរបស់ប្អូនៗដល់កម្រិតណា?

សិស្សចំនួន៣នាក់ ស្មើនឹង៨.៨% យល់ថាការដែលសិស្សចំនួនច្រើនក្នុងថ្នាក់មានការប៉ះពាល់ដល់ការសិក្សាខ្លាំងណាស់ សិស្សចំនួន១៣នាក់ ស្មើនឹង៣៨.២% យល់ថាការដែលមានសិស្សចំនួនច្រើនក្នុងថ្នាក់មានការប៉ះពាល់ដល់ការសិក្សាខ្លាំង សិស្សចំនួន១៥នាក់ ស្មើនឹង៤៤% យល់ថាការដែលមានសិស្សចំនួនច្រើនក្នុងថ្នាក់មានការប៉ះពាល់ដល់ការសិក្សាកម្រិតមធ្យម និងសិស្សចំនួន៤នាក់ ស្មើនឹង ៥.៩% យល់ថាការដែលសិស្សមានចំនួនច្រើនក្នុងថ្នាក់មានការប៉ះពាល់ដល់ការសិក្សាតិចតួច និងសិស្សចំនួន១នាក់ ស្មើនឹង២.៩% យល់ថាការដែលមានសិស្សចំនួនច្រើនក្នុងថ្នាក់មិនមានការប៉ះ

ពាល់ដល់ការសិក្សាទេ។ មានន័យ សិស្សយល់ថាការដែលសិស្សមានចំនួនច្រើនក្នុងថ្នាក់ គឺមានការប៉ះពាល់ដល់ការសិក្សាជាមធ្យមប៉ុណ្ណោះ ទោះបីជាយ៉ាងណា បើយើងគិតអំពី គុណភាពអប់រំរបស់សិស្សក្នុងថ្នាក់ ជាមធ្យមគឺក្នុងមួយថ្នាក់ចន្លោះសិស្សពី៤០នាក់ ទៅ៤៥នាក់ប៉ុណ្ណោះនៅសាលារដ្ឋ តែតាមការជាក់ស្តែងការសិក្សារបស់សិស្សនៅវិទ្យាល័យបវេល បច្ចុប្បន្នចំនួនសិស្សក្នុងមួយថ្នាក់មាន សិស្សចន្លោះ ៤៥នាក់ ទៅ៦០នាក់ នេះគឺជាបញ្ហាដែលអាចនាំឲ្យប៉ះដល់ការរៀន និងការបង្រៀនខ្លាំងណាស់។

៤.៣.១.៥ ស្ថានភាពសិក្សារបស់សិស្ស

១៦. តើប្អូនបានប្រឹងប្រែងក្នុងការសិក្សានៅក្នុងថ្នាក់ដល់កម្រិតណា?

| សកម្មភាព | កម្រិតនៃការប្រឹងប្រែង | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ល្អណាស់ | ភាគរយ | ល្អ | ភាគរយ | បង្គួរ | ភាគរយ | មធ្យម | ភាគរយ | ខ្សោយ | ភាគរយ |
| ១.មករៀនទៀងទាត់ និងទាន់ពេលវេលា | ៥នាក់ | 14.70% | ១៨នាក់ | 52.90% | ៩នាក់ | 26.50% | ២នាក់ | 5.90% | គ្មាន | |
| ២.យកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា | ៧នាក់ | 20.60% | ១៦នាក់ | 47.10% | ៩នាក់ | 26.50% | ២នាក់ | 5.90% | គ្មាន | |
| ៣.ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូដាក់ឲ្យក្នុងថ្នាក់ | ៤នាក់ | 11.80% | ១៩នាក់ | 55.90% | ៩នាក់ | 26.50% | ២នាក់ | 5.90% | គ្មាន | |
| ៤.ធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឲ្យទៀងទាត់ | ៧នាក់ | 20.60% | ១៧នាក់ | 50.00% | ៧នាក់ | 20.60% | ៣នាក់ | 8.80% | គ្មាន | |

យោងតាមទិន្នន័យខាងលើនេះ បង្ហាញថាសិស្សដែលមានការមករៀនទៀងទាត់ និងទាន់ពេលវេលាបានល្អ មានសិស្សចូលរួមចំនួន១៨នាក់ ស្មើនឹង៥២.៩០% នៃសិស្សសរុប៣៤នាក់។ ចំណែកឯការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សាបានល្អ មានសិស្សចំនួន១៦នាក់ ស្មើនឹង៤៧.១០% ចំពោះការចូលរួមសកម្មភាពផ្សេៗ ដែលគ្រូដាក់ក្នុងថ្នាក់ មានសិស្សចំនួន១៩នាក់ ស្មើនឹង៥៥.៩០% និងការធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឲ្យទៀងទាត់ មានសិស្សចំនួន១៧នាក់ ស្មើនឹង៥០% នៃសិស្សសរុប៣៤នាក់។ យើងឃើញថា រាល់សកម្មភាពទាំងបួនខាងលើនេះ ភាគច្រើនទទួលបានភាគរយខ្ពស់ជាងគេ ដែលបញ្ជាក់ថាសិស្សមានការគោរពិន័យបានល្អ ជាពិសេស ពួកគេមានការប្រតិបត្តិតាមការណែនាំរបស់គ្រូបង្រៀនបានល្អ។

១៧. សំណួមពរទាក់ទងនឹងបញ្ហាប្រឈមនានា ចំពោះការសិក្សារបស់សិស្ស

- សុំឲ្យមានការបំពាក់កង្ហាតាមបន្ទប់រៀន ព្រោះសិស្សច្រើនក្នុងថ្នាក់ពេលខ្លះក្តៅខ្លាំងពិបាករៀន
- សុំឲ្យលោកគ្រូ អ្នកគ្រូពន្យល់បន្ថែម និងនិយាយឲ្យលឺជាងមុន និងសរសេរមេរៀនពេលកំពុង បង្រៀនផង។
- ចង់ឲ្យបើកសាលារៀនឡើងវិញ
- សុំឲ្យគ្រូខិតខំបង្រៀនបន្ថែម

៤.២.២ ការយល់ឃើញរបស់គ្រូបង្រៀន(កម្រងសំណួរ)

អ្នកស្រាវជ្រាវបានរៀបចំទម្រង់កម្រងសំណួរចំនួន៨ផ្នែក ដែលត្រូវយកមកបង្ហាញ និងបកស្រាយពន្យល់បន្ថែម ដើម្បីបញ្ជាក់បង្ហាញអំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP) ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេល ខេត្តបាត់ដំបង។

៤.២.២.១ អំពីព័ត៌មានទូទៅ

តាមរយៈការធ្វើកម្រងសំណួរ អ្នកស្រាវជ្រាវទទួលបានការឆ្លើយតបពីលោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ ចំនួន២២នាក់ ស្រី១៥ នាក់ ។

៤.២.២.២ គុណវុឌ្ឍិគ្រូបង្រៀន

នៅក្នុងងផ្នែកនេះ អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរចំនួន៧ សំណួរ ចាប់ពីសំណួរទី៦ ដល់ទី១២ នឹងយកមកបង្ហាញ និងបកស្រាយពន្យល់បន្ថែមដូចជា៖

- បង្រៀនកម្រិតមូលដ្ឋានមានចំនួន១៥នាក់ ស្មើនឹង៤៥.៥% និងគ្រូបង្រៀនកម្រិតឧត្តមមានចំនួន៥៥១២នាក់ ស្មើនឹង៥៥.៥%។
- លោកគ្រូ អ្នកគ្រូដែលមានសញ្ញាបត្រចុងក្រោយៈ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន១នាក់ ស្មើនឹង៤.៥% គ្រូដែលមានសញ្ញាបត្របរិញ្ញាបត្រចំនួន២០នាក់ ស្មើនឹង៩០.៩% និងគ្រូដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន១នាក់ ស្មើនឹង៤.៥%។

- លោកគ្រូ អ្នកគ្រូចំនួន១៥នាក់ ស្មើនឹង៦៨.២% យល់ថាគ្រូដែលមានសមត្ថភាពខ្ពស់ អាចជួយឲ្យសិស្សឆាប់ យល់មេរៀនបានខ្លាំង ឬច្រើន ប៉ុន្តែមានគ្រូចំនួន៧នាក់ ស្មើនឹង ៣១.៨% យល់ថាគ្រូដែលមានសមត្ថភាពខ្ពស់ អាចជួយឲ្យសិស្សឆាប់ យល់មេរៀនបាន ខ្លាំង ឬច្រើន នៅមានកម្រិតមធ្យមនៅឡើយ។
- ចំពោះបទពិសោធន៍បង្រៀនសិស្ស តិចជាង៥ឆ្នាំ មានចំនួន៤នាក់ ស្មើនឹង១៨.២% លោកគ្រូ អ្នកគ្រូ ដែលមានបទពិសោធន៍ចន្លោះពី៦ឆ្នាំ ទៅ១០ឆ្នាំមានចំនួន១៤នាក់ ស្មើនឹង៦៣.៦% និងគ្រូដែលមានបទពិសោធន៍បង្រៀនច្រើនជាង១៥ឆ្នាំមានចំនួន៤នាក់ ស្មើនឹង១៨.២%។
- លោកគ្រូ អ្នកគ្រូដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាក់ទងនឹង គរុកោសល្យ ឬវិធីសាស្ត្របង្រៀនលើឯកទេសរបស់ខ្លួន ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានចំនួន៨នាក់ ស្មើនឹង ៣៦.៤% និងគ្រូដែលមិនបានចូលរួមមានចំនួន១៤នាក់ ស្មើនឹង ៦៣.៦%។
- បន្ទាប់ពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាលរួច លោកគ្រូ អ្នកគ្រូដែលគាត់យល់ថាវគ្គបណ្តុះបណ្តាលមានសារៈប្រយោជន៍ដល់ការបង្រៀនរបស់ពួកគាត់ខ្លាំងណាស់មានចំនួន៥នាក់ ស្មើនឹង២៥% ហើយគ្រូដែលយល់ថាមានសារៈប្រយោជន៍ខ្លាំងចំនួន១៤នាក់ ស្មើនឹង ៧០% និងគ្រូដែលយល់ថាមានសារៈប្រយោជន៍កម្រិតមធ្យមចំនួន១នាក់ ស្មើនឹង៥% ។
- បន្ថែមពីនោះទៀត អ្វីដែលលោកគ្រូ អ្នកគ្រូត្រូវការជាចាំបាច់ ដើម្បីបង្រៀនមុខវិជ្ជារបស់ពួកគាត់មានដូចជា៖
  - **ចិត្តគរុកោសល្យ៖** មានគ្រូចំនួន៤នាក់ ស្មើនឹង២២.២% ដែលត្រូវការបំប៉នបន្ថែម ក្នុងការបង្រៀន
  - **វិធីសាស្ត្របង្រៀន៖** មានគ្រូចំនួន១៥នាក់ ស្មើនឹង៨៣.៣% ដែលត្រូវការបំប៉នវិធីសាស្ត្រថ្មី សម្រាប់យកមកបង្រៀន។

- **ពង្រឹងចំណេះដឹងមុខវិជ្ជាឯកទេស៖** មានគ្រូចំនួន១៣នាក់ ស្មើនឹង៧២.២%ដែលត្រូវការ។
- **បច្ចេកវិទ្យាព័ត៌មាន៖ICT** ៖ មានគ្រូចំនួន៦នាក់ ស្មើនឹង៣៣.៣% ត្រូវការបន្ថែមផ្នែកបច្ចេកវិទ្យាសម្រាប់ជួយសម្រួលដល់ការធ្វើកិច្ចការផ្សេងៗក្នុងការបង្រៀន។
- **ការផលិត និងការប្រើប្រាស់សម្ភារៈឧបទេស៖** មានគ្រូចំនួន១៣នាក់ ស្មើនឹង១៣.៧% ដែល ត្រូវការចង់ចេះផលិតសម្ភារៈបន្ថែមដែលគាំទ្រដល់ការបង្រៀនរបស់ពួកគាត់។

៤.២.២.៣ កម្មវិធីសិក្សា

នៅក្នុងងផ្នែកនេះ អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរចំនួន១៥សំណួរ ចាប់ពីសំណួរទី១៣ ដល់ទី២៧ នឹងយកមកបង្ហាញ និងបកស្រាយពន្យល់បន្ថែមដូចជា៖

- លោកគ្រូ អ្នកគ្រូចំនួន២២នាក់ ស្មើនឹ១០០% សុទ្ធតែមានបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំសម្រាប់ការបង្រៀន។
- លោកគ្រូ អ្នកគ្រូយល់ថា កម្មវិធីសិក្សាមានសារៈសំខាន់ខ្លាំងណាស់ ដល់ការបង្រៀនរបស់ពួកគាត់នៅតាមមុខវិជ្ជានីមួយៗ មានចំនួន៥នាក់ស្មើនឹង២២.៧% ហើយគ្រូ ដែលយល់ថាកម្មវិធីសិក្សាមានសារៈសំខាន់ខ្លាំង មានចំនួន១៥នាក់ ស្មើនឹង៦៨.២% និងគ្រូដែលយល់ថាកម្មវិធីសិក្សាមានសារៈសំខាន់មធ្យម មានចំនួន២នាក់ ស្មើនឹង៩.១%។
- លោកគ្រូ អ្នកគ្រូបានបញ្ជាក់បន្ថែមទៀតថា សាលាក៏មានបន្ទប់សម្រាប់ធ្វើការពិសោធន៍ជាក់ស្តែង សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រផងដែរ មានចំនួន២២នាក់ ស្មើនឹង១០០%។ ទោះបីយ៉ាងណាក៏ដោយ ក្នុងចំណោមគ្រូទាំង២២នាក់ខាងលើនេះ មានគ្រូបង្រៀនខ្លះផ្នែកមុខវិជ្ជាសង្គម ដូច្នេះចំពោះសំណួរបន្ទាប់ពួកគាត់អាចរំលងបាន។
- ចំពោះការអនុវត្ត ឬការធ្វើពិសោធន៍វិញ មានគ្រូចំនួន៩នាក់ ស្មើនឹ៦៩.២% បានពិសោធន៍ចំនួន១ម៉ោងក្នុងមួយសប្តាហ៍ គ្រូចំនួន២នាក់ ស្មើនឹង១៥.៤% បានអនុវត្ត

ចំនួន២ម៉ោងក្នុងមួយសប្តាហ៍ និគ្រូចំនួន១នាក់ ស្មើនឹង៧.៧% បានអនុវត្ត៣ម៉ោងក្នុងមួយសប្តាហ៍ និងគ្រូចំនួន១នាក់ ស្មើនឹង៧.៧% បានអនុវត្ត៤ម៉ោងក្នុងមួយសប្តាហ៍។

- លោកគ្រូ អ្នកគ្រូបានបន្ថែមទៀតថា សាលមានបណ្ណាល័យចំនួន១ សម្រាប់គាំទ្រដល់ការសិក្សា របស់សិស្ស ដែលមានគ្រូចូលរួមឆ្លើយចំនួន២២នាក់ ស្មើនឹង១០០%។
- បន្ទាប់មកលោកគ្រូ អ្នកគ្រូ បានចូលរួមស្រាវជ្រាវ ឬដឹកនាំសិស្សចូលបណ្ណាល័យ ដែលគ្រូចំនួន១២នាក់ ស្មើនឹង៦៦.៧% ចូលបានតែ១ម៉ោងក្នុងមួយសប្តាហ៍ ហើយគ្រូចំនួន១នាក់ ស្មើនឹង៥.៦% បានចូល២ម៉ោង ក្នុងមួយសប្តាហ៍ គ្រូចំនួន១នាក់ ស្មើនឹង៥.៦% បានចូល៤ម៉ោង ក្នុងមួយសប្តាហ៍និងគ្រូចំនួន៥នាក់ ស្មើនឹង២២.២% មិនបានចូលសោះ។
- លោកគ្រូ អ្នកគ្រូចំនួន៤នាក់ ស្មើនឹង១៨.២% បានប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌល និងគ្រូចំនួន ១៨នាក់ ស្មើនឹង៨១.៨% ប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល។
- លោកគ្រូ អ្នកគ្រូបានជ្រើសរើសយកវិធីសាស្រ្តក្នុងការបង្រៀនដូចខាងក្រោមៈ
  - តាមបែបរិះរក(IBL) ៖ មានគ្រូចំនួន៣នាក់ ស្មើនឹង១៥%
  - តាមបែបសហការ ៖ មានគ្រូចំនួន៩នាក់ ស្មើនឹង៤៥%
  - វិធីវិទ្យាសាស្រ្ត ៖ គ្មាន
  - តាមបែបផឹនទីគំនិត ៖ គ្មាន
  - តាមបែបតុក្កតាគំនិត៖ គ្មាន
  - តាមបែបដោះស្រាយបញ្ហា៖ មានគ្រូចំនួន២នាក់ ស្មើនឹង១០%
  - ប្រើវិធីទាំងអស់ខាងលើ៖ មានគ្រូចំនួន៨នាក់ ស្មើនឹង៤០%
- ចំពោះការរៀបចំ ឬការធ្វើកិច្ចតែងការបង្រៀន មានគ្រូចំនួន៦នាក់ ស្មើនឹង២៧.៣% ដែលធ្វើកិច្ចតែងការដោយប្រើឧបករណ៍អេឡិចត្រូនិច ឯគ្រូចំនួន១៦នាក់ ស្មើនឹង៧២.៧% ធ្វើកិច្ចតែងការដោយសរសេរដៃ។ ដោយសារលោកគ្រូ អ្នកគ្រូភាគច្រើនខ្វះចំណេះដឹងផ្នែកអេឡិចត្រូនិច។

- បន្ទាប់មកទៀត លោកគ្រូ អ្នកគ្រូដែលធ្វើកិច្ចតែងការបង្រៀនបានគ្រប់មេរៀនដូចខាងក្រោម៖
  - គ្រូដែលធ្វើកិច្ចតែងការគ្រប់មេរៀន និងគ្រប់ពេលមានចំនួន៩នាក់ ស្មើនឹង៤០.៩%
  - គ្រូដែលធ្វើកិច្ចតែងការគ្រប់មេរៀន ពេលខ្លះ មានចំនួន១៣នាក់ ស្មើនឹង៥៩.១%
- ការដាក់កិច្ចការផ្ទះឲ្យសិស្ស គ្រូដែលបានដាក់កិច្ចការផ្ទះបាន១ដង ចំនួន១៣នាក់ ស្មើនឹង ៥៩.១% គ្រូដែលបានដាក់កិច្ចការផ្ទះ២ដង មានចំនួន៧នាក់ ស្មើនឹង៣១.៨% និងគ្រូដែលបានដាក់កិច្ចការផ្ទះ៣ដង មានចំនួន២នាក់ ស្មើនឹង៩.១%។
- ហើយភាគរយសិស្សដែលបានធ្វើកិច្ចការផ្ទះ ចន្លោះពី២០%ទៅ៤០% មានចំនួន១នាក់ ស្មើនឹង៤.៥% ចន្លោះពី៤០%ទៅ៦០% មានគ្រូចំនួន១១នាក់ ស្មើនឹង៥០% ចន្លោះពី ៦០%ទៅ៨០% មានគ្រូចំនួន៨មាក់ ស្មើនឹង៣៦.៤% និងចន្លោះពី៨០%ទៅ១០០% មានចំនួន២នាក់ ស្មើនឹង៩.១%។
- សម្រាប់ម៉ោងបង្រៀនមុខវិជ្ជានីមួយៗនៅសាលារដ្ឋ មានលោកគ្រូ អ្នកគ្រូចំនួន១២នាក់ ស្មើនឹង៥៤.៥% យល់ថា គ្រប់គ្រាន់ ហើយលោកគ្រូ អ្នកគ្រូចំនួន១០នាក់ស្មើនឹង ៤៥.៥% យល់ថាមិនគ្រប់គ្រាន់ទេ។
- ចំពោះលោកគ្រូ អ្នកគ្រូដែលយល់ថា ម៉ោងបង្រៀនមុខវិជ្ជានីមួយៗមិនគ្រប់គ្រាន់ ពួកគាត់ត្រូវការ ម៉ោងបន្ថែមដូចតទៅ គ្រូចំនួន២នាក់ ស្មើនឹង២០% ត្រូវការម៉ោងបន្ថែមចំនួន២ម៉ោង ហើយគ្រូចំនួន៣នាក់ ស្មើនឹង៣០% ត្រូវការម៉ោងបន្ថែម៤ម៉ោង គ្រូចំនួន៣នាក់ ស្មើនឹង៣០% ត្រូវការម៉ោងបន្ថែម៦ម៉ោង និងគ្រូចំនួន២នាក់ ស្មើនឹង២០% ត្រូវការម៉ោងបន្ថែម៧ម៉ោង។

### ៤.២.២.៤ សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់

នៅក្នុងចំណុចនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់សំណួរចំនួន២ចាប់ពីសំណួរទី២៨ដល់ទី១៩៖

- សកម្មភាពសិស្សរៀនក្នុងថ្នាក់ ត្រូវបានបែងចែកជា៤សកម្មភាពដូចខាងក្រោមៈ

- **សិស្សធ្វើសកម្មភាពម្នាក់ឯង៖** គ្រូចំនួន៤នាក់ ស្មើនឹង១៨.២% តែងតែឲ្យសិស្សធ្វើកិច្ចការម្នាក់ឯងគ្រប់ពេល គ្រូចំនួន៧នាក់ ស្មើនឹង៣១.៨% ឲ្យសិស្សធ្វើម្នាក់ឯងញឹកញ៉ាប់ គ្រូចំនួន១០នាក់ ស្មើនឹង៤៥.៥% ឲ្យសិស្សធ្វើម្នាក់ឯងពេលខ្លះ និងគ្រូចំនួន១នាក់ ស្មើនឹង៤.៥% កម្រឲ្យសិស្សធ្វើម្នាក់ឯងណាស់។
- **សិស្សធ្វើការងារជាដៃគូរ៖** គ្រូចំនួន១នាក់ ស្មើនឹង៤.៥% តែងតែឲ្យសិស្សធ្វើការងារជាដៃគូរគ្រប់ពេល គ្រូចំនួន៧នាក់ ស្មើនឹង៣១.៨% ឲ្យសិស្សធ្វើការងារជាដៃគូរបានញឹកញ៉ាប់ គ្រូចំនួន១២នាក់ ស្មើនឹង៥៤.៥% ឲ្យសិស្សធ្វើការងារជាដៃគូរពេលខ្លះ និងគ្រូចំនួន២នាក់ ស្មើនឹង៩.១% កម្រឲ្យសិស្សធ្វើការងារជាដៃគូរណាស់។
- **សិស្សធ្វើការជាក្រុម៖** គ្រូចំនួន៣នាក់ ស្មើនឹង១៣.៦% តែងតែឲ្យសិស្សធ្វើការជាក្រុមគ្រប់ពេល គ្រូចំនួន៦នាក់ ស្មើនឹង២៧.៣% ឲ្យសិស្សធ្វើការជាក្រុមបានញឹកញ៉ាប់ គ្រូចំនួន១១នាក់ ស្មើនឹង៥០% ឲ្យសិស្សធ្វើការជាក្រុមនៅពេលខ្លះ និងគ្រូចំនួន២នាក់ ស្មើនឹង៩.១% កម្រឲ្យសិស្សធ្វើការជាក្រុមណាស់។
- **សិស្សទាំងអស់ធ្វើការរួមគ្នា៖** គ្រូចំនួន១នាក់ ស្មើនឹង៤.៥% តែងតែឲ្យសិស្សទាំងអស់ធ្វើការរួមគ្នាបានញឹកញ៉ាប់ គ្រូចំនួន១៣នាក់ ស្មើនឹង៥៩.១% ឲ្យសិស្សទាំងអស់ធ្វើការរួមគ្នានៅពេលខ្លះគ្រូចំនួន៦នាក់ ស្មើនឹង២៧.៣% កម្រឲ្យសិស្សទាំងអស់ធ្វើការរួមគ្នាណាស់ និងគ្រូចំនួន២នាក់ ស្មើនឹង៩.១% មិនដែលឲ្យសិស្សទាំងអស់ធ្វើការរួមគ្នាសោះ។

- លោកគ្រូ អ្នកគ្រូចំនួន១២នាក់ ស្មើនឹង៥៤.៥% តែងតែលើកទឹកចិត្តសិស្សនៅពេលបង្រៀនគ្រប់ពេល ហើយលោកគ្រូ អ្នកគ្រូចំនួន១០នាក់ ស្មើនឹង៤៥.៥%។

៤.២.២.៥ បរិមាណសិស្សក្នុងថ្នាក់

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានបង្កើតសំណួរចំនួន២ ចាប់ពីសំណួរទី៣០ ដល់ទី៣១ ៖

- ជាមធ្យមសិស្សក្នុងថ្នាក់ចន្លោះពី៤៦នាក់ ទៅ៥០នាក់មានលោកគ្រូ អ្នកគ្រូចំនួន៦នាក់ ស្មើនឹង២៧.៣% និងគ្រូចំនួន១៦នាក់ ស្មើនឹង៧២.៧% បានឆ្លើយថា សិស្សជាមធ្យមក្នុងថ្នាក់ចគឺច្រើន ជាង៥០នាក់។
- បន្ទាប់មកលោកគ្រូ អ្នកគ្រូយល់ថា កាលណាចំនួនសិស្សច្រើនក្នុងថ្នាក់ធ្វើឲ្យជះឥទ្ធិពលអវិជ្ជមានដល់ការបង្រៀនខ្លាំងណាស់ មានគ្រូចំនួន៦នាក់ ស្មើនឹង២៧.២% ហើយគ្រូដែលយល់ថាសិស្សច្រើនជះឥទ្ធិពលអវិជ្ជមានដល់ការបង្រៀនខ្លាំង មានចំនួន១៥នាក់ ស្មើនឹង៦៨.២% និងគ្រូដែលយល់ថាសិស្សច្រើនក្នុងថ្នាក់បានជះឥទ្ធិពលអវិជ្ជមានដល់ការបង្រៀនជាមធ្យម។

៤.២.២.៦ វិន័យ

នៅចំណុចនេះ អ្នកស្រាវជ្រាវមានសំណួរចំនួន៣ ចាប់ពីសំណួរទី៣២ ដល់៣៤ សម្រាប់យកមកបង្ហាញ និងបកស្រាយពន្យល់ដូចខាងក្រោមះ

- លោកគ្រូ អ្នកគ្រូបានបញ្ជាក់បន្ថែមអំពីសិស្សដែលអវត្តមានច្រើន មានគ្រូ២នាក់ ស្មើនឹង៩.១% បានយល់ថាបើសិស្សអវត្តមានច្រើនត្រូវធ្វើការដកពិន្ទុ ហើយគ្រូចំនួន៩នាក់ ស្មើនឹង៤០.៩% បានយល់ថាត្រូវផ្តល់ដំណឹងដល់ឪពុកម្តាយ ឯគ្រូចំនួន១នាក់ ស្មើនឹង៤.៥% យល់ថាគួផាកពិន័យជាប្រាក់ និងគ្រូចំនួន១០នាក់ ស្មើនឹង៤៥.៥% យល់ថាត្រូវឲ្យសិស្សសរសេរកិច្ចសន្យា។
- ក្នុងថ្នាក់ជាមធ្យមសិស្សអវត្តមានចំនួន១នាក់ ដែលមានគ្រូ១នាក់ ស្មើនឹង៤.៥% បានឆ្លើយ ហើយគ្រូចំនួន២នាក់ ស្មើនឹង៩.១% ឆ្លើយថាសិស្សអវត្តមានចំនួន២នាក់ក្នុងម៉ោងសិក្សា គ្រូ៧នាក់ ស្មើនឹង៣១.៨% បានឆ្លើយថាសិស្សអវត្តមានចំនួន៣នាក់ក្នុងពេលសិក្សា ឯគ្រូចំនួន៣នាក់ ស្មើនឹង១៣.៦% ថាសិស្សអវត្តមានចំនួន៤នាក់ក្នុងពេលម៉ោងបង្រៀន និងគ្រូចំនួន៩នាក់ ស្មើនឹង៤០.៩% ថាសិស្សអវត្តមានច្រើនជាង៤នាក់ក្នុងពេល

រៀន ភាគច្រើនជាសិស្សដែលនៅឆ្ងាយ និងជួបការលំបាក គ្មានមធ្យោបាយធ្វើដំណើរ និងអ្នកខ្លះជាគ្រួសារក្រីក្រ។

- ទោះជាយ៉ាងណាក៏ដោយ លោកគ្រូ អ្នកគ្រូចំនួន១២នាក់ ស្មើនឹង៥៤.៥% បានបង្ហាញថាសិស្ស៩០% បានមករៀនទៀត ហើយគ្រូចំនួន៦នាក់ ថាសិស្ស៨០% បានមករៀនទៀងពេល ឯគ្រូ២នាក់ ស្មើនឹង៩.១% ថាសិស្ស៧០% បានមករៀនទៀងពេល គ្រូ១នាក់ ស្មើនឹង ៤.៥% ថាសិស្ស៦០%មករៀនទៀងពេល និងមានគ្រូ១នាក់ ស្មើនឹ៤.៥% ថាសិស្ស១០០% បានរៀនទៀងពេល។

### ៤.២.២.៧ បរិស្ថានសិក្សា

នៅចំណុចនេះ អ្នកស្រាវជ្រាវមានសំណួរចំនួន៣ ចាប់ពីសំណួរទទី៣៥ ដល់៣៧ សម្រាប់យកមកបង្ហាញ និងបកស្រាយពន្យល់ដូចខាងក្រោម៖

- លោកគ្រូ អ្នកគ្រូចំនួន១៦នាក់ ស្មើនឹង៧២.៧% បានចុះកម្មសិក្សា ហើយលោកគ្រូ អ្នកគ្រូចំនួន៦នាក់ មិនបានចូលរួមចុះកម្មសិក្សាទេ។
- លោកគ្រូ អ្នកគ្រូចំនួន១៦នាក់ ស្មើនឹង៧៦.២% ថាការសិក្សាភាគច្រើនប្រព្រឹត្តទៅនៅក្នុងថ្នាក់រៀន ហើយគ្រូចំនួន២នាក់ ស្មើនឹង៩.៥% ថាការសិក្សាភាគច្រើនប្រព្រឹត្តទៅនៅក្នុងបរិវេណសាលារៀន និងគ្រូចំនួន៣នាក់ ស្មើនឹង១៤.៣% ថាការសិក្សាភាគច្រើនប្រព្រឹត្តទៅនៅក្នុងថ្នាក់រៀនផង ទីពិសោធផង និងបរិវេណសាលាផង តាមកាលៈទេសៈនៃមេរៀន។
- ចំពោះទំនាក់ទំនងរវាងគ្រូ និងសិស្ស ហើយរវាងសិស្ស និងគ្រូវិញ មានគ្រូចំនួន២នាក់ យល់ថានៅមានកម្រិតល្អបង្គួរនៅឡើយ ហើយមានគ្រូចំនួន១៦នាក់ ស្មើនឹង៧២.៧% យល់ថាមានទំនាក់ទំនងល្អ និងគ្រូចំនួន១នាក់ ស្មើនឹង៤.៥% យល់ថាមានទំនាក់ទំនងល្អណាស់។

៤.២.២.៨ ប្រសិទ្ធភាព

នៅចំណុចនេះ អ្នកស្រាវជ្រាវមានសំណួរចំនួន៥ ចាប់ពីសំណួរទទី៣៨ ដល់៤២ សម្រាប់យកមកបង្ហាញ និងបកស្រាយពន្យល់ដូចខាងក្រោម៖

- កម្រិតវប្បមធ៌របស់លោកគ្រូ អ្នកគ្រូ ដែលក្នុងចំណុចនេះ លោកគ្រូ អ្នកគ្រូចំនួន២នាក់ ស្មើនឹង៩.១% មានសញ្ញាបត្រទុតិយភូមិ ហើយលោកគ្រូ អ្នកគ្រូចំនួន១៩នាក់ ស្មើនឹង ៨៦.៤% មានសញ្ញាបត្របរិញ្ញាបត្រ និងលោកគ្រូ អ្នកគ្រូចំនួន១នាក់ ស្មើនឹង៤.៥% មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។
- លោកគ្រូ អ្នកគ្រូចំនួន៤នាក់ ស្មើនឹង១៨.២% មានបទពិសោធការងារ អស់រយៈពេល១ ទៅ៣ឆ្នាំ ហើយលោកគ្រូ អ្នកគ្រូចំនួន២នាក់ ស្មើនឹង៩.១% មានបទពិសោធការងារអស់រយៈពេល៣ទៅ៦ឆ្នាំ លោកគ្រូ អ្នកគ្រូចំនួន៨នាក់ ស្មើនឹង៣៦.៤% មានបទពិសោធការងារ អស់រយៈពេល៦ទៅ៩ឆ្នាំ និងលោកគ្រូ អ្នកគ្រូចំនួន៨នាក់ ស្មើនឹង៣៦.៤% មានបទពិសោធការងារអស់រយៈពេលច្រើនជាង៩ឆ្នាំហើយ។
- បន្ទាប់មកទៀតលោកគ្រូ អ្នកគ្រូចំនួន៤នាក់ ស្មើនឹង១៨.២% បង្រៀន១កម្រិតថ្នាក់ លោកគ្រូ អ្នកគ្រូចំនួន១៦នាក់ ស្មើនឹង១៨.២% បង្រៀន២កម្រិតថ្នាក់ លោកគ្រូ អ្នកគ្រូចំនួន២នាក់ ស្មើនឹង៩.១% បង្រៀនចំនួន៣កម្រិតថ្នាក់
- ចំពោះការប្រជុំបច្ចេកទេស លោកគ្រូ អ្នកគ្រូ ចំនួន២១នាក់ ស្មើនឹង៩៥.៥% បានប្រជុំបច្ចេកទេស១ដង ក្នុងមួយខែ ហើយលោកគ្រូ អ្នកគ្រូ ចំនួន១នាក់ ស្មើនឹ៤.៥% បានប្រជុំបច្ចេកទេស៤ដងក្នុងមួយខែ។
- ជាចុងក្រោយ លោកគ្រូ អ្នកគ្រូបង្ហាញអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់គម្រោងSEIP៖

❖ **ចំណុចខ្លាំង**

- សិស្សខិតខំរៀនបានច្រើន

- ទទួលបានបទពិសោធន៍ថ្មីៗនិងធ្វើឲ្យយើងមានការទទួលខុសត្រូវលើការងារ

- ពង្រឹងវិន័យសិស្ស និងគ្រូ
- មានការលើកទឹកចិត្តគ្រូបង្រៀន និងសិស្ស
- ការគ្រប់គ្រងល្អ
- ផ្តល់ឱកាសឲ្យគ្រូទៅពង្រឹងគុណវុឌ្ឍិបន្ថែម២ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ពង្រឹងគុណភាពចំណេះដឹងទាំងគ្រូ និងសិស្ស
- សិស្សអាចបញ្ចេញសមត្ថភាពផ្ទាល់ខ្លួន និងបានដឹងពីសមត្ថភាពពិតរបស់ខ្លួន
- សិស្សមានកាស្វ័យសិក្សាបានច្រើនជាងមុន និងខិតខំប្រឹងរៀនជាងមុន មានស្មារតីទទួលខុសត្រូវខ្ពស់
- លទ្ធផលសិក្សារបស់សិស្សបានល្អជាងពេលមុនៗ

❖ **ចំណុចខ្សោយ**

- សិស្សពិបាកក្នុងការធ្វើតេស្តដោយមានការប្តូរបែបបទតាមខែនីមួយៗ
- ពេលខ្លះឯកសារច្រើនពេក និងពិបាកក្នុងការយល់ ដើម្បីធ្វើរបាយការណ៍
- ខ្វះគ្រូ និងខ្វះអគារសិក្សា
- ពិបាកជួយសិស្សដែលរៀនយឺត( សិស្សដែលរៀនយឺតតាមមិនទាន់ )
- ពិបាកទាក់ទងជាមួយអាណាព្យាបាលរបស់សិស្ស ព្រោះពួកគាត់ធ្វើចំណាកស្រុក
- គ្រូមានរបាយការណ៍ច្រើនពេក
- ច្របូកច្របល់ពេលធ្វើតេស្តប្រចាំខែម្តងៗ ហើយខាតពេលរៀនរបស់សិស្ស

# ជំពូកទី៥. ការសេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# ការសេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះក្នុងគោលបំណងសិក្សាអំពី ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅ មធ្យមសិក្សា(SEIP) ដែលជួយដល់ការរៀន និងការបង្រៀននៅវិទ្យាល័យបវេល ខេត្តបាត់ដំបង។ ក្នុងនោះ អ្នក ស្រាវជ្រាវបានជ្រើសរើសប្រជាជនចំនួន៥៨នាក់ ស្រី៣៧នាក់ រួមមាន៖

- គណៈគ្រប់គ្រងសាលា ២នាក់ នាយក១នាក់ និងនាយករង ១នាក់
- លោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ ចំនួន ២២នាក់ ស្រី១៥នាក់
- សិស្សថ្នាក់ទី៧ ចំនួន ០៥នាក់ ស្រី ០៣នាក់
- សិស្សថ្នាក់ទី៨ ចំនួន ០៥នាក់ ស្រី ០៣នាក់
- សិស្សថ្នាក់ទី៩ ចំនួន ២៤នាក់ ស្រី ១៦នាក់

ឧបករណ៍ស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរជ្រើសរើស និងបំពេញចម្លើយដោយបែងចែកជា៣ទម្រង់៖

- ទម្រង់ទី១ កម្រងសំណួរសម្រាប់សិស្ស មាន៦ផ្នែក៖
  - ផ្នែកទី១ ព័ត៌មានទូទៅ មាន៣ចំណុច ចាប់ពីចំណុចទី១ ដល់៣
  - ផ្នែកទី២ គុណវុឌ្ឍគ្រូបង្រៀន មាន៣ចំណុច ចាប់ពីចំណុចទី៤ ដល់៦
  - ផ្នែកទី៣ កម្មវិធីសិក្សា មាន៥ចំណុច ចាប់ពីចំណុចទី៧ ដល់១១
  - ផ្នែកទី៤ សម្ភារៈទ្រទ្រង់ដល់ការបង្រៀន មាន២ចំណុច ចាប់ពីចំណុចទី១២ ដល់១៣
  - ផ្នែកទី៥ សកម្មភាពសិស្សក្នុងថ្នាក់ មាន២ចំណុច ចាប់ពីចំណុចទី១៤ ដល់១៥
  - ផ្នែកទី៦ បរិមាណសិស្សក្នុងថ្នាក់ មាន២ចំណុច ចាប់ពីចំណុចទី១៦ ដល់១៧
- ទម្រង់ទី២ កម្រងសំណួរសម្រាប់គ្រូបង្រៀន មាន៨ផ្នែក៖

- ផ្នែកទី១ ព័ត៌មានទូទៅ មាន៥ចំណុច ចាប់ពីចំណុចទី១ ដល់៥
- ផ្នែកទី២ គុណវុឌ្ឍិគ្រូបង្រៀន មាន៧ចំណុច ចាប់ពីចំណុចទី៦ ដល់១២
- ផ្នែកទី៣ កម្មវិធីសិក្សា មាន១៥ចំណុច ចាប់ពីចំណុចទី១៣ ដល់២៧
- ផ្នែកទី៤ សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់ មាន២ចំណុច ចាប់ពីចំណុចទី២៨ ដល់២៩
- ផ្នែកទី៥ បរិមាណសិស្សក្នុងថ្នាក់ មាន២ចំណុច ចាប់ពីចំណុចទី៣០ ដល់៣១
- ផ្នែកទី៦ វិន័យ មាន៣ចំណុច ចាប់ពីចំណុចទី៣២ ដល់៣៤
- ផ្នែកទី៧ បរិស្ថានសិក្សា មាន៣ចំណុច ចាប់ពីចំណុចទី៣៥ ដល់៣៧
- ផ្នែកទី៨ ប្រសិទ្ធភាព មាន៥ចំណុច ចាប់ពីចំណុចទី៣៨ ដល់៤២

- ទម្រង់ទី៣ កម្រងសំណួរសម្រាប់នាយកសាលា និងនាយករង មាន៤ផ្នែកៈ

- ផ្នែកទី១ ព័ត៌មានទូទៅ មាន៤ចំណុច ចាប់ពីចំណុចទី១ ដល់៤
- ផ្នែកទី២ គុណវុឌ្ឍិនាយក មាន៥ចំណុច ចាប់ពីចំណុចទី៥ ដល់៩
- ផ្នែកទី៣ ការគ្រប់គ្រងសាលា មាន៨ចំណុច ចាប់ពីចំណុចទី១០ ដល់១៧
- ផ្នែកទី៤ កម្មវិធីសិក្សា មានា៥ចំណុច ចាប់ពីចំណុចទី១៨ ដល់២២នាក់

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការវិភាគទិន្នន័យតាមបែបវិធីចម្រុះ រួមមាន វិភាគតាមបរិមាណវិស័យផង និងគុណវិស័យផង។ បន្ទាប់មក អ្នកស្រាវជ្រាវបានធ្វើការប្រៀបធៀបលទ្ធ ផលសិក្សារបស់សិស្សនៅឆមាសទី១ សម្រាប់សិស្សថ្នាក់ទី៧(២០១៨-២០១៩) ជាមួយសិស្សថ្នាក់ទី៨(២០១៩-២០២០) និងប្រៀបធៀបសិស្សថ្នាក់ទី៧(២០១៨-២០១៩) ជាមួយសិស្សថ្នាក់ទី៧(២០១៩-២០២០) ដោយប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់វិភាគរក មធ្យម និងគម្លាតស្តង់ដា។ ម្យ៉ាងទៀត អ្នក ស្រាវជ្រាវបានសំយោគបញ្ចូលគ្នានូវចម្លើយដែលបានពីកម្រងសំណួរទាំងអស់តាមផ្នែក ដើម្បីផ្សារភ្ជាប់ជាមួយ លទ្ធផលសិក្សារបស់សិស្សដោយផ្តោតលើប្រសិទ្ធភាពនៃករអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលជួយដល់ការរៀន(SEIP) និងការបង្រៀននៅវិទ្យាល័យបវេល ខេត្តបាត់ដំបង។

១.តាមរយៈការប្រៀបធៀបមធ្យមពិន្ទុរបស់សិស្សសម្រាប់ឆមាសទី១ **ថ្នាក់ទី៧(២០១៨-២០១៩) ជាមួយសិស្សថ្នាក់ទី៨(២០១៩-២០២០)** អ្នកស្រាវជ្រាវសង្កេតឃើញថា មធ្យមពិន្ទុតាមមុខវិជ្ជានីមួយៗឃើញ ថាមានការកើនឡើងគួរឲ្យកត់សំគាល់ នេះបង្ហាញឲ្យឃើញផងដែរអំពីការយកចិត្តទុកដាក់ក្នុងការខិតខំរៀនសូត្ររបស់សិស្សបានល្អ សិស្សមានការស្វ័យសិក្សាខ្ពស់ ជាពិសេសបង្ហាញឲ្យឃើញពីការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាដែលប្រកបដោយអភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព ជាពិសេសមានការសហការគ្នាល្អជាមួយលោកគ្រូ អ្នកគ្រូក្នុងការបង្ហាត់បង្រៀនសិស្សដោយស្មារតីទទួលខុសត្រូវលើតួនាទី ភារកិច្ចរបស់ខ្លួនម្នាក់ៗបានល្អ។ ដោយឡែកក៏មានមុខវិជ្ជា២មានការថយចុះមធ្យមពិន្ទុគឺប្រវត្តិវិទ្យា និងគីមីវិទ្យា អ្នកស្រាវជ្រាវយល់ថា ការធ្លាក់ចុះនេះអាចបណ្តាលមកពីកំហុសបច្ចេកទេសក្នុងការធ្វើវិញ្ញាសាតេស្តស្តង់ដាប្រចាំខែ និងអាចមកពីលោកគ្រូ អ្នកគ្រូមិនសូវយល់ពីរបៀបធ្វើវិញ្ញាសាស្តង់ដាប្រចាំខែនីមួយៗ និងអាចមកពីសិស្សអវត្តមានច្រើនក្នុង ពេលធ្វើតេស្តប្រចាំខែជាដើម។

២. តាមក្រាបទី២ខាងលើនេះ អ្នកស្រាវជ្រាវសង្កេតឃើញថាមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) **គឺ ១៦.៦២** និងមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៨(២០១៩-២០២០) **គឺ ២៦.៦៥ ។** តាមរយៈទិន្នន័យនេះ សិស្សទាំងពីរកម្រិតថ្នាក់នេះជាសិស្ស ដដែល និងបានឆ្លងកាត់ការធ្វើតេស្តស្តង់ដារាល់ខែ ហើយលទ្ធផលមធ្យមរបស់សិស្សថ្នាក់ទី៧(២០១៨-២០១៩) ទាបជាង លទ្ធផលមធ្យមរបស់សិស្សថ្នាក់ទី៨(២០១៩-២០២០)។ ដូច្នេះ អ្នកស្រាវជ្រាវយល់ថា ការអនុវត្តគម្រោង SEIP នៅឆ្នាំ២០១៨-២០១៩ មិនទាន់បានល្អនៅឡើយ ដោយសារការតាក់តែងវិញ្ញាសាតេស្តស្តង់ដាប្រចាំខែរបស់លោកគ្រូ អ្នកគ្រូ នៅមានកម្រិតនៅឡើយ ម្យ៉ាងទៀតអាចមកពីការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមិនទាន់ស៊ីជម្រៅទៅលើមេរៀន ជាពិសេសមុខវិជ្ជាមួយដែលមានគ្រូបង្រៀនតែម្នាក់ ធ្វើឲ្យពិបាកក្នុងការធ្វើការវាយតម្លៃទៅលើសមត្ថភាពរបស់សិស្សច្រើនថ្នាក់បាន រីឯការសិស្សក៏មិនទាន់បានរៀបចំឥរិយាបថក្នុងការប្រឡងប្រចាំខែជាលក្ខណៈស្តង់ដានៅឡើយ និងមិនសូវខិតខំរៀនសូត្រ ដូច្នេះហើយបានជាលទ្ធផលមធ្យម ឆមាសទី១ សម្រាប់សិស្ស

ថ្នាក់ទី៧(២០១៨-២០១៩)នៅទាប**គឺ១៦.៦២។** ចំណែកឯ សិស្សថ្នាក់ទី៨(២០១៩-២០២០)**គឺ ២៦.៦៥** មានមធ្យមសរុបខ្ពស់ជាង ថ្នាក់ទី៧(២០១៨-២០១៩) ដោយសារសិស្សនេះគឺជាសិស្សឆ្នាំចាស់ដដែល ដែលបានឡើងថ្នាក់ទី៨ ហើយពួកគាត់បានយល់ច្បាស់អំពីការប្រែការប្រឡងស្តង់ដាប្រចាំខែ និងមានការខិតខំរៀនសូត្រ មានការស្វ័យសិក្សាល្អជាងមុន ចំណែកលោកគ្រូ អ្នកគ្រូក៏មានការកែប្រែឥរិយាបថក្នុងការបង្រៀនឲ្យបានល្អ បង្រៀនដោយមានកិច្ចតែងការ និងយកចិត្តទុកដាក់ទៅលើការសិក្សារបស់សិស្ស ហើយមានការតាក់តែងវិញ្ញាសាតេស្តស្តង់ដាយ៉ាងមានប្រសិទ្ធជាងពេលមុនៗ និងចេះវាស់ពីសមត្ថភាពសិស្សដែលរៀនថ្នាក់ខុសគ្នា លោកគ្រូ អ្នកគ្រូ មានការសហការគ្នាល្អជាមួយគ្រូបង្រៀនដូចគ្នា និងជាមួយគណៈគ្រប់គ្រងក្នុងការរៀបចំសិស្សធ្វើតេស្តជារៀងរាល់ខែបានយ៉ាងល្អដូច្នេះហើយបានជាការសិក្សារបស់សិស្សថ្នាក់ទី៨(២០១៩-២០២០)ទទួលបានមធ្យមខ្ពស់។ ទាំងនេះបង្ហាញឲ្យឃើញថា ការអណុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP)ដែលបានជួយដល់ការរៀន និងការបង្រៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាពជាមុនពីមួយឆ្នាំទៅមួយឆ្នាំ។

៣.តាមរយៈការប្រៀបធៀបមធ្យមពិន្ទុរបស់សិស្សសម្រាប់ឆមាសទី១ **ថ្នាក់ទី៧(២០១៨-២០១៩) ជាមួយសិស្សថ្នាក់ទី៧(២០១៩-២០២០)** អ្នកស្រាវជ្រាវសង្កេតឃើញថា សិស្សទាំងពីកម្រិតថ្នាក់នេះសុទ្ធតែចាប់ផ្តើមឈានចូលកម្រិតអនុវិទ្យាល័យ និងត្រូវឆ្លងកាត់ការធ្វើតេស្តចូលរៀនផងដែរ ហើយចំពោះមធ្យមពិន្ទុតាមមុខវិជ្ជានីមួយៗឃើញថាក៏មានការកើនឡើងគួរឲ្យកត់សំគាល់ នេះបង្ហាញឲ្យឃើញផងដែរអំពីការយកចិត្តទុកដាក់ក្នុងការខិតខំរៀនសូត្ររបស់សិស្សបានល្អពីមួយឆ្នាំទៅមួយឆ្នាំ សិស្សមានការស្វ័យសិក្សាខ្ពស់ ជាពិសេសបង្ហាញឲ្យឃើញពីការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាដែលប្រកបដោយអភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព ជាពិសេសមានការសហការគ្នាល្អជាមួយលោកគ្រូ អ្នកគ្រូក្នុងការបង្ហាត់បង្រៀនសិស្សដោយស្មារតីទទួលខុសត្រូវលើតួនាទី ភារកិច្ចរបស់ខ្លួនម្នាក់ៗ បានល្អ។ ដោយឡែកក៏មានមុខវិជ្ជា២មានការថយចុះមធ្យមពិន្ទុគឺប្រវត្តិវិទ្យា និងគីមីវិទ្យា អ្នកស្រាវជ្រាវយល់ថា ការធ្លាក់ចុះនេះអាចបណ្តាលមកពីកំហុសបច្ចេកទេសក្នុងការធ្វើវិញ្ញាសាតេស្តស្តង់ដា

ប្រចាំខែ និងអាចមកពីលោកគ្រូ អ្នកគ្រូមិនសូវយល់ពីរបៀបធ្វើវិញ្ញាសាស្តង់ដាប្រចាំខែនីមួយៗ និង អាចមកពីសិស្សអវត្តមានច្រើនក្នុង ពេលធ្វើតេស្តប្រចាំខែជាដើម។

៤. តាមរយៈក្រាបទី៤ខាងលើនេះ បង្ហាញថាលទ្ធផលមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៨-២០១៩)**គឺ១៦.៦២** និងមធ្យមសរុបសម្រាប់ឆមាសទី១ របស់សិស្សថ្នាក់ទី៧(២០១៩-២០២០)**គឺ២២.៧០។** តាមលទ្ធផលខាងលើនេះ ត្បិតថាសិស្សទាំងពីរកម្រិតមានកម្រិតដូចគ្នា ប៉ុន្តែឆ្នាំសិស្សរបស់ពួកគាត់ខុសគ្នា អ្នកស្រាវជ្រាវយល់ថា ការអនុវត្តគម្រោង SEIP នៅវិទ្យាល័យបវេល មានប្រសិទ្ធភាពពីមួយឆ្នាំទៅមួយឆ្នាំ ព្រោះកាលណាលទ្ធផលសិក្សារបស់សិស្សដែលបានឆ្លង កាត់ការប្រឡងស្តង់ដា ដែលមានការរៀបចំពីសាលរៀនមានលក្ខណៈតឹងរឹង សមធម៌ និងមានតម្លាភាព ហើយទិន្នន័យនេះក៏បង្ហាញឲ្យឃើញពីការខិតខំរៀនសូត្ររបស់សិស្ស និងការការបង្រៀនយ៉ាងយកចិត្ត ទុកដាក់របស់លោកគ្រូ អ្នកគ្រូបានស៊ីជម្រៅទៅតាមមេរៀននីមួយៗ ដែលធ្វើឲ្យសិស្សអាចធ្វើកិច្ចការនោះបានល្អ ជាពិសេសការរៀបចំការប្រឡងប្រចាំខែមានលក្ខណៈតឹងរឹងច្បាស់លាស់ និងបង្ហាញពីការគ្រប់គ្រងរវាងគណៈគ្រប់គ្រងសាលានិងលោកគ្រូ អ្នកគ្រូសហការគ្នាបំពេញការងារបានល្អប្រសើរ ទើបធ្វើឲ្យលទ្ធផលសិក្សារបស់សិស្សកើនខ្ពស់។ ទាំងនេះបញ្ជាក់ថាការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP )នៃវិទ្យាល័យបវេលមានប្រសិទ្ធភាព។

៥. តាមក្រាបទី៦ **(សិស្សដដែលប៉ុន្តែ កម្រិតថ្នាក់ខុសគ្នា)** បង្ហាញអំពីការប្រៀបធៀបគម្លាតស្តង់ដាសរុប នៅឆមាសទី១ សម្រាប់សិស្ស ថ្នាក់ទី៧(២០១៨-២០១៩)គឺ**៩.៣៥** ឯសិស្សថ្នាក់ទី៨(២០១៩-២០២០)មានគម្លាតស្តង់ដាសរុបគឺ **១២.០៨**។ យើងឃើញថា គម្លាតស្តង់ដាសរុបមានការកើនឡើង នេះបង្ហាញឲ្យឃើញថាប្រសិទ្ធនសការប្រឡងប្រចាំខែឬឆមាសកាន់តែតឹងរឹង និង ច្បាស់លាស់ នោះធ្វើឲ្យមានគម្លាតស្តង់ដាកាន់តែធំដែរ មានន័យថាសិស្សពិតជាបានបញ្ចេញសមត្ថភាពផ្ទាល់ខ្លួន មិនអាចចម្លងគ្នាបាន ឬសួរគ្នាបាន។ ទាំងនេះបញ្ជាក់ថា ការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលបានជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលពិតជាមានប្រសិទ្ធភាព។

៦.តាមក្រាបទី៧ (**សិស្សផ្សេងគ្នា តែកម្រិតថ្នាក់ដូចគ្នា**) បង្ហាញពីគម្លាតស្តង់ដាសរុប ឆមាសទី១ រវាងសិស្សថ្នាក់ទី៧(២០១៨-២០១៩)គឺ**៩.៣៥** និងសិស្សថ្នាក់ទី៧(២០១៩-២០២០) **គឺ ១២.៤៩។** យោងតាមទិន្នន័យនេះ យើងឃើញថាគម្លាតស្តង់ដាសរុបគ្រប់មុខវិជ្ជាមានការកើនឡើង បញ្ជាក់ថារាល់ការបង្រៀន និងរៀនគឺមានការរីតបន្តឹង ជាពិសេសការប្រឡងប្រចាំខែនីមួយៗមានតម្លាភាព មានន័យថាសិស្សមិនអាចចម្លងគ្នា ឬសួរគ្នាបានទេ ហើយគ្រូបង្រៀនវិញគឺមានការបំពេញការងារបង្រៀនយ៉ាងយកចិត្តទុកដាក់ ខិតខំស្រាវជ្រាវវិធីសាស្ត្រថ្មី ចំណេះដឹងថ្មីៗសម្រាប់យកមកបង្រៀនសិស្សឲ្យកាន់តែប្រសើរថែមទៀត។ ទាំងនេះបង្ហាញឲ្យយើងឃើញពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា ដែលជួយដល់ការបង្រៀន និងរៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាព។

៧. ក្រោយពេលសាលាបានអនុវត្តគម្រោង SEIP នេះមក ឃើញថាសាលាទទួលបានលទ្ធផលសិក្សារបស់ល្អជាងមុន ការគ្រប់គ្រងមានការកែប្រែល្អជាងមុន ចំណែកលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សមានការកែ ប្រែឥរិយាបទទាំងការបំពេញការងារ ការមកបង្រៀន និងការមករៀនរបស់សិស្សបានទៀងទាត់ពេលវេលាល្អ គ្រូបង្រៀនមានកិច្ចតែងការ និងមានការដឹកនាំសិស្សធ្វើពិសោធ ឬធ្វើសកម្មភាពផ្សេងៗដែលគាំទ្រដល់ការរៀន និងការបង្រៀន លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាទទួលបានការបណ្តុះបណ្តាលបន្ថែមលើឯកទេសក្នុងការបង្រៀន និងការគ្រប់គ្រងសាលាតាមរយៈគម្រោង ។ ជារៀងរាល់ខែមានការប្រជុំការងារបានទៀងទាត់ និងមាន ការប្រជុំបច្ចេកទេសតាមមុខវិជ្ជានីមួយៗបានទៀងទាត់ ទោះបីជាការអនុវត្តគម្រោង SEIP នៅវិទ្យាល័យបវេលនេះនៅមានកម្រិតក៏ដោយ គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ និងគណៈទ្រទ្រង់សាលានៅតែខិតខំបន្ត ដើម្បីបំពេញការងារអស់ពីកម្លាំងកាយចិត្ត និងមនសិកាលើការងារ ដើម្បីធ្វើឲ្យសិស្សានុសិស្សនៅវិទ្យាល័យបវេលទទួលបានចំណេះដឹងថ្មីស្របតាមការសិក្សាបែបសតវត្សន៍ទី២១ បង្រៀនសិស្សឲ្យចេះអំពីបំណិនជីវិតច្បាស់លាស់ ការចេះរួមរស់ជាមួយគ្នាប្រកបដោយសុខដុម មានសីលធម៌ល្អក្នុងសង្គម។

## ៥.២ បញ្ហាប្រឈមក្នុងការដំណើរការគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា

ទន្ទឹមនឹងការបង្ហាញចំណុចល្អៗខាងលើ ក៏មានចមណុចខ្វះខាតដែលជាបញ្ហាក្នុងការអនុវត្តគម្រោង SEIP នៅវិទ្យាល័យបវេលនេះផងដែរដូចជា សាលាខ្វះខាតអគារសិក្សា ខ្វះបន្ទប់រៀន និងខ្វះបន្ទប់ពិសោធន៍ សិស្សច្រើនពេកក្នុងថ្នាក់(៤៥ ទៅ៦០នាក់) ខ្វះសម្ភារឧបទេសដែលទ្រទ្រង់ដល់ការបង្រៀនរបស់គ្រូ ។ ជាពិសេស ផលធៀបសិស្ស គ្រូនៅខ្ពស់នៅឡើយ ដែលសព្វថ្ងៃគ្រូបង្រៀនសរុបមានតែ៧៥នាក់ ឯសិស្សមានដល់២៩៥៣នាក់ ដូច្នេះលោកគ្រូ អ្នកគ្រូម្នាក់ៗបង្រៀនច្រើនម៉ោង និងច្រើនកម្រិតថ្នាក់ មិនមានម៉ោងសម្រាប់ស្រាវជ្រាវគ្រប់គ្រាន់។ ម្យ៉ាងវិញទៀតការចូលរួមរបស់សហគមន៍នៅមានកម្រិត ព្រោះមាតាបិតាមួយចំនួនមិនទាន់យល់ច្បាស់ អំពីគោលបំណងរបស់គម្រោង និងគ្រួសារមួយចំនួនជួបការលំបាក ធ្វើចំណាកស្រុក ដែលជាកត្តាធ្វើឲ្យប៉ះពាល់ដល់ការសិក្សារបស់សិស្សផងដែរ។ បន្ថែមពីនោះផងដែរ អ្នកស្រាវជ្រាវបានសង្កេតឃើញថា លោកគ្រូ អ្នកគ្រូខ្លះ មិនបានចូលរួមក្នុងការបណ្តុះបណ្តាលបន្ថែម ឬបង្កើនគុណវុឌ្ឍិតាមរយៈគម្រោង SEIP នៅឡើយ ដោយសារ កន្លែងបណ្តុះបណ្តាលនៅឆ្ងាយពេក ហើយប៉ះពាល់ដល់ការសិក្សារបស់សិស្ស។ បណ្ណាល័យ តូចចង្អៀត មិនទាន់ក្លាយទៅជាបណ្ណាល័យបែបសតវត្សន៍ទី២១នៅឡើយ ការប្រើប្រាស់បណ្ណាល័យនៅមានកម្រិត ព្រោះគ្មានការទាក់ទាញ ខ្វះអ្នកថែទាំសៀវភៅ។

## ៥.៣ សំណូមពរ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងដើម្បីធ្វើឲ្យការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) ដែលជួយដល់ការរៀន និងការបង្រៀននៅវិទ្យាល័យបវេលកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតនោះ អ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួនដូចខាងក្រោម៖

- **ក្រសួងអប់រំ យុវជន និងកីឡា:** គួរចុះពិនិត្យតាមដាន និងវាយតម្លៃឲ្យបានទៀងទាត់ ដើម្បីពង្រឹងការអនុវត្តគម្រោងSEIP ឲ្យប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។ ក្រសួងអប់រំ យុវជន និងកីឡាគួររៀបចំការបណ្តុះបណ្តាលគ្រូបន្ថែមអំពីវិធីសាស្ត្របង្រៀនថ្មីឲ្យបានច្រើនដូចជាចិត្ត-គរុកោសល្យ បណ្តុះបណ្តាលបច្ចេកវិទ្យាICT កុំព្យូទ័របន្ថែមដល់គ្រូ។

ម្យ៉ាងវិញទៀត គួរដាក់កន្លែងដែលបណ្តុះបណ្តាលគ្រូ ដើម្បីពង្រឹងគុណវុឌ្ឍិគ្រូបន្ថែមនៅកន្លែងណាមួយសមរម្យ និងដើម្បីឲ្យគ្រូងាយស្រួលក្នុងការធ្វើដំណើរទៅទទួលការបណ្តុះបណ្តាល ។ ក្រសួងអប់រំ យុវជន និងកីឡា គួរសាងសង់អគារសិក្សាបន្ថែម ឲ្យបានគ្រប់គ្រាន់សម្រាប់សិស្ស និងមាន បំពាក់ឧបករណ៍ដែលគាំទ្រដល់ការរៀន និងបង្រៀនបន្ថែម។ ក្រសួងអប់រំ យុវជន និងកីឡាគួរមានការលើកទឹកចិត្តគ្រូបន្ថែម និងបង្កើនម៉ោងសិក្សាតាមមុខវិជ្ជាបន្ថែម ដើម្បីឲ្យគ្រូ និងសិស្សបានអនុវត្តឲ្យបានច្រើន។

- **មន្ទីរអប់រំ យុវជន និងកីឡាខេត្ត:** គួរចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគម្រោង ឲ្យបានទៀងទាត់ និងគួរមានអ្នកជំនាញឯកទេសដែលយល់ច្បាស់ពីគម្រោង មកចុះជួយគ្រូក្នុងការតាក់តែង វិញ្ញាសាស្តង់ដា សម្រាប់តេស្តប្រចាំខែនីមួយៗ។ មន្ទីអប់រំ យុវជន និងកីឡាគួរធ្វើការប្រឡងជ្រើសរើស គ្រូបន្ថែម និងជ្រើសរើសគ្រូដែលមានសមត្ថភាពចំណេះដឹងខ្ពស់ មានមនសិការក្នុងការងារបន្ថែម ដើម្បី ជួយបង្រៀននៅវិទ្យាល័យបវេល។ មន្ទីអប់រំ យុវជន និងកីឡា គួរតែស្នើទៅក្រសួងអប់រំ ដើម្បីសាងសង់ អគារស្នាក់នៅសម្រាប់សិស្ស និងគ្រូដែលមកពីឆ្ងាយ ឬសិស្សដែលជួបការលំបាកបានស្នាក់នៅ ដើម្បីបានសិក្សាបន្តផងដែរ។
- **សាលារៀន:** គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូគួរយកចិត្តទុកដាក់ និងសហការគ្នាបន្ថែម ដើម្បីអនុវត្តគម្រោងនេះឲ្យកាន់តែមានប្រសិទ្ធភាព ជាពិសេស ត្រូវដឹងឲ្យច្បាស់អំពីភារកិច្ច តួនាទីរបស់ខ្លួន ក្នុងការបំពេញការងារប្រកបដោយគុណភាពខ្ពស់ មានតម្លាភាព គណនេយ្យភាព និងមានអភិបាលកិច្ចល្អនៅក្នុងអង្គភាពវិទ្យាល័យបវេលឲ្យកាន់តែរីកចំរើនបន្តទៅមុខទៀត។
- **សហគមន៍:** គួរចូលរួមឲ្យបានច្រើន និងសកម្មផងដែរជាមួយសាលារៀន ដើម្បីកៀរគរទាំងសម្ភារៈ ឧបទេស និងថវិកាសម្រាប់ទ្រទ្រង់ដល់ដំណើរការ ឬការអភិវឌ្ឍសាលារៀនបន្ថែម ជាពិសេស ចូលរួមលើកទឹកចិត្តសិស្សានុសិស្ស ឬកូនៗរបស់ខ្លួនឲ្យខិតខំរៀនសូត្របន្ត និងទទួលបានលទ្ធផលល្អ។ ជាពិសេស សហគមន៍គួចូលរួមគាំទ្រក្នុងការកសាងផ្សេងៗនៅក្នុងសាលា

រៀនដែលមានការចាំបាច់សម្រាប់ ការរៀន និងការបង្រៀនប្រកបដោយគុណភាព និងមានប្រសិទ្ធភាព។

- **ដៃគូរអភិវឌ្ឍ:** គួរចូលរួមឧបត្ថមគាំទ្រទាំងសម្ភារៈ និងថវិកា និងបច្ចេកទេសបន្ថែមដល់លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ជាពិសេសគួរបំពាក់ឧបករណ៍បង្រៀន បែបទំនើបនៅតាមបន្ទប់រៀននីមួយៗតាមលទ្ធភាព ដើម្បីជួយជំរុញដល់គ្រូ និងសិស្សឲ្យចប្រើប្រាស់ ការបង្រៀន និងរៀនតាមបែបសតវត្សន៍ទី២១។
- **ចំពោះអ្នកស្រាវជ្រាវបន្ត:** សូមសំណូមពរទៅកាន់អ្នកស្រាវជ្រាវក្រោយៗទៀត សូមសិក្សាឲ្យបានទូលំទូលាយទៅលបញ្ហាប្រឈមលើមុខវិជ្ជាប្រវត្តិវិទ្យា និងគីមីវិទ្យាបន្ថែម និងសិក្សាឲ្យបានស៊ីជម្រៅ ទៅលើបញ្ហាអវត្តមានសិស្សផងដែរ។

# ឯកសារយោង


1. គម្រោងកែលម្អការអប់រំមធ្យមសិក្សា. (២០១៦, វិច្ឆិកា).

2. *គោលនយោបាយស្តីពីគ្រូបង្រៀន.* (២៧ ឧសភា ២០១៣).

3. *ច្បាប់ស្តីពីការអប់រំ.* (១៩ តុលា ២០០៧).

4. *នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស.* (២០១៥).

5. *បញ្ញតិនៃការធានាគុណភាពអប់រំ.* (កុម្ភៈ ២០២៥).

6. *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨.* (មីនា ២០១៤).

7. *សេចក្តីព្រាងចុងក្រោយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣.* (ឧសភា ២០១៩).

8. Henly, J. (2005). The primary education improvement project of Vanuatu: A model for teacher development in the Pacific. *Directions: Journal of Educational Studies*, *27*(2), 25-36.

9. Kuroda, K., Kartika, D., & Kitamura, Y. (2017). Implications for teacher training and support for inclusive education in Cambodia: an empirical case study in a developing country. *JICA Research Institute*, (148), 1-47.

10. Bredenberg, K. (2018). Secondary education in Cambodia: The progress of reform. *Phnom Penh*.

11. Razinkina, E., Pankova, L., Trostinskaya, I., Pozdeeva, E., Evseeva, L., & Tanova, A. (2018). Student satisfaction as an element of education quality monitoring in innovative higher education institution. In *E3S Web of Conferences* (Vol. 33, p. 03043). EDP Sciences.

12. Lin, D. (2019). *Cambodia-Secondary Education Improvement Project-Revised Audited Financial Statement (6Jul17 to 31Dec18)* (No. AUD0025149, pp. 1-0). The World Bank.

13. Chieap, R. (2017). *2.3-KH_SEIP_RPF_FINAL04102016-MKT-Sarin_JUAN Rev and Obs (002)-Sarin_ Clean* (No. SFG2696, pp. 1-89). The World Bank.

14. Vicera, C. R., & Laude, A. Efficacy of the Secondary Education Development and Improvement Project (SEDIP) in Biliran Division, Philippines.

15. https://www.moeys.gov.kh/index.php/kh/eeqp/project-information.html

16. http://www.reednepal.org/secondary-education-improvement-project/

# ឧបសម្ព័ន្ធ

# កម្រងសំណួរសម្រាប់សិស្ស

នាងខ្ញុំឈ្មោះ យឿន វន្ថា ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ **ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) ដែលជួយដល់ការបង្រៀន និងរៀន ករណីសិក្សា៖ វិទ្យាល័យបវេល ខេត្តបាត់ដំបង** ។ អាស្រ័យហេតុនេះសូមលោកនាយក/នាយិកា មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះតាមភាពជាកស្តែងរបស់ខ្លួន។ *រាល់ចម្លើយរបស់លោកនាយក/នាយិកាទាំងអស់ នឹងត្រូវបានរក្សាជាការសម្ងាត់ និងត្រូវបានប្រើសម្រាប់តែការសរសេរនិក្ខេបបទនេះប៉ុណ្ណោះ*។ សូមថ្លែងអំណរគុណដល់សិស្សានុសិស្សទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយនាងខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់នេះ។

សូមបំពេញដោយគូសសញ្ញា ✓ ក្នុងប្រអប់ ☐ និងបំពេញចន្លោះតាមភាពជាក់ស្តែងរបស់ប្អូនដែលបានជ្រើសរើស។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

**ខេត្ត បាត់ដំបង**

១. ស្រុក:........................................ ២.សាលា:...............................................

៣. ភេទ៖ ☐ ស្រី ☐ ប្រុស

**ផ្នែកទី២៖ គុណវុឌ្ឍិគ្រូបង្រៀន**

៤. តើលោកគ្រូ អ្នកគ្រូរបស់ប្អូនមានចំណេះដឹងកម្រិតណា?

☐១. ខ្លាំងណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.ខ្សោយ

៥.តើលោកគ្រូ អ្នកគ្រូដែលមានសមត្ថភាពខ្ពស់ ជួយឲ្យប្អូនឆាប់យល់មេរៀនបានកម្រិតណា?

☐១. ខ្លាំងណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.ខ្សោយ

៦.តើប្អូនយល់ឃើញយ៉ាងណា ចំពោះការបង្រៀនរបស់លោកគ្រូ អ្នកគ្រូរបស់ប្អូន?

☐១. ល្អណាស់ ☐២.ល្អ ☐៣.មធ្យម ☐៤.ខ្សោយ

## ផ្នែកទី៣៖ កម្មវិធីសិក្សា

៧.តើខ្លឹមសារមេរៀនក្នុងសៀវភៅពុម្ព សមស្របទៅនឹងកម្រិតសមត្ថភាពរបស់ប្អូនៗឬទេ?

☐១.មានកម្រិតខ្ពស់ជាងសមត្ថភាពរបស់ខ្ញុំ ☐២.សមស្របនឹងសមត្ថភាពរបស់ខ្ញុំ

☐៣.ទាបជាងសមត្ថភាពរបស់ខ្ញុំ

៨.តើប្អូនចាប់អារម្មណ៍ ដូចម្តេចចំពោះសៀវភៅពុម្ព ដែលកំពុងរៀនសព្វថ្ងៃ?

☐១.គួរឲ្យចាប់អារម្មណ៍ខ្លាំង ☐២.មិនសូវគួរឲ្យចាប់អារម្មណ៍

៩. តើក្នុងមួយខែ ប្អូនត្រូវឆ្លងកាត់ការធ្វើតេស្តស្តង់ដាប៉ុន្មានដង?

☐១. ១ដង ☐២.២ដង ☐៣.៣ដង ☐៤.៤ដង

១០. តើប្អូនយល់យ៉ាងណា ចំពោះការធ្វើតេស្តស្តង់ដារាល់ខែនោះ?

☐១. ល្អណាស់ ☐២.ល្អ ☐៣.មធ្យម ☐៤.ខ្សោយ

១១. តើគម្រោងSEIP នេះ បានជួយដល់ការសិក្សារបស់ប្អូនៗកម្រិតណាដែរ?

☐១.ខ្លាំងណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.តិចតួច ☐៥.អត់សោះ

## ផ្នែកទី៤. សកម្មភាពរៀនក្នុងថ្នាក់

១២.តើលោកគ្រូ អ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការបង្រៀនបានកម្រិតណា?

| សកម្មភាព | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|
| ១.សិស្សធ្វើម្នាក់ឯង | | | | | |
| ២.សិស្សធ្វើការជាដៃគូរ | | | | | |
| ៣.សិស្សធ្វើការជាក្រុម | | | | | |
| ៤.សិស្សទាំងអស់ធ្វើការរួមគ្នា | | | | | |

១៣. តើលោកគ្រូ អ្នកគ្រូបានព្យាយាមលើកទឹកចិត្តសិស្សដល់កម្រិតណានៅពេលបង្រៀន?

☐១.គ្រប់ពេល ☐២.ញឹកញាប់ ☐៣.ម្តងម្កាល ☐៤.អត់សោះ

## ផ្នែកទី៥. បរិមាណសិស្សក្នុងថ្នាក់

១៤. តើជាមធ្យម ថ្នាក់រៀនដែលលោកគ្រូ អ្នកគ្រូបង្រៀនមានសិស្សចំនួនប៉ុន្មាននាក់?

☐១.៣០-៤០ ☐២.៤១-៤៥ ☐៣.៤៦-៥០ ☐៤.ច្រើនជាង៥០

១៥.តើប្អូនៗយល់ថាចំនួនសិស្សច្រើនក្នុងថ្នាក់ធ្វើឲ្យជះឥទ្ធិពលអវិជ្ជមានដល់ការរៀន និងការបង្រៀនរបស់ប្អូនៗដល់កម្រិតណា?

☐១.ខ្លាំងណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.តិចតួច ☐៥.អត់សោះ

## ផ្នែកទី៦. ស្ថានភាពសិក្សារបស់សិស្ស

១៦. តើប្អូនបានប្រឹងប្រែងក្នុងការសិក្សានៅក្នុងថ្នាក់ដល់កម្រិតណា?

| សកម្មភាព | កម្រិតនៃការប្រឹងប្រែង | | | | |
|---|---|---|---|---|---|
| | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ខ្សោយ |
| ១.មករៀនទៀងទាត់ និងទាន់ពេលវេលា | | | | | |
| ២.យកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា | | | | | |
| ៣.ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូដាក់ឲ្យក្នុងថ្នាក់ | | | | | |
| ៤.ធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឲ្យទៀងទាត់ | | | | | |

១៧. សំណូមពរទាក់ទងនឹងបញ្ហាប្រឈមនានា ចំពោះការសិក្សារបស់ប្អូន។

.....................................................................................................................

.....................................................................................................................

.....................................................................................................................

...................................................................................................................។

# កម្រងសំណួរសម្រាប់គ្រូ

នាងខ្ញុំឈ្មោះ យឿន វន្ថា ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បាន រៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ **ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) ដែលជួយដល់ការបង្រៀន និងរៀន ករណីសិក្សា៖ វិទ្យាល័យបវេល ខេត្តបាត់ដំបង** ។ អាស្រ័យហេតុនេះសូមលោកនាយក/នាយិកា មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះតាមភាពជាកស្តែងរបស់ខ្លួន។ *រាល់ចម្លើយរបស់លោកនាយក/នាយិកាទាំងអស់ នឹងត្រូវបានរក្សាជាការសម្ងាត់ និងត្រូវបានប្រើសម្រាប់តែការសរសេរនិក្ខេបបទនេះប៉ុណ្ណោះ*។ សូមថ្លែងអំណរគុណដល់លោកនាយក-នាយិកាទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយនាងខ្ញុំក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់នេះ។

សូមបំពេញដោយគូសសញ្ញា √ ក្នុងប្រអប់ □និងបំពេញចន្លោះតាមភាពជាក់ស្តែងរបស់លោកនាយក/នាយិកាដែល បានជ្រើសរើស។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

### ខេត្ត បាត់ដំបង

១. ភេទ៖ ស្រី□ ប្រុស □

២. ស្រុក:........................................ ៣. សាលា:................................................

៤.មុខវិជ្ជា៖........................................

៥. បង្រៀនថ្នាក់ទី □ថ្នាក់ទី៧ □ថ្នាក់ទី៨ □ថ្នាក់ទី៩ □ថ្នាក់ទី១០

## ផ្នែកទី២៖ គុណវុឌ្ឍិគ្រូបង្រៀន

៦. តើលោកគ្រូ អ្នកគ្រូមានក្របខណ្ឌប្រភេទអ្វី?

□១. គ្រូបង្រៀនកម្រិតបឋម □២. គ្រូបង្រៀនកម្រិតមូលដ្ឋាន

□៣. គ្រូបង្រៀនកម្រិតឧត្តម

៧. សូមបញ្ជាក់ពីកម្រិតសញ្ញាបត្រចុងក្រោយរបស់លោកគ្រូ អ្នកគ្រូ៖

☐១. សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

☐២. សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

☐៣. សញ្ញាបត្របរិញ្ញាបត្រ

☐៤. សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់

☐៥. សញ្ញាបត្របណ្ឌិត

៨. តើលោកគ្រូ អ្នកគ្រូយល់ថា នៅពេលដែលគ្រូមានសមត្ថភាពខ្ពស់ អាចជួយសិស្សឲ្យឆាប់យល់មេរៀនដល់កម្រិតណា?

☐ ១. ខ្លាំណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.តិចតួច ☐៥. អត់សោះ

៩. តើលោកគ្រូ អ្នកគ្រូ មានបទពិសោធបង្រៀនអស់រយៈប៉ុន្មានឆ្នាំ?

☐ ១.តិចជាង៥ឆ្នាំ ☐២.៦-១០ឆ្នាំ ☐៣.១១-១៥ឆ្នាំ ☐៤.ច្រើនជាង១៥ឆ្នាំ

១០. តើលោកគ្រូ អ្នកគ្រូបានឆ្លងកាត់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាក់ទងនឹងគរុកោសល្យ ឬវិធីសាស្ត្រ បង្រៀនលើឯកទេសរបស់ខ្លួន ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ឬទេ?

☐១. បាន ☐២. មិនបាន

១១. តើលោកគ្រូ អ្នកគ្រូគិតថា ការចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានោះមានសារៈប្រយោជន៍ដល់ការបង្រៀនលើឯកទេសរបស់លោកគ្រូ អ្នកគ្រូបានកម្រិតណា?

☐ ១. ខ្លាំណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.តិចតួច ☐៥. អត់សោះ

១២. សូមជ្រើសរើសវគ្គបំប៉នខាងក្រោមចំនួន ៣ ដែលលោកគ្រូ អ្នកគ្រូត្រូវការចាំបាច់ ដើម្បីបង្រៀនមុខវិជ្ជារបស់ ខ្លួននៅមធ្យមសិក្សា៖

☐១.ចិត្ត-គរុកោសល្យ ☐ ២.វិធីសាស្ត្របង្រៀន

☐៣.ពង្រឹងចំណេះដឹងមុខវិជ្ជាឯកទេស ☐៤.បច្ចេកវិទ្យាព័ត៌មាន (ICT)

☐៥.ការផលិត និងការប្រើប្រាស់សម្ភារឧបទេស

**ផ្នែកទី៣៖ កម្មវិធីសិក្សា**

១៣. តើលោកគ្រូ អ្នកគ្រូ មានបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ សម្រាប់ការប្រើប្រាស់ក្នុងកាបង្រៀន ដែរ ឬទេ?

☐១. មាន ☐២. គ្មាន

១៤.តើកម្មវិធីសិក្សា មានសារៈសំខាន់កម្រិតណាដល់ការបង្រៀននៅតាមមុខវិជ្ជានីមួយៗរបស់លោកគ្រូអ្នកគ្រូ?

☐ ១. ខ្លាំណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.តិចតួច ☐៥. អត់សោះ

១៥. តើសាលារៀនរបស់លោកគ្រូ អ្នកគ្រូ មានបន្ទប់ពិសោធន៍ដែរ ឬទេ?

☐១. មាន ☐២. គ្មាន

១៦. បើមាន តើក្នុងមួយសប្តាហ៍មានការធ្វើពិសោធ ឬអនុវត្តប៉ុន្មានម៉ោង?

☐ ១. ១ម៉ោង ☐២.២ម៉ោង ☐៣.៣ម៉ោង ☐៤.៤ម៉ោង ☐៥.មិនបានសោះ

១៧. តើនៅសាលារៀនរបស់លោកគ្រូ អ្នកគ្រូ មានបន្ទប់បណ្ណាល័យសម្រាប់គាំទ្រដល់ការរៀន និងបង្រៀនដែរ ឬទេ?

☐១. មាន ☐២. គ្មាន

១៨. តើលោកគ្រូ អ្នកគ្រូចូលស្រាវជ្រាវ ឬដឹកនាំសិស្សចូលបណ្ណាល័យប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍?

☐១.១ម៉ោង ☐២.២ម៉ោង ☐៣.៣ម៉ោង ☐៤.៤ម៉ោង ☐៥.អត់សោះ

១៩. តើក្នុងមួយខែមានការធ្វើតេស្តសិស្សប៉ុន្មានដង?

☐១. ១ដង ☐២.២ដង ☐៣.៣ដង ☐៤.៤ដង

២០. តើលោកគ្រូ អ្នកគ្រូជ្រើសរើសគោលវិធីអ្វី ក្នុងការបង្រៀន?

☐១. គ្រូមជ្ឈមណ្ឌល ☐២. សិស្សមជ្ឈមណ្ឌល

២១. តើលោកគ្រូ អ្នកគ្រូជ្រើសរើសវិធីសាស្ត្រអ្វី ក្នុងការបង្រៀន?

☐ ១. តាមបែបរិះរក(IBL) ☐២.តាមបែបសហការ

☐ ៣. វិធីវិទ្យាសាស្ត្រ ☐៤. តាមបែបផែនទីគំនិត

☐៥. តាមបែបតុក្កតាគំនិត ☐៦.តាមបែបដោះស្រាយបញ្ហា

☐៧.ប្រើវិធីទាំងអស់ខាងលើ

២២. តើលោកគ្រូ អ្នកគ្រូប្រើអ្វី ដើម្បីសរសេរកិច្ចតែងការបង្រៀន?

☐១. ឧបករណ៍អេឡិចត្រូនិច ☐២.សរសេរដោយដៃ

២៣. តើលោកគ្រូ អ្នកគ្រូធ្វើកិច្ចតែងការបង្រៀនបានគ្រប់មេរៀនដែរ ឬទេ?

☐១.គ្រប់ពេល ☐២.ពេលខ្លះ ☐៣.កម្រណាស់ ☐៤.អត់សោះ

២៤. តើលោកគ្រូ អ្នកគ្រូ ដាក់កិច្ចការផ្ទះឲ្យសិស្សប៉ុន្មានដងក្នុងមួយសប្តាហ៍?

☐១. ១ដង ☐២.២ដង ☐៣.៣ដង

២៥. តើសិស្សប៉ុន្មានភាគរយធ្វើកិច្ចការផ្ទះ?

☐១.២០%-៤០% ☐២.៤០%-៦០% ☐៣.៦០%-៨០% ☐៤.៨០%-១០០%

២៦. តើម៉ោងបង្រៀនមុខវិជ្ជានីមួយៗរបស់លោកគ្រូ អ្នកគ្រូគ្រប់គ្រាន់សម្រាប់ឲ្យសិស្សចេះដែរ ឬទេ?

☐១. គ្រប់គ្រាន់ (សូមបន្តទៅសំណួរ២៨)

☐២. មិនគ្រប់គ្រាន់

២៧. បើមិនគ្រប់គ្រាន់ តើម៉ោងសិក្សាមុខវិជ្ជានីមួយៗនៅសាលារដ្ឋ គួរតែមានប៉ុន្មានម៉ោងក្នុងមួយថ្នាក់ក្នុងមួយសប្តាហ៍សម្រាប់ការសិក្សារបស់សិស្ស?

☐១. ២ម៉ោង ☐២. ៤ម៉ោង ☐៣.៥ម៉ោង ☐៤.៦ម៉ោង ☐៥. ៧ម៉ោង

## ផ្នែកទី៤. សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់

២៨.តើលោកគ្រូ អ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការបង្រៀនបានកម្រិតណា?

| សកម្មភាព | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|
| ១.សិស្សធ្វើម្នាក់ឯង | | | | | |
| ២.សិស្សធ្វើការជាដៃគូរ | | | | | |
| ៣.សិស្សធ្វើការជាក្រុម | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤.សិស្សទាំងអស់ធ្វើការរួមគ្នា | | | | | |

២៩. តើលោកគ្រូ អ្នកគ្រូបានព្យាយាមលើកទឹកចិត្តសិស្សដល់កម្រិតណានៅពេលបង្រៀន?

☐១.គ្រប់ពេល ☐២.ញឹកញាប់ ☐៣.ម្តងម្កាល ☐៤.អត់សោះ

## ផ្នែកទី៥. បរិមាណសិស្សក្នុងថ្នាក់

៣០. តើជាមធ្យម ថ្នាក់រៀនដែលលោកគ្រូ អ្នកគ្រូបង្រៀនមានសិស្សចំនួនប៉ុន្មាននាក់?

☐១.៣០-៤០ ☐២.៤១-៤៥ ☐៣.៤៦-៥០ ☐៤.ច្រើនជាង៥០

៣១.តើលោកគ្រូ អ្នកគ្រូយល់ថាចំនួនសិស្សច្រើនក្នុងថ្នាក់ធ្វើឲ្យជះឥទ្ធិពលអវិជ្ជមានដល់ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូដល់កម្រិតណា?

☐១.ខ្លាំងណាស់ ☐២.ខ្លាំង ☐៣.មធ្យម ☐៤.តិចតួច ☐៥.អត់សោះ

## ផ្នែកទី៦. វិន័យ

៣២. តើសាលាមានវិធានការបែបណាចំពោះសិស្សដែលមិនគោរពវិន័យ?

☐១.បញ្ឈប់ការសិក្សា ☐២.ដកពិន្ទុ ☐៣.ផ្តល់ដំណឹងដល់ឪពុកម្តាយ

☐៤. ផាកពិន័យជាប្រាក់ ☐៥.សរសេរកិច្ចសន្យា

៣៣. តើក្នុងថ្នាក់ជាមធ្យមសិស្សអវត្តមានប៉ុន្មាននាក់?

☐១.១នាក់ ☐២.២នាក់ ☐៣.៣នាក់ ☐៤.៤នាក់ ☐៥.ច្រើនជាង ៤នាក់

៣៤. តើសិស្សមករៀនទៀងពេលមានប៉ុន្មានភាគរយ?

☐១.៥០% ☐២.៦០% ☐៣.៧០% ☐៤.៨០% ☐៥.៩០% ☐៦.១០០%

## ផ្នែកទី៧. បរិស្ថានសិក្សា

៣៥. តើសាលារបស់លោកគ្រូ អ្នកគ្រូ មានការចុះកម្មសិក្សាដែរ ឬទេក្នុងមួយឆ្នាំ?

☐១.បាន ☐២.មិនបាន

៣៦. តើការសិក្សាភាគច្រើនប្រព្រឹត្តទៅនៅកន្លែងណា?

☐ ១. ថ្នាក់រៀន ☐២. ទីសោធន៍ ☐៣. បរិវេណសាលា ☐៤.ទាំងបីខាងមុខ

៣៧. តើរវាង គ្រូនិងសិស្ស ហើយ សិស្សនិងគ្រូ មានទំនាក់ទំនងគ្នាត្រឹមកម្រិតណា?

☐១.ខ្សោយ ☐២.មធ្យម ☐៣. ល្អបង្គួរ ☐៤.ល្អ ☐៥.ល្អណាស់ ☐៦.ល្អប្រសើរ

**ផ្នែកទី៨. ប្រសិទ្ធភាព**

៣៨. កម្រិតវប្បធម៌របស់លោកគ្រូ អ្នកគ្រូ

☐១.សញ្ញាបត្រទុតិយភូមិ ☐២.បរិញ្ញាបត្រ ☐៣.បរិញ្ញាបត្រជាន់ខ្ពស់ ☐៤.បណ្ឌិត

៣៩.បទពិសោធនៃការបង្រៀន

☐១.១ទៅ៣ឆ្នាំ ☐២.៣ទៅ៦ឆ្នាំ ☐៣.៦ទៅ៩ឆ្នាំ ☐៤.៩ឆ្នាំឡើង

៤០. ក្នុងគ្រូម្នាក់បង្រៀនប៉ុន្មានកម្រិតថ្នាក់?

☐១.មួយកម្រិត ☐២.ពីកម្រិត ☐៣.បីកម្រិត

៤១. តើក្នុងមួយខែប្រជុំបច្ចេកទេសប៉ុន្មានដង?

☐១. មួយដង ☐២.ពីដង ☐៣.បីដង ☐៤. បួនដង ☐៥. ច្រើនជាង៤ដង

៤២. តើចំណុចខ្លាំង និងចំណុចខ្សោយនៃគម្រោងSEIP?

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| ១.................................................... | ១.................................................... |
| ២.................................................... | ២.................................................... |
| ៣.................................................... | ៣.................................................... |
| ៤.................................................... | ៤.................................................... |

# **ក្រម្រងសំណួរសម្រាប់នាយក**

នាងខ្ញុំឈ្មោះ យឿន វន្ថា ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បាន រៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ **ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា(SEIP) ដែលជួយដល់ការបង្រៀន និងរៀន ករណីសិក្សា៖ វិទ្យាល័យបវេល ខេត្តបាត់ដំបង** ។ អាស្រ័យហេតុនេះសូមលោកនាយក/នាយិកា មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះតាមភាពជាក់ស្តែងរបស់ខ្លួន។ ***រាល់ចម្លើយរបស់លោកនាយក/នាយិកាទាំងអស់ នឹងត្រូវបានរក្សាជាការសម្ងាត់ និងត្រូវបានប្រើសម្រាប់តែការសរសេរនិក្ខេបបទនេះប៉ុណ្ណោះ***។ សូម ថ្លែងអំណរគុណដល់លោកនាយក-នាយិកាទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយនាងខ្ញុំក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់នេះ។

សូមបំពេញដោយគូសសញ្ញា √ ក្នុងប្រអប់ ☐និងបំពេញចន្លោះតាមភាពជាក់ស្តែងរបស់លោកនាយក/នាយិកាដែល បានជ្រើសរើស។

## **ផ្នែកទី១៖ ព័ត៌មានទូទៅ**

**ខេត្ត បាត់ដំបង**

១. ស្រុក:............................................... ២.សាលា:.................................................

៣. ឋានៈតួនាទី: ☐១. នាយក/នាយិកា ☐២. នាយករង/នាយិការង

៤. ភេទ៖ ☐ ស្រី ☐ ប្រុស

## **ផ្នែកទី២៖ គុណវុឌ្ឍិនាយកសាលា**

៥. តើលោកនាយក/នាយិកាមានតួនាទីជានាយកនៅសាលានេះប៉ុន្មានឆ្នាំមកហើយ?

☐១. ១ឆ្នាំដល់ ៥ឆ្នាំ ☐២.៥ឆ្នាំ ដល់ ១០ឆ្នាំ

☐៣. ១០ឆ្នាំ ដល់ ២០ឆ្នាំ ☐៤. ច្រើនជាង ២០ឆ្នាំ

៦. តើលោកនាយក/នាយិកាមានក្រខណ្ឌប្រភេទអ្វី?

☐១. គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐ ២. គ្រូបង្រៀនកម្រិតឧត្តម

៧. សូមបញ្ជាក់កម្រិតសញ្ញាបត្រចុងក្រោយរបស់លោកនាយក/នាយិកា៖

☐១. សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ☐២. សញ្ញាបត្របរិញ្ញាបត្រ

☐៣. សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ☐៤.សញ្ញាបត្របរិញ្ញាបត្របណ្ឌិត

៨. តើលោកនាយក/លោកស្រីនាយិកា ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗទាក់ទងនឹងការគ្រប់គ្រងដែរ ឬទេ?

☐១. បាន ☐ ២. មិនបាន

៩. បើបាន វគ្គនោះមានរយៈពេលប៉ុន្មាន?

..............................................................................................................................

.............................................................................................................................។

១០. តើលោកនាយក/លោកស្រីនាយិកា ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗទាក់ទងនឹងគម្រោង SEIP ដែរ ឬទេ?

☐១. បាន ☐ ២. មិនបាន

១១. បើបាន វគ្គនោះមានរយៈពេលប៉ុន្មាន? វគ្គនោះស្តីអំពីអ្វី?

..............................................................................................................................

.............................................................................................................................។

**ផ្នែកទី៣៖ ការគ្រប់គ្រងសាលារៀន**

១២. តើសាលារៀនមានគ្រូបង្រៀនសរុបប៉ុន្មាននាក់? ស្រីប៉ុន្មាន?

.................................................................................................................................។

១៣. តើសាលារៀនមានគ្រូកម្រិតបឋមភូមិចំនួនប៉ុន្មាននាក់? គ្រូកម្រិតឧត្តមចំនួនប៉ុន្មាននាក់?

.................................................................................................................................។

១៤. តើមានគ្រូប៉ុន្មាននាក់ដែលទទួលបានការបណ្តុះបណ្តាលជំនាញ ឬឯកទេសបន្ថែមតាមរយៈគម្រោងSEIP?

.................................................................................................................................។

១៥. ក្រោយពេលដែលលោកគ្រូ អ្នកគ្រូបានឆ្លងកាត់ការបណ្តុះបណ្តាលបន្ថែមរួម តើពួកគាត់បានចែករំលែក ចំណេះដឹងថ្មីនោះកម្រិតណាដែរ ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅក្នុងសាលា?

.................................................................................................................................។

១៦.តើលោកនាយក/នាយិកាគិតថា លោកគ្រូ អ្នកគ្រូ បានអនុវត្តការងាររបស់ខ្លួនដល់កម្រិតណាពាក់ព័ន្ធ ទៅនឹង៖

១. ការមកបង្រៀនទៀតទាត់

.................................................................................................................................។

២. ការរៀបចំកិច្ចតែងការបង្រៀន

.................................................................................................................................។

៣. ការពង្រឹងចំណេះដឹង និងជំនាញទាក់ទងនឹងមុខវិជ្ជាកំពុងបង្រៀន

.................................................................................................................................។

៤. ការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស

..........................................................................................................................................។

១៧. តើលទ្ធផលសិក្សារបស់សិស្សឆ្នាំចាស់( ឆ្នាំចាប់ផ្តើមគម្រោងSEIP) យ៉ាងណាដែរ?

១. ភាគយជាប់៖.............................?        ២. ភាគរយធ្លាក់៖..............................?

១៨. តើសាលារៀនមានកម្មវិធីជួយសិស្សដែលរៀនយឺតដែរ ឬទេ ?

☐ ១. មាន        ☐២. គ្មាន

១៩. បើមាន តើមានមុខវិជ្ជាអ្វីខ្លះដែល ត្រូវបំប៉នសិស្សបន្ថែម ?

.......................................................................................................................................។

២០.តើសាលារៀនមានចំនួនសិស្សដែលជួបការលំបាកប៉ុន្មាននាក់ ?

☐ ១. មាន        ☐២. គ្មាន

២១. តើសាលាបានជួយអ្វីខ្លះដល់ សិស្សានុសិស្សដែលមានកាលំបាកក្នុងការសិក្សាទាំងនោះ ?

..........................................................................................................................................។

## ផ្នែកទី៤៖ សម្ភារសិក្សា

២២. តើសិស្សានុសិស្សមានសៀវភៅគោល សម្រាប់សិស្សគ្រប់គ្រាន់ដែរ ឬទេ ?

..........................................................................................................................................។

២៣. តើសាលារៀនមានបណ្ណាល័យសម្រាប់គាំទ្រដល់ការរៀនសូត្ររបស់សិស្សបន្ថែមដែរ ឬទេ ?

☐ ១. មាន        ☐ ២. គ្មាន

២៤. តើសាលារៀនមានអគារសិក្សាគ្រប់គ្រាន់ដែរ ឬទេ ?

☐ ១. មាន ☐ ២. គ្មាន

២៥. តើបច្ចុប្បន្ន មានសិស្សសរុបចំនួនប៉ុន្មានថ្នាក់? ហើយបើមិនគ្រប់គ្រាន់ នៅខ្វះចំនួនប៉ុន្មានថ្នាក់?

.....................................................................................................................។

២៦. តើសាលារៀនមានកន្លែងស្នាក់នៅសម្រាប់លោកគ្រូ ឬអ្នកគ្រូ និងសិស្សដែលមកពីឆ្ងាយដែរ ឬទេ?

☐ ១. មាន ☐ ២. គ្មាន

២៧. តើលោកនាយក/នាយិកា មានសំណូមពរអ្វីខ្លះ ដើម្បីឲ្យស្ថានភាពនៃការបង្រៀន និងរៀននៅក្នុងសាលា របស់លោកនាយក/នាយិកាកាន់តែប្រសើរជាងនេះទៀត?

........................................................................................................................

........................................................................................................................

........................................................................................................................

.....................................................................................................................។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :១៤៣ វជអ.**

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **យឿន វន្ថា** នៅវិទ្យាល័យ បវេល ក្នុងខេត្តបាត់ដំបង។
**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា លោកស្រី **យឿន វន្ថា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧របស់ក្រសួងអប់រំ យុ វជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំមានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី«**ប្រសិទ្ធភាពនៃការអនុវត្តគម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP) នៅវិទ្យាល័យ បវេល** »ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ លោកស្រី **យឿន វន្ថា** នឹងសម្ភាសន៍តាមប្រព័ន្ធ ONLINE ពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សថ្នាក់ទី១០ ដែលកំពុងសិក្សានៅវិទ្យាល័យ បវេល នៅខេត្តបាត់ដំបង ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៅរឿន សុវណ្ណា**

លេខ.១៦៩៤......អយកខ.មចទ
បានឃើញ និងឯកភាព
**បញ្ជូនមកលោកនាយកវិទ្យាល័យបវេល**
**"ដើម្បីសហការ"**
ថ្ងៃ៧រោចខែ៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័កព.ស២៥៦៤
បាត់ដំបងថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០២០
**ប្រធានមន្ទីរ** ៥
**អនុប្រធាន**

**មាស_តិរុណ**